


# របាយការណ៍ត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត នៅកម្ពុជា

ខែឧសភា ឆ្នាំ២០២៣

រៀបចំដោយ

គាំទ្រដោយ

UCLG ASPAC United Cities and Local Governments Asia Pacific

UCLG United Cities and Local Governments

Global Affairs Canada / Affaires mondiales Canada

FCM Federation of Canadian Municipalities / Fédération canadienne des municipalités

# របាយការណ៍ត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត នៅកម្ពុជា

កាលបរិច្ឆេទ បោះពុម្ព ៖ ខែឧសភា ឆ្នាំ២០២៣

ឯកសារបោះពុម្ពនេះត្រូវបានធ្វើឡើង និងចែកចាយដោយ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ក្រោមការគាំទ្រពី សហភាពទីក្រុង និងអភិបាលកិច្ចមូលដ្ឋាន (UCLG), សហភាពទីក្រុង និងអភិបាលកិច្ចមូលដ្ឋាន អាស៊ីប៉ាស៊ីភិច (UCLG-ASPAC) និង សហព័ន្ធទីក្រុងនៃប្រទេសកាណាដា (FCM) តាមរយៈមូលនិធិកិច្ចការសកល ប្រទេសកាណាដា

រក្សាសិទ្ធិគ្រប់យ៉ាង ដោយគ្មានផ្នែកណាមួយនៃឯកសារនេះត្រូវបានអនុញ្ញាតឲ្យថតចម្លង ឬបោះពុម្ពឡើងវិញ ឬ សរសេរឡើងវិញ នៅក្នុងទម្រង់ណាក៏ដោយ ដែលធ្វើឡើងក្នុងរូបភាពចែកចាយឬលក់ដូរ ដោយគ្មានការអនុញ្ញាតពីសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានបានទេ។

សហការគាំទ្រថវិកាដោយ សហគមន៍អឺរ៉ុប

ឯកសារបោះពុម្ពនេះត្រូវបានធ្វើឡើង បានទទួលការគាំទ្រហិរញ្ញប្បទានពីសហគមន៍អឺរ៉ុប។ ខ្លឹមសារនៃឯកសារនេះ ជាការទទួលខុសត្រូវរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហគមន៍អឺរ៉ុបទេ។

# បុព្វកថា

ប្រទេសជាសមាជិកនៃអង្គការសហប្រជាជាតិ រួមទាំងកម្ពុជាផងបានទទួលយក និងបំប្លែងរបៀបវារៈសកលឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដែលបានអនុម័តកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥។ ប្រទេសជាសមាជិកទាំងអស់ឯកភាព យល់ព្រមកសាងផែនការសកម្មភាពរបស់ខ្លួនឆ្ពោះទៅធ្វើឱ្យសង្គមកាន់តែមានចីរភាព។ ពោល គឺលុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លាន និងការពារភេពផែនដីដោយគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ព្រមទាំងអនុវត្តវិធានការមានប្រសិទ្ធភាពនានាដើម្បីដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ។ ក្រៅពីនេះ គឺជំរុញឱ្យមានយុត្តិធម៌សង្គម និងសន្តិភាពប្រកបដោយបរិយាប័ន្ន ជៀសផុតពីភាពភ័យខ្លាច និងអំពើហឹង្សាគ្រប់ទម្រង់។ ដោយឡែក ប្រទេសកម្ពុជា បានអនុវត្តគោលដៅទី១៨ មួយបន្ថែមទៀត គឺធ្វើឱ្យកម្ពុជាគ្មានគ្រាប់មីន និងសំណល់មិនទាន់ផ្ទុះពីសង្គ្រាម។

ការធ្វើមូលដ្ឋានីយកម្ម និងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទាមទារកិច្ចខិតខំប្រឹងប្រែងជាលក្ខណៈប្រមូលផ្តុំនៅគ្រប់កម្រិត ព្រមទាំងទទួលស្គាល់ថា គេមិនត្រូវពឹងផ្អែកតែលើរដ្ឋាភិបាលមជ្ឈឹមនោះទេ។ គ្រប់ប្រទេសទាំងអស់ មានអាជ្ញាធរមូលដ្ឋាន/អាជ្ញាធរតំបន់ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាតួអង្គសំខាន់ក្នុងការជំរុញឱ្យមានសង្គមមួយប្រកបដោយនិរន្តរភាពល្អ។

ការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តស្តីពីការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព បានឆ្លុះបញ្ចាំងពីការរួមវិភាគទានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និងបានឆ្លុះបញ្ចាំងពីទស្សនៈវិស័យក្នុងការពង្រីកវិសាលភាព ព្រមទាំងធ្វើឱ្យកាន់តែមានដំណោះស្រាយទូលំទូលាយថែមទៀតផង។

រាជរដ្ឋាភិបាលកម្ពុជាបានពុះពារ និងបន្ថែមកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្រោមគំនិតផ្តួចផ្តើមកំណែទម្រង់ជាតិដ៏ស៊ីជម្រៅ។ នុំះ គឺកិច្ចខិតខំប្រឹងប្រែងកំណែទម្រង់ពីអភិបាលកិច្ចជាប្រពៃណីយូរលង់ឱ្យទៅជាអភិបាលកិច្ចបែបវិមជ្ឈការ និងវិសហមជ្ឈការ សំដៅលើកកម្ពស់ការអភិវឌ្ឍបែបប្រជាធិបតេយ្យ។ កំណែទម្រង់នេះបានបង្កើតឱ្យមានទំនាក់ទំនងល្អរវាងរដ្ឋ និងថ្នាក់ក្រោមជាតិ ព្រមទាំងបង្កើតឱ្យមានរចនាសម្ព័ន្ធភ្នាក់ងារជាតិនៅគ្រប់កម្រិត។ លើសពីនេះទៅទៀត កំណែទម្រង់ខាងលើ បានបង្កើតឱ្យមានលក្ខខណ្ឌល្អក្នុងការបំពេញភារកិច្ចប្រកបដោយកិច្ចសហការ សំដៅធ្វើការអភិវឌ្ឍប្រកបដោយចីរភាព។

កំណែទម្រង់ទាំងអស់ បានបើកផ្លូវឱ្យថ្នាក់ក្រោមជាតិដើរតួនាទីកាន់តែសំខាន់ក្នុងការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា។ ការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តបានបញ្ជាក់យ៉ាងច្បាស់ថា រដ្ឋបាលថ្នាក់ក្រោមជាតិពិតជាបាននឹងកំពុងដើរតួនាទីជាផ្លូវការយ៉ាងសំខាន់ក្នុងការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ថ្នាក់ក្រោមជាតិបានប្រើប្រាស់ធនធានវិភាជន៍ពីថ្នាក់ជាតិ ជំនួយពីដៃគូអភិវឌ្ឍន៍ និងធនធានកៀរគរបានពីក្នុងមូលដ្ឋានក្នុងការអនុវត្តគម្រោង។ ពិសេសជាងនេះទៅទៀត ការត្រួតពិនិត្យថ្នាក់

ក្រោមជាតិដោយស្ម័គ្រចិត្តបានបញ្ជាក់ថា ភាគច្រើននៃគម្រោងដែលអនុវត្តដោយក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ បានផ្តល់ផលប្រយោជន៍ច្រើន និងដោយផ្ទាល់ដល់សហគមន៍មូលដ្ឋាន។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមថ្លែងអំណរគុណដល់គ្រប់ភាគីពាក់ព័ន្ធដែលបានចូលរួមក្នុងការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តនេះ ចំពោះការចូលរួមដ៏មានតម្លៃ និងការផ្តល់ធាតុចូល ហើយក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការគាំទ្ររបស់សហភាពទីក្រុង និងអភិបាលកិច្ចមូលដ្ឋាន (UCLG លេខាធិការដ្ឋានពិភពលោក) សហភាពទីក្រុង និងអភិបាលកិច្ចមូលដ្ឋានប្រចាំតំបន់អាស៊ីប៉ាស៊ីភិច (UCLG Asia Pacific) និងសហព័ន្ធទីក្រុងនៃប្រទេសកាណាដា (FCM)។



**ឯកឧត្តម សយ កុសល**

ប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន នៅកម្ពុជា

## តារាងមាតិកា


បញ្ជីឈ្មោះអក្សរកាត់ និងសម្រាយ ........................................................................................6
គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងអត្ថន័យសង្ខេប ...............................................10
ផែនទី និងទិន្នន័យគោលប្រទេសកម្ពុជា ..................................................................................12
របកគំហើញសង្ខេប .......................................................................................................................15
ជំពូក ១ ៖ សេចក្តីផ្តើមទូទៅ ..............................................................................................................17
ជំពូក ២ ៖ វិធីសាស្ត្រនៃការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត ........................................ 20
ជំពូក ៣ ៖ គោលនយោបាយ និងបរិយាកាសអំណោយផលដល់ការធ្វើមូលដ្ឋានីយកម្មSDGs............24
៣.១. យុទ្ធសាស្ត្រជាតិសម្រាប់ការអនុវត្ត និងធ្វើមូលដ្ឋានីយកម្មSDGs.......................................24
៣.២. យន្តការសម្របសម្រួលថ្នាក់ជាតិ ...........................................................................................27
៣.៣. ការបង្កើនបរិយាកាសស្ថាប័នសម្រាប់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ.................................... 30
ជំពូក ៤ ៖ សកម្មភាពក្នុងមូលដ្ឋានក្នុងការធ្វើមូលដ្ឋានីយកម្មSDGs ..............................................38
៤.១. សកម្មភាពលើកកម្ពស់ការយល់ដឹង និងភាពជាម្ចាស់លើSDGs .........................................38
៤.២. កិច្ចខិតខំប្រឹងប្រែង និងវិធីសាស្ត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តCSDGs ..........45
៤.៣. វឌ្ឍនភាពនៃការអនុវត្តគោលដៅចំបងៗ ...............................................................................54
៤.៤. គោលដៅអាទិភាពទាំងដប់សម្រាប់អនុវត្តក្រោយវិបត្តិ Covid-19 .........................................54
ជំពូក ៥ ៖ មធ្យោបាយ និងបញ្ហាប្រឈមក្នុងការអនុវត្តCSDGs....................................................76
ជំពូក ៦ ៖ សេចក្តីសំយោគ និងអនុសាសន៍................................................................................78
៦.១. សេចក្តីសំយោគ ......................................................................................................................78
៦.២. ការបរិយាយវិភាគ...................................................................................................................79
៦.៣. អនុសាសន៍.............................................................................................................................79
ឧបសម្ព័ន្ធ A ៖ បញ្ជីឈ្មោះបុគ្គលសំខាន់ៗដែលបានផ្តល់ព័ត៌មាន.................................................82
ឧបសម្ព័ន្ធ B ៖ បញ្ជីគម្រោងដែលបានអនុវត្តដោយ NLC/NACPC និងចូលរួមដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ..........................................................................................................................................83
ឧបសម្ព័ន្ធ C ៖ សមាសភាពអ្នកផ្តល់ចម្លើយក្នុងកម្រងសំណួរ.........................................................85
ឧបសម្ព័ន្ធ D ៖ វឌ្ឍនភាពគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (ឆ្នាំ២០២១) .................88
ឧបសម្ព័ន្ធ E ៖ របាយការណ៍សង្ខេបសិក្ខាសាលាផ្ទៀងផ្ទាត់លទ្ធផល VSR .................................92

# បញ្ជីឈ្មោះអក្សរកាត់ និងសម្រាយ

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី<br>Asian Development Bank |
| API | វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ<br>Advocacy and Policy Institute |
| CAOD | ទីភ្នាក់ងារកាតូលីកសម្រាប់ការអភិវឌ្ឍក្រៅប្រទេស<br>Catholic Agency for Overseas Development |
| CARD/CM | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៃទីស្តីការគណៈរដ្ឋមន្ត្រី<br>Council for Agriculture and Rural Development of the Council of Ministers |
| CBET | សហគមន៍អេកូទេសចរណ៍<br>Community-based Eco-tourism |
| CCC | គណៈកម្មការសម្របសម្រួលកម្ពុជា (ស្ថាប័នសម្របសម្រួលសង្គមស៊ីវិល)<br>Cambodia Coordination Committee (civil society coordination body) |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា<br>Cambodia's Millennium Development Goals |
| CP | រាជធានី ខេត្ត<br>Capital, Province |
| CS | ឃុំ សង្កាត់<br>Commune/Sangkat |
| CSDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា<br>Cambodia's Sustainable Development Goals |
| DA | ទីភ្នាក់ងារអភិវឌ្ឍន៍<br>Development Agencies |
| DANIDA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក<br>Danish International Development Agency |
| DMK | ស្រុក ក្រុង ខណ្ឌ<br>District, Municipality, Khan |
| DMO | អង្គការគ្រប់គ្រងគោលដៅ<br>Destination Management Organization |
| DP | ដៃគូអភិវឌ្ឍន៍<br>Development Partners |
| EIB | ធនាគារវិនិយោគអឺរ៉ុប<br>European Investment Bank |
| EU | សហគមន៍អឺរ៉ុប<br>European Union |
| EWS | ប្រព័ន្ធប្រកាសឱ្យដឹងមុនពីគ្រោះថ្នាក់<br>Early Warning System |
| GEF | មូលនិធិបរិស្ថានសកល |

| | |
|---|---|
| | Global Environmental Fund |
| GIZ/MUSEFO | ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការបច្ចេកទេស អាល្លឺម៉ង់ / សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ពហុវិស័យ<br>German Technical Cooperation/ Multi-sectoral Food Security and Nutrition |
| HKI | អង្គការហេលេនខេល័រអន្តរជាតិ<br>Helen Keller International |
| IEC Material | សម្ភារៈទំនាក់ទំនង អប់រំ និងព័ត៌មាន<br>Information, Education and Communication Material |
| IFAD | មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម<br>International Fund for Agriculture Development |
| IP3 | កម្មវិធីអនុវត្តបីឆ្នាំ<br>Three-Year Implementation Program |
| JICA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិជប៉ុន<br>Japan International Development Agency |
| LED | ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន<br>Local Economic Development |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>Ministry of Economic and Finance |
| MOE | ក្រសួងបរិស្ថាន<br>Ministry of Environment |
| MOI | ក្រសួងមហាផ្ទៃ<br>Ministry of Interior |
| MOP | ក្រសួងផែនការ<br>Ministry of Planning |
| MOWA | ក្រសួងកិច្ចការនារី<br>Ministry of Women's Affairs |
| NACPC | សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត<br>National Association of Capital and Provincial Council |
| NCDD | គណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យ<br>National Committee for Democratic Development |
| NCSD | ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍដោយនិរន្តរភាព<br>National Council for Sustainable Development |
| NC-SNDD | គណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ<br>National Committee for Sub-national Democratic Development |
| NIS | វិទ្យាស្ថានជាតិស្ថិតិ<br>National Institute of Statistics |
| NLC | សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន<br>National League of Local Council |
| NRM | ការគ្រប់គ្រងធនធានធម្មជាតិ |

| | |
|---|---|
| | Natural Resource Management |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ<br>National Strategy Development Program |
| OWSO | ការិយាល័យច្រកចេញចូលតែមួយ<br>One Window Service Office |
| PDAFF | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត<br>Provincial Department of Agriculture, Forestry and Fishery |
| PDEF | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត<br>Provincial Department of Economic and Finance |
| PDEYS | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត<br>Provincial Department of Education, Youth and Sport |
| PDH | មន្ទីរសុខាភិបាលខេត្ត<br>Provincial Department of Health |
| PDOP | មន្ទីរផែនការខេត្ត<br>Provincial Department of Planning |
| PDRD | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត<br>Provincial Department of Rural Development |
| PDWA | មន្ទីរកិច្ចការនារីខេត្ត<br>Provincial Department of Women’s Affairs |
| PDWRM | មន្ទីរធនធានទឹក និងឧត្តុនិយមខេត្ត<br>Provincial Department of Water Resource Management |
| PDP | ផែនការអភិវឌ្ឍន៍ខេត្ត<br>Provincial Development Plan |
| PIP | កម្មវិធីវិនិយោគសាធារណៈ/ ផែនការវិនិយោគខេត្ត<br>Public Investment Program/ Provincial Investment Plan |
| PPA | គម្រោង កម្មវិធី ឬ/និង សកម្មភាព<br>Project, Programme and/or Activity |
| RGC | រាជរដ្ឋាភិបាលកម្ពុជា<br>Royal Government of Cambodia |
| RS | យុទ្ធសាស្ត្រចតុកោណ<br>Rectangular Strategy |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព<br>Sustainable Development Goals |
| SME | សហគ្រាសខ្នាតតូច និងមធ្យម<br>Small and Medium Enterprise |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ<br>Sub-national Administration |
| SNIF | មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ<br>Sub-national Investment Fund<br>សហភាពទីក្រុង និងអភិបាលកិច្ចមូលដ្ឋាន/ អាស៊ីប៉ាស៊ីភិច |

| | |
|---|---|
| UCLG/ASPAC | United Cities and Local Government/ Asia Pacific |
| UN | អង្គការសហប្រជាជាតិ<br>United Nations |
| UNDP | កម្មវិធីអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ<br>United Nations Development Programme |
| UNEP | កម្មវិធីបរិស្ថាន អង្គការសហប្រជាជាតិ<br>United Nations Environmental Programme |
| UN Habitat | កម្មវិធីតាំងទីលំនៅអង្គការសហប្រជាជាតិ<br>United Nations Human Settlements Programme |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ<br>United State Agency for International Development |
| VNR | ការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត<br>Voluntary National Review |
| VSR | ការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត (ដោយសុច្ឆន្ទៈ)<br>Voluntary Sub-national Review |
| WA | សម្ព័ន្ធភាពសត្វព្រៃ<br>Wildlife Alliance |
| WASH | ទឹកស្អាត និងអនាម័យ<br>Water, Sanitation and Hygiene |
| WB | ធនាគារពិភពលោក<br>World Bank |
| WCS | សហគមន៍អភិរក្សសត្វព្រៃ<br>Wildlife Conservation Society |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក<br>World Food Programme |

# គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងអត្ថន័យសង្ខេប

| គោលដៅ | អត្ថន័យសូចនាករសង្ខេប |
|---|---|
| គោលដៅ ១ ៖ គ្មានភាពក្រីក្រ | លុបបំបាត់ភាពក្រីក្រគ្រប់ទម្រង់និងគ្រប់ទីកន្លែង |
| គោលដៅ ២៖ គ្មានគ្រោះអត់ឃ្លាន | លុបបំបាត់ភាពស្រេកឃ្លាន សម្រេចឱ្យបាននូវសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយនិរន្តរភាព |
| គោលដៅ ៣៖ សុខភាព និងសុខុមាលភាពមាំមួន | ធានាឱ្យជីវិតរស់នៅទាំងអស់មានសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពគ្រប់អាយុកាលគ្រប់រូប |
| គោលដៅ៤៖ ការអប់រំប្រកបដោយគុណភាព | ធានាឱ្យមានការអប់រំប្រកបដោយគុណភាពនិងប្រកបដោយបរិយាប័ន្ន និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិត |
| គោលដៅ ៥៖ សមភាពយេនឌ័រ | សម្រេចឱ្យបាននូវសមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី និងកុមារី |
| គោលដៅ ៦៖ ទឹកស្អាត និងអនាម័យ | ធានាឱ្យមាន និងគ្រប់គ្រងទឹកស្អាតនិងអនាម័យប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា |
| គោលដៅ ៧៖ ថាមពលស្អាតដែលមានតម្លៃសមរម្យ | ធានាឱ្យបាននូវការប្រើប្រាស់ថាមពលទំនើប មានតម្លៃសមរម្យ អាចទុកចិត្តបាន និងមាននិរន្តរភាព |
| គោលដៅ ៨៖ ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច | លើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងប្រកបដោយបរិយាប័ន្ន ដែលផ្តល់ការងារពេញលេញ និងបង្កើតឱ្យមាននិយោជិកភាព និងឱកាសការងារសម្រាប់ទាំងអស់គ្នា |
| គោលដៅ ៩៖ ឧស្សាហកម្ម នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ | កសាងហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់ លើកកម្ពស់ឧស្សាហកម្មនីយកម្មប្រកបដោយនិរន្តរភាព និងប្រកបដោយបរិយាប័ន្ន និងជំរុញឱ្យមាននវានុវត្តន៍ |
| គោលដៅ ១០៖ កាត់បន្ថយវិសមភាព | កាត់បន្ថយវិសមភាពផ្ទៃក្នុងប្រទេស និងវិសមភាពរវាងប្រទេសនិងប្រទេស |
| គោលដៅ ១១៖ ទីក្រុង និងសហគមន៍ប្រកបដោយនិរន្តរភាព | ធ្វើឱ្យទីក្រុងនិងការតាំងទីលំនៅរបស់មនុស្សប្រកបដោយបរិយាប័ន្ន មានសុវត្ថិភាព មានភាពធន់ និងមាននិរន្តរភាព |
| គោលដៅ ១២៖ ការប្រើប្រាស់ និងការផលិតប្រកបដោយការទទួលខុសត្រូវ | ធានាឱ្យបាននូវដំណើរការប្រើប្រាស់ និងការផលិតប្រកបដោយនិរន្តរភាព |
| គោលដៅ ១៣៖ សកម្មភាពបរិស្ថាន | ធ្វើសកម្មភាពបឋមបន្ទាន់ ដើម្បីកាត់បន្ថយបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់ពីបម្រែបម្រួលអាកាសធាតុ |
| គោលដៅ ១៤៖ ជីវិតក្រោមទឹក | ធ្វើការអភិរក្ស និងប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានទឹកសមុទ្រ ធនធានមហាសមុទ្រ និងធានធានមច្ឆារ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព |
| គោលដៅ ១៥៖ ជីវិតលើដី | ការពារ បង្កើតឱ្យមានឡើងវិញ និងលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីភពផែនដី ព្រមទាំងគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាពលុបបំបាត់ |

| | |
|---|---|
| | ការកាប់បំផ្លាញព្រៃឈើ និងកាត់បន្ថយឱ្យបានពាក់កណ្តាលនូវការសឹករិចរិលដី និងការបាត់បង់ជីវៈចម្រុះ |
| គោលដៅ ១៦៖ សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ | លើកកម្ពស់សន្តិភាព និងលើកកម្ពស់ការអភិវឌ្ឍសង្គមប្រកបដោយបរិយាប័ន្ន ព្រមទាំងផ្តល់ឱ្យមនុស្សគ្រប់រូបនូវយុត្តិធម៌ និងកសាងស្ថាប័នប្រកបដោយបរិយាប័ន្ន ប្រកបដោយគណនេយ្យភាព និងប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិតទាំងអស់ |
| គោលដៅ ១៧៖ ភាពជាដៃគូដើម្បីសម្រេចគោលដៅ | ពង្រឹងមធ្យោបាយអនុវត្តគោលដៅ និងកសាងភាពជាដៃគូសកល សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព |
| គោលដៅ ១៨៖ កម្ពុជាគ្មានគ្រាប់មីន និងសំណល់មិនទាន់ផ្ទុះពីសង្គ្រាម | បញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានពីគ្រាប់មីននិងសំណល់មិនទាន់ផ្ទុះពីសង្គ្រាម និងលើកកម្ពស់ជំនួយដល់ជនរងគ្រោះ |
| | |

# ផែនទី និងទិន្នន័យគោលប្រទេសកម្ពុជា

## ផែនទីប្រទេសកម្ពុជា

(ស្ថិតិពលរដ្ឋតាមរាជធានី/ខេត្ត)



# ទិន្នន័យគោលប្រទេសកម្ពុជា

| សូចនាករ | ទិន្នន័យគោល |
|---|---|
| **ក. ព័ត៌មានប្រជាសាស្ត្រសង្គម** | |
| ផ្ទៃដីសរុប | 181,035 គ.ម$^{2}$ |
| ប្រជាពលរដ្ឋសរុប (២០២១) | 16.95 លាននាក់ |
| អត្រាភាពក្រីក្រ (២០១៩) | 18% |
| ភាគរយអ្នកចូលរួមកម្លាំងពលកម្ម (អាយុពី ១៥ ដល់ ៥៩ ឆ្នាំ) | 81.7% |
| សរុបស្ត្រី តាមតំបន់ (ស្ត្រី %) | 15,552,211 (51.3%) |
| • តំបន់កណ្ដាល | 7,644,295 (49.7%) |
| • តំបន់ទន្លេសាប | 4,852,964 (31.0%) |
| • តំបន់មាត់សមុទ្រ | 1,072,468 (6.8%) |
| • តំបន់ខ្ពង់រាប | 1,982,484 (12.5%) |
| ការបែងចែកប្រជាសាស្ត្រ តាមភូមិសាស្ត្រ | |
| • *ជនបទ* | 75.1% |
| • *ទីក្រុង* | 24.9% |
| អត្រាកំណើនប្រជាពលរដ្ឋ ប្រចាំឆ្នាំ | 1.4% |
| អាយុកាលរស់ ជាមធ្យមរបស់បុរស និងស្ត្រី (ចាប់ពីថ្ងៃកើត) | 75.5 ឆ្នាំ (ស្ត្រី 76.8 ឆ្នាំ) |
| ដង់ស៊ីតេប្រជាពលរដ្ឋ (ចំនួនមនុស្សក្នុង១គីឡូម៉ែត្រការ៉េ) | 87 នាក់/ គ.ម$^{2}$ |
| ភាគរយប្រជាពលរដ្ឋ តាមក្រុមអាយុ | |
| • អាយុពី *0-14* ឆ្នាំ | 29.4% |
| • អាយុពី *15-59* ឆ្នាំ | 61.7% |
| • អាយុពី/លើសពី *60* ឆ្នាំ | 8.9% |
| ចំនួនប្រជាពលរដ្ឋធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស (ឆ្នាំ ២០១៨) | 1,235,993 នាក់ |
| ចំនួនប្រជាពលរដ្ឋបានទទួលការអប់រំ (អាយុពី/លើស ១៥ឆ្នាំ) | |
| • មិនបានទទួលការអប់រំ (មិនបានចូលរៀននៅសាលា) | 0.06% |
| • មិនបានបញ្ចប់បឋមសិក្សា | 35.1% |
| • បានបញ្ចប់បឋមសិក្សា | 31.1% |
| • បានបញ្ចប់អនុវិទ្យាល័យ | 26.6% |
| • បានបញ្ចប់វិទ្យាល័យ ចំណេះទូទៅ | 2.9% |
| • បានបញ្ចប់ជំនាញបច្ចេកទេស/ជំនាញវិជ្ជាជីវៈ | 0.7% |

| | |
|---|---|
| • កម្រិតបរិញ្ញាប័ត្រ | 2.9% |
| • កម្រិតអនុបណ្ឌិត/បណ្ឌិត | 0.6% |
| • វិញ្ញាបណ្ណបត្របណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ | 0.03% |
| **ខ. សូចនាករសេដ្ឋកិច្ច** | |
| ផលិតផលដុលសរុបក្នុងស្រុក ជាដុល្លារសហរដ្ឋអាមេរិក (ឆ្នាំ២០២១) | 26.96 ប៊ីលាន |
| ចំណូលសរុបក្នុងម្នាក់ៗ ជាដុល្លារសហរដ្ឋអាមេរិក (ឆ្នាំ២០២១) | 1,404 ដុល្លារ |
| អត្រាគ្មានការងារ (ឆ្នាំ ២០២១) | 0.6% |
| អត្រាកំណើនផលិតផលដុលសរុបក្នុងស្រុក (ឆ្នាំ ២០២២) | 4.8% |
| ការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី អំពី ផលិតផលដុលសរុបក្នុងស្រុក ឆ្នាំ ២០២៣ | 5.5% |
| សរសរស្ដំសេដ្ឋកិច្ច (កម្មន្តសាល ទេសចរណ៍ កសិកម្ម និងសំណង់) | |
| នីហរណកម្ម ឆ្នាំ 2017 (អាមេរិក: 21%; សឹង្ហបុរី: 8%; ថៃ: 8%; អាល្លឺម៉ង់: 7%; ជប៉ុន: 6%; ចិន: 5%; កាណាដា: 5%; អង់គ្លេស: 5%) | $11.42 ប៊ីលាន |
| អាហរណកម្ម ឆ្នាំ 2017 (ចិន: 27%; ថៃ: 25%; វៀតណាម: 15%; សឹង្ហបុរី: 10%) | $14.37 ប៊ីលាន |
| បំណុលសាធារណៈ (ឆ្នាំ ២០១៧) | 30.4% នៃផលិតផលដុលសរុបក្នុងស្រុក |
| អតិផរណាជាមធ្យម (ប្រចាំឆ្នាំ) | 2.8% |
| ទុនវិនិយោគបរទេស (ឆ្នាំ ២០២១) | 5,119 លានដុល្លារសហរដ្ឋ |
| ក្រុមប្រទេសមានចំណូល | មធ្យមកម្រិតទាប |

Sources: General Population Census of Cambodia 2019 and Cambodia Socio-Economic Survey for 2019
OECD-WOFI (sng-wofi.org)
https://data.worldbank.org/country/cambodia?view=chart
https://en.wikipedia.org/wiki/Economy_of_Cambodia

# របកគំហើញសង្ខេប

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្ត SDGs ។ កញ្ចប់នៃយុទ្ធសាស្ត្រ គោលនយោបាយ បទប្បញ្ញត្តិ និងបទដ្ឋានដ៏សម្បូរបែបត្រូវបានបង្កើត ផ្សព្វផ្សាយ និងប្រកាសដាក់ឱ្យប្រើប្រាស់។ នៅក្នុងការអនុវត្តច្បាប់ កម្ពុជាបានធ្វើកំណែទម្រង់ខ្លួនឯងពីអភិបាលកិច្ចមជ្ឈិមដែលធ្លាប់មានពីយូរលង់មកបែបប្រពៃណីឱ្យទៅជាអភិបាលកិច្ចបែបវិមជ្ឈការ និងវិសហមជ្ឈការ ដែលជាការជំរុញការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត និងបន្ថែមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជាទី១៨។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជាទីដប់ប្រាំបី គឺ អំពីការបញ្ចប់ផលប៉ះពាល់អវិជ្ជមាននៃមីន និងសំណល់មិនទាន់ផ្ទុះសល់ពីសង្គ្រាម/ERW។

ក្រោមកំណែទម្រង់ដ៏មានអត្ថន័យខាងលើ ធនធានជាច្រើន (មនុស្ស សម្ភារៈ ហិរញ្ញវត្ថុ) ត្រូវបានបែងចែកទៅថ្នាក់ក្រោមជាតិ គឺ ថ្នាក់រាជធានី ខេត្ត ស្រុក ក្រុង ខណ្ឌ និងថ្នាក់ឃុំ/សង្កាត់។ រវាងឆ្នាំ ២០១០ ដល់ឆ្នាំ ២០២០ ថវិកាជាតិជាង ១៤.៦៤៣ ពាន់លានរៀលត្រូវបានបែងចែកទៅថ្នាក់ក្រោមជាតិ ។ ដោយឡែក មូលនិធិឃុំ សង្កាត់ និងមូលនិធិ ក្រុង ស្រុក ខណ្ឌ មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

ដោយផ្អែកលើមូលដ្ឋានទិន្នន័យរបស់ធនាគារពិភពលោក សូចនាករចំនួន៦៣ ក្នុងចំណោមសូចនាករចំនួន៧១ ដែលបានវាស់វែងលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទាំង១៧ ត្រូវបានបញ្ជាក់ថាមានដំណើរការលូតលាស់ជាវិជ្ជមាន។ ខណៈពេលដែលសូចនាករចំនួន៨ទៀតមិនមានទិន្នន័យដែលអាចផ្ទៀងផ្ទាត់បាន។

យោងតាមតារាងទី៦ និងរូបភាពទី១៤ ខាងក្រោម រដ្ឋបាលថ្នាក់ក្រោមជាតិ(SNA) ផ្តល់អាទិភាពដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពចំនួនប្រាំបីក្នុងចំណោមប្រាំបួន។ នៅក្នុងអាទិភាពជាលំដាប់ រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្ត SDG#1: គ្មានភាពក្រីក្រ SDG#4: ការអប់រំប្រកបដោយគុណភាព SDG#3: សុខភាពល្អ និងសុខុមាលភាព SDG#6: ទឹកស្អាត និងអនាម័យ SDG#8: ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច SDG#9: ឧស្សាហកម្ម ការច្នៃប្រឌិត និងហេដ្ឋារចនាសម្ព័ន្ធ SDG#5: សមភាពយេនឌ័រ និងSDG#7: តម្លៃសមរម្យ និងថាមពលស្អាត។ អ្នកឆ្លើយសំណួរក៏បានទទួលស្គាល់ពីវឌ្ឍនភាពនៃ SDG#11: ទីក្រុង និងសហគមន៍ប្រកបដោយនិរន្តរភាព ជាពិសេសនៅក្នុង CP/MDK ដែលទទួលបានអត្ថប្រយោជន៍ពីការគាំទ្រផ្នែកហិរញ្ញវត្ថុ និង/ឬបច្ចេកទេសពីរដ្ឋាភិបាលជាតិ និងពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល (ក្រុម A៖ គំនិតផ្តួចផ្តើមធ្វើឡើងដោយ CP/MDK ក្រោមជំនួយផ្នែកហិរញ្ញវត្ថុ និង/ឬបច្ចេកទេសពីរដ្ឋាភិបាលជាតិ និងក្រុម B៖ គំនិតផ្តួចផ្តើមធ្វើឡើងដោយ CP/MDK ក្រោមជំនួយហិរញ្ញវត្ថុ និង/ឬបច្ចេកទេសពី DP/DA ឬ NGOs ។ សូមមើលតារាងទី៦ ផ្នែកទី៤.៣)។ ក្នុងការប្រៀបធៀបរវាងការកំណត់អាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថានភាពជាក់ស្តែងលើមូលដ្ឋាន សហគមន៍មូលដ្ឋានក្នុងប្រទេសកម្ពុជា រដ្ឋបាលថ្នាក់ក្រោមជាតិកំពុងព្យាយាមបំពេញតម្រូវការជាមូលដ្ឋានរបស់សាធារណជនក្នុងមូលដ្ឋានរបស់គេ ដោយអនុវត្តជាពិសេស SDG#1, SDG#3, SDG#4, SDG#6 និង SDG#8។

ការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត(VSR) លើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) ត្រូវបានរៀបចំឡើងដោយសហការជាមួយភាគីពាក់ព័ន្ធនានា រួមមានតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ មេដឹកនាំសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ រដ្ឋបាលថ្នាក់ក្រោមជាតិបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើមូលដ្ឋានីយកម្មនៃCSDGs ដោយអនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានគេមើលឃើញថាវិធីសាស្ត្រទូទៅ។ ទោះជាយ៉ាងណាក៏ដោយ កង្វះថវិកានៅថ្នាក់ក្រោមជាតិនៅតែជាបញ្ហាប្រឈមដ៏សំខាន់ក្នុងការជំរុញរបៀបវារៈនៃការអភិវឌ្ឍន៍ តែទន្ទឹមនឹងនេះ ថវិកាដែលបានបែងចែកសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងពន្ធក្នុងស្រុកត្រូវបានកើនឡើង។

ជាសេចក្តីសំយោគ គឺថា រដ្ឋបាលថ្នាក់ក្រោមជាតិដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តCSDGs បំពេញបន្ថែមកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលជាតិ។

ការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត(VSR) បានជួយលើកកម្ពស់ការយល់ដឹងអំពីទំនួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើមូលដ្ឋានីយកម្មCSDGs។ តួអង្គជាច្រើនបានបង្ហាញពីតម្រូវការសម្រាប់ការបណ្តុះបណ្តាល ជំនួយបច្ចេកទេស ការផ្តល់យោបល់ និងការត្រួតពិនិត្យលើការបកស្រាយ និងការធ្វើមូលដ្ឋានីយកម្មCSDGs ដែលអាចឱ្យពួកគេបន្សុីគ្នាបានរវាងផែនការអភិវឌ្ឍន៍ក្នុងមូលដ្ឋានរបស់គេ និងCSDGs ។ លើសពីនេះ ពួកគេបានបង្ហាញពីតម្រូវការសម្រាប់ទិន្នន័យ និងព័ត៌មានជាមូលដ្ឋាន ដើម្បីកែលម្អផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគេ ស្របតាមCSDGs ។ រដ្ឋបាលថ្នាក់ក្រោមជាតិគួរតែត្រូវបានលើកទឹកចិត្តឱ្យបញ្ជ្រាបការប្រើប្រាស់CSDGs ជាឯកសារយោងសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ រួមទាំងមន្ទីរពាក់ព័ន្ធផងដែរ។ ការប្រើប្រាស់ ឧបករណ៍ការពារសង្គម និងបរិស្ថាន (Safeguard) នៅគ្រប់គម្រោងនៅថ្នាក់ក្រោមជាតិ គួរតែត្រូវបានពង្រឹង ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមាននៃគម្រោង និងរួមចំណែកដល់គោលដៅរួមនៃSDGs ក្នុងការធានាឱ្យមានអនាគតរួមប្រកបដោយសមធម៌ វិបុលភាព និងនិរន្តរភាព។

# ជំពូក ១ ៖ សេចក្តីផ្តើមទូទៅ

ប្រទេសកម្ពុជាមានប្រព័ន្ធរដ្ឋាភិបាលថ្នាក់ក្រោមជាតិបីជាន់។ រចនាសម្ព័ន្ធនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានទទួលស្គាល់ជាផ្លូវការនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ (កែសម្រួលក្នុងឆ្នាំ ២០០៨) នៅក្នុងជំពូកទី XIII ។ នៅកម្រិតខ្ពស់បំផុតគឺ (i) ខេត្ត និងរាជធានី (ii) កម្រិតមធ្យម និងទាបគឺស្រុក ក្រុង ខណ្ឌ និង (iii) ឃុំ និងសង្កាត់ (សូមមើលរូបភាពទី១) ។ ច្បាប់រៀបចំឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បង្កើតមុខងារ និងកំណត់បទប្បញ្ញត្តិហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់។

ខេត្តនីមួយៗមានអភិបាលខេត្តមួយរូប និងអភិបាលរង១០រូប អភិបាលក្រុង១រូប និងអភិបាលរង៦រូប សម្រាប់ក្រុង/ស្រុក/ខណ្ឌនីមួយៗ។ អភិបាលខេត្ត និងអភិបាលក្រុងត្រូវបានចាត់ទុកជាស្ថាប័នប្រតិបត្តិ ចំណែកក្រុមប្រឹក្សារាជធានី/ខេត្ត ក្រុង ស្រុក ខណ្ឌ (MDK) និងក្រុមប្រឹក្សាឃុំ-សង្កាត់(គ/ស) គឺជា ស្ថាប័ននីតិប្បញ្ញត្តិ។ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់អាណត្តិអភិបាលខេត្ត អភិបាលរង និងអភិបាលក្រុង ស្រុក/ខណ្ឌ ឱ្យកាន់មុខតំណែងមិនលើសពី ២អាណត្តិជាប់គ្នា(៨ឆ្នាំ) ក្នុងទឹកដីតែមួយ។ មកដល់ពេលនេះ ប្រទេសកម្ពុជាមានរាជធានីមួយ មានខេត្ត២៤ ក្រុង១៤ ខណ្ឌ៣១ ស្រុក១៦៣ សង្កាត់២៦៧ និងមានឃុំចំនួន១.៣៨៥ ។




រូបភាពទី១ ៖ រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្អែកលើ គ.ជ.អ.ប. រដ្ឋបាល និងទីភ្នាក់ងារមូលដ្ឋានមានទំនួលខុសត្រូវខ្ពស់ចំពោះរាជរដ្ឋាភិបាលកម្ពុជា(RGC) សម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរសិទ្ធិ។ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន(DoLA) ត្រួតពិនិត្យស្រុក ក្រុង និងខណ្ឌ ខណៈដែលខេត្ត និងរាជធានីស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន(GDoLA) និងលេខាធិការដ្ឋានសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ដើរតួជាឆ័ត្រសម្រាប់កិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ និងធ្វើឱ្យភ្នាក់ងារថ្នាក់ជាតិធ្វើការកាន់តែមានប្រសិទ្ធភាពក្នុងកម្រិតរដ្ឋបាលនីមួយៗ។ នៅឆ្នាំ២០២០ កម្ពុជាបានបញ្ចប់ដំណាក់កាលទីមួយនៃកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិឆ្នាំ ២០១០-២០១៩ ដែលដឹកនាំដោយ គ.ជ.អ.ប។

នៅកម្ពុជា មានការបោះឆ្នោតចំនួនពីរក្នុងរយៈពេលប្រាំឆ្នាំម្តង ដូចជាការបោះឆ្នោតឃុំ សង្កាត់ (ធ្វើឡើងក្នុងឆ្នាំ២០០២, ២០០៧, ២០១២, ២០១៧ និងឆ្នាំ២០២២) និងការបោះឆ្នោតសកល(ធ្វើឡើងនៅឆ្នាំ១៩៩៣, ១៩៩៨, ២០០៣, ២០០៨, ២០១៨ និងនៅខែកក្កដា ឆ្នាំ២០២៣)។ នេះមានន័យថា រាជរដ្ឋាភិបាលត្រូវបានបោះឆ្នោតជ្រើសតាំងជារៀងរាល់៥ឆ្នាំម្តងតាមរយៈការបោះឆ្នោតទូទៅ ចំណែកអភិបាលរាជធានី/ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបានតែងតាំងដោយគណបក្សកាន់អំណាចដែលដឹកនាំដោយរដ្ឋាភិបាល។ ក្រុមប្រឹក្សារាជធានី-ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ចំណែកប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតឃុំ-សង្កាត់រៀងរាល់៥ឆ្នាំម្តង។

ចាប់តាំងពីឆ្នាំ១៩៩៦មក រាជរដ្ឋាភិបាលកម្ពុជា(RGC) បានដាក់ចេញនូវកំណែទម្រង់សំខាន់ៗជាច្រើន ដើម្បីធ្វើឱ្យស៊ីជម្រៅ និងពង្រឹងវិមជ្ឈការ និងវិសហមជ្ឈការ(D&D) នៅកម្ពុជា ដើម្បីធ្វើប្រតិភូកម្ម(ផ្ទេរភារកិច្ច និងធនធាន) ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាឧទាហរណ៍ ប្រទេសកម្ពុជាបានអនុម័តច្បាប់សំខាន់ៗមួយចំនួន រួមមាន ច្បាប់ឃុំ សង្កាត់(ឆ្នាំ២០០១) ច្បាប់អង្គការស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ(២០០៨) និងច្បាប់ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ(២០១១)។

ជាលទ្ធផលនៃកំណែទម្រង់របស់រាជរដ្ឋាភិបាលជាច្រើនឆ្នាំមក រដ្ឋបាលថ្នាក់ក្រោមជាតិបាននឹងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចចិត្តសំខាន់ៗសម្រាប់ការអភិវឌ្ឍនិងការវិនិយោគក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព(SDGs) គឺ ទាក់ទងដោយផ្ទាល់ និងដោយប្រយោលទៅនឹងទំនួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ ដោយសារតែរដ្ឋបាលថ្នាក់ក្រោមជាតិមានទំនួលខុសត្រូវលើសេវាកម្មដ៏ធំទូលាយដែលជាប់ពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ជាពិសេសសេវាទាក់ទងនឹងវិស័យទឹកស្អាត អនាម័យ ការអប់រំបឋម សេវាសុខភាពសហគមន៍ គមនាគមន៍ក្នុងមូលដ្ឋាន សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ល។ សេវាកម្មទាំងអស់នេះ មានឥទ្ធិពលលើការលើកកម្ពស់សិទ្ធិទទួលបានសេវាសាធារណៈដោយសមធម៌ ជាពិសេសសម្រាប់ស្ត្រី និងកុមារី។ តាមពិតទៅ រដ្ឋាភិបាលជាតិនឹងមិនអាចផ្តល់ការប្តេជ្ញាចិត្តទាំងអស់ដើម្បីសម្រេចបាន SDGs នៅឆ្នាំ ២០៣០ ដោយគ្មាន

ការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ(SNAs)បានទេ ហើយលទ្ធផលបានមកពីការអនុវត្ត SDGs ពីរដ្ឋាភិបាលជាតិអាចថាបានពាក់កណ្តាលនៃរូបភាពរួមប៉ុណ្ណោះ។ ដូច្នេះ វាជាការចាំបាច់ដែលត្រូវទទួលស្គាល់កិច្ចខិតខំប្រឹងប្រែង និងការអនុវត្តប្រកបដោយភាពច្នៃប្រឌិតដ៏សម្បើមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសម្រេចបាន និងធ្វើមូលដ្ឋានីយកម្មSDGs ជាមួយនឹងធនធានមានកំណត់របស់ពួកគេ។

ដូចដែលបានបញ្ជាក់ខាងលើ រដ្ឋបាលថ្នាក់ក្រោមជាតិអាចជាចំណុចស្នូលនៃរបៀបវារៈឆ្នាំ ២០៣០ (Global Task Force, 2016)។

ការត្រួតពិនិត្យដោយស្ម័គ្រចិត្តថ្នាក់ក្រោមជាតិលើការធ្វើមូលដ្ឋានីយកម្មSDG និងការរៀបចំរបាយការណ៍ដែលដឹកនាំដោយរដ្ឋាភិបាលក្នុងតំបន់ និងដៃគូរបស់គេរៀងៗខ្លួននោះ បានបង្ហាញពីភាពចាំបាច់។ វានាំមកនូវកត្តាលីករនៃការផ្លាស់ប្តូរ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការពហុភាគីពាក់ព័ន្ធ និងកិច្ចសហប្រតិបត្តិការអភិបាលកិច្ចពហុកម្រិតកាន់តែរឹងមាំ ការអនុវត្តគោលនយោបាយពាក់ព័ន្ធដែលនាំឱ្យមានផ្លាស់ប្តូរ តម្លាភាព និងគណនេយ្យភាព(UCLG, ២០២១)។

ការរៀបចំត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត(VSR)នៅកម្ពុជា ធ្វើឡើងដោយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន សហការជាមួយអគ្គលេខាធិការដ្ឋានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ដែលជាសមាគមយ៉ាងសកម្មនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា។ ក្នុងន័យនេះ គេក៏មិនភ្លេចនិយាយទេថា សម្ព័ន្ធភាពជាតិនៃក្រុមប្រឹក្សាមូលដ្ឋាន(NLC) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៣ ជាស្ថាប័នសំខាន់មួយតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ។ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន មានបេសកកម្មធ្វើការតស៊ូមតិដើម្បីផលប្រយោជន៍និងចំណាប់អារម្មណ៍របស់ក្រុមប្រឹក្សាមូលដ្ឋាននៅថ្នាក់ជាតិ ផ្តល់សេវាកម្ម និងការបណ្តុះបណ្តាល និងជំរុញកិច្ចសហប្រតិបត្តិការក្នុងចំណោមឃុំ សង្កាត់។ នៅឆ្នាំ២០១៤ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន បានពង្រីក និងរួមបញ្ចូលក្រុមប្រឹក្សា ក្រុង ស្រុក និងខណ្ឌ។ ទន្ទឹមនឹងនេះ សមាគមជាតិក្រុមប្រឹក្សារាជធានី និងខេត្ត(NACPC) ត្រូវបានបង្កើតឡើង និងចុះបញ្ជីនៅក្រសួងមហាផ្ទៃ (MOI) ក្នុងឆ្នាំ២០១៣។ សមាគមជាតិនេះ មានសមាសភាពក្រុមប្រឹក្សាខេត្តចំនួន២៤ និងរាជធានីភ្នំពេញ។ សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត មានគោលបំណង៖ ១) លើកកម្ពស់ឋានៈ និងកសាងសមត្ថភាពក្រុមប្រឹក្សារាជធានី ខេត្ត។ ២) ការពារផលប្រយោជន៍ និងភាពស្របច្បាប់របស់សមាជិកសមាគម; ៣) កសាងភាពជាដៃគូជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអភិវឌ្ឍមូលដ្ឋាន ពង្រឹងនីតិរដ្ឋ និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ទាំងសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន(NLC) និងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត(NACPC) មានលេខាធិការដ្ឋានរួមមួយហៅថា អគ្គលេខាធិការដ្ឋានASAC ដែលមានទីតាំងនៅក្នុងបរិវេណព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូក ២ ៖ វិធីសាស្ត្រនៃការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត

របាយការណ៍នេះត្រូវបានរៀបចំឡើងតាមសៀវភៅណែនាំVNR របស់អង្គការសហប្រជាជាតិ និងគោលការណ៍ណែនាំរបស់ UCLG សម្រាប់ការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត(VSRs) ជាមួយនឹងផែនទីបង្ហាញផ្លូវរបស់(VSR)។ បច្ចេកទេសប្រមូលទិន្នន័យជាច្រើនត្រូវបានប្រើប្រាស់ដើម្បីប្រមូលព័ត៌មានសំខាន់ៗ ពាក់ព័ន្ធទាក់ទងនឹងការធ្វើមូលដ្ឋានីយកម្ម រួមមាន បទពិសោធន៍ បញ្ហាប្រឈម និងវឌ្ឍនភាព នៅក្នុងបរិបទនៃប្រទេសកម្ពុជា។ ទាំងនោះរួមមានការពិនិត្យឯកសារពាក់ព័ន្ធ ការស្ទង់មតិ ការសម្ភាសន៍ស៊ីជម្រៅ និងការសង្កេតផ្ទាល់នៅតាមសហគមន៍មូលដ្ឋាន (មើលរូបភាពទី២)។




**រូបភាពទី២ ៖ កិច្ចដំណើរការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត**

## កាលវិភាគនៃការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត

| ចាប់ផ្តើម | ប្រមូលព័ត៌មាន | | | របាយការណ៍ការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត | | | ការធ្វើឱសាន្តវាទីរបាយការណ៍ | | |
|---|---|---|---|---|---|---|---|---|---|
| | ពិនិត្យឯកសារ | សិក្សាស្ទង់មតិ | ករណីសិក្សា | រៀបចំទម្រង់ | របាយការណ៍បឋម | សេចក្តីព្រាងចុងក្រោយ | សិក្ខាសាលាផ្ទៀងផ្ទាត់ | របាយការណ៍ចុងក្រោយ | បោះពុម្ពផ្សព្វផ្សាយ |
| ខែធ្នូ ២០២២ | ខែមករា - ខែកុម្ភៈ | ខែធ្នូ - ខែមករា | ខែមករា - ខែមិនា | ខែកុម្ភៈ | ខែមិនា | ខែមេសា | ថ្ងៃទី២៥ ខែមេសា | ពាក់កណ្តាល ខែឧសភា | ចុង ខែឧសភា |

**ការពិនិត្យលើឯកសារពាក់ព័ន្ធ៖** រួមទាំងឯកសារក្របខ័ណ្ឌ ផែនការអភិវឌ្ឍន៍ជាតិ(ដូចជាគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍) ដោយឆ្លុះបញ្ចាំងពីការធ្វើមូលដ្ឋានីយកម្ម និងការធ្វើសមាហរណកម្មSDGs ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ និងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា ឆ្នាំ២០១៦-២០៣០។ល។ ទន្ទឹមនឹងនេះ របាយការណ៍សិក្សាស្រាវជ្រាវជាច្រើន និងរបាយការណ៍ទាក់ទងនឹងបទពិសោធន៍ធ្វើមូលដ្ឋានីយកម្មនៃSDGs នៅកម្ពុជា ដោយអ្នកសិក្សាជំនាញៗ ទីភ្នាក់ងាររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ក៏ត្រូវបានពិនិត្យផងដែរ។ ទាំងនេះបានជួយការយល់ដឹង អំពី បរិបទ ស្ថាប័ននៃរដ្ឋាភិបាលជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងប្រទេសកម្ពុជា ទាក់ទងនឹងតួនាទីរបស់ពួកគេ និងការគាំទ្រចាំបាច់សម្រាប់ការធ្វើមូលដ្ឋានីយកម្មនៃSDGs ក៏ដូចជានិន្នាការនៃការធ្វើវិមជ្ឈការអំណាច និងការទទួលខុសត្រូវរួមគ្នារវាងរដ្ឋបាលមូលដ្ឋាន និងថ្នាក់ជាតិ។ ក្នុងន័យនេះ ការពិនិត្យលើឯកសារពាក់ព័ន្ធនេះ បានពិនិត្យយ៉ាងស៊ីជម្រៅលើមូលដ្ឋានទិន្នន័យតាមដានCSDG យ៉ាងហ្មត់ចត់ ហើយបានរកឃើញថាសូចនាករចំនួន៦៣ ក្នុងចំណោមសូចនាករចំនួន៧១ ដែលវាស់វែងលើSDGs ទាំង១៧ ត្រូវបានបញ្ជាក់ថាមានការវិវឌ្ឍវិជ្ជមាន។ ខណៈពេលដែលសូចនាករចំនួន៨ មិនមានទិន្នន័យដែលអាចផ្ទៀងផ្ទាត់បាន (សូមមើលឧបសម្ព័ន្ធ D)

**ការស្ទង់មតិ៖** ការស្ទង់មតិត្រូវបានធ្វើឡើងដោយបានកំណត់គោលដៅពីរកម្រិតនៃរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិនៅទូទាំងប្រទេសគឺ រាជធានី-ខេត្ត(CP) និងក្រុង/ស្រុក/ខណ្ឌ(MDK) (សូមមើលរូបភាពទី១ នៅក្នុងសេចក្តីផ្តើម)។ ការស្ទង់មតិយកសំណាកសរុបចំនួន១៧២ ក្នុងចំណោម២០៤ ដោយជ្រើសរើសបែបចៃដន្យ(សូមមើលតារាងទី១)។ ៤១% នៃអ្នកផ្តល់ចម្លើយសរុប បានបំពេញបញ្ចប់កម្រងសំណួរ ហើយផ្ញើត្រឡប់មកវិញ។ កម្រងសំណួរត្រូវបានបកប្រែជាភាសាខ្មែរ និងបានបោះពុម្ពចេញ រួចបានចែកជូនតំណាងរដ្ឋបាលខេត្ត រាជធានី ក្រុង ស្រុក ខណ្ឌ ដោយមានលិខិតផ្លូវការចុះហត្ថលេខាដោយប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។ ការចែកចាយកម្រងសំណួរនេះត្រូវបានសម្របសម្រួល និងគាំទ្រដោយក្រុមការងាររបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

បន្ទាប់ពីការពិនិត្យ ពិចារណាយ៉ាងហ្មត់ចត់ជាមួយបុគ្គលសំខាន់ៗ ដៃគូការងារ និងអ្នកពាក់ព័ន្ធ ការស្ទង់មតិនេះ បានសន្មត់កំណត់យកគោលដៅ(CSDGs) អាទិភាពចំនួនប្រាំបី គឺ គោលដៅ១ គោលដៅ៣ គោលដៅ៥ គោលដៅ៦ គោលដៅ៧ គោលដៅ១០ គោលដៅ១១ និងគោលដៅ១៣។ ការផ្តល់

អាទិភាពទាំងនេះបានអនុញ្ញាតឱ្យរបាយការណ៍នេះចូលជ្រៅជាលក្ខណៈទូលំទូលាយ អំពី បទពិសោធន៍នៃដំណើរការធ្វើមូលដ្ឋានីយកម្ម និងវឌ្ឍនភាពនៃSDGs នៅកម្រិតថ្នាក់ក្រោមជាតិ រួមទាំងករណីសិក្សាបញ្ហាប្រឈម និងជំនួយចាំបាច់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវការដើម្បីសម្រេចបាននូវSDGs ជាក់លាក់នៅក្នុងបរិបទនៃប្រទេសកម្ពុជា។

**តារាងទី១៖ ការជ្រើសរើសសំណាក តាមតំបន់**

| តំបន់ | រាជធានី/ខេត្ត | សរុប រាជធានី ខេត្ត +ក្រុង ស្រុក ខណ្ឌ | ចំនួន សំណាក | ចំនួន អ្នកឆ្លើយ | ភាគរយ អ្នកឆ្លើយ |
|---|---|---|---|---|---|
| ទំនាបកណ្ដាល (៧) | (1) កំពង់ចាម | ១+១១ | ៩ | ៤ | ៤៤% |
| | (2) ត្បូងឃ្មុំ | ១+៧ | ៦ | ១ | ១៧% |
| | (3) កណ្ដាល | ១+១១ | ៩ | ១ | ១១% |
| | (4) ភ្នំពេញ | ១+១៤ | ១១ | ៣ | ២៧% |
| | (5) ព្រៃវែង | ១+១៣ | ១០ | 0 | 0% |
| | (6) ស្វាយរៀង | ១+៨ | ៧ | ១ | ១៤% |
| | (7) តាកែវ | ១+១០ | ៨ | ១ | ១៣% |
| ទន្លេសាប (៨) | (8) បន្ទាយមានជ័យ | ១+១០ | ៨ | ១ | ១៣% |
| | (9) បាត់ដំបង | ១+១៤ | ១១ | ៩ | ៨២% |
| | (10) កំពង់ឆ្នាំង | ១+៨ | ៧ | ១ | ១៤% |
| | (11) កំពង់ធំ | ១+៩ | ៧ | ៧ | ១០០% |
| | (12) ពោធិសាត់ | ១+៧ | ៦ | ២ | ៣៣% |
| | (13) សៀមរាប | ១+១២ | ៩ | ២ | ២២% |
| | (14) ឧត្ដរមានជ័យ | ១+៥ | ៥ | 0 | 0% |
| | (15) ប៉ៃលិន | ១+២ | ៣ | ២ | ៦៧% |
| ឆ្នេរសមុទ្រ (៤) | (16) កំពត | ១+៨ | ៧ | ៧ | ១០០% |
| | (17) កោះកុង | ១+៧ | ៦ | ៤ | ៦៧% |
| | (18) ព្រះសីហនុ | ១+៤ | ៤ | ៣ | ៧៥% |
| | (19) កែប | ១+២ | ៣ | 0 | 0% |
| ខ្ពង់រាប (៦) | (20) កំពង់ស្ពឺ | ១+៨ | ៧ | 0 | 0% |
| | (21) ក្រចេះ | ១+៦ | ៥ | ៤ | ៨០% |
| | (22) មណ្ឌលគីរី | ១+៥ | ៥ | ៣ | ៦០% |
| | (23) ព្រះវិហារ | ១+៨ | ៧ | 0 | 0% |
| | (24) រតនគីរី | ១+៩ | ៧ | ១ | ១៤% |
| | (25) ស្ទឹងត្រែង | ១+៦ | ៥ | 0 | 0% |
| សរុប | ២៥ | ២០៤ | ១៤៧ | ៦០ | ៤១% |

**ការសម្ភាសន៍ស៊ីជម្រៅ៖** ធ្វើឡើងជាមួយអ្នកតំណាងមកពីស្ថាប័នរដ្ឋាភិបាលជាតិ និងថ្នាក់ក្រោមជាតិ ដូចជា MOP/NIS, MOI, NCSD, MOWA, CARD/CM និងដៃគូអភិវឌ្ឍន៍សក្តានុពលមួយចំនួន និង/ឬទីភ្នាក់ងារផ្តល់ជំនួយនៅកម្ពុជា រួមមាន UNDP, UN-Habitat, GIZ-MUSEFO ។ ការពិភាក្សាបានផ្តោតលើការគាំទ្រក្នុងស្រុក និងថ្នាក់ជាតិ គោលនយោបាយ យុទ្ធសាស្ត្រ ឧបករណ៍ត្រួតពិនិត្យ និងមូលដ្ឋានទិន្នន័យ រួមទាំងការអនុវត្តល្អ និងករណីសិក្សា ដើម្បីវាស់វែងដំណើរការ និងវឌ្ឍនភាពក្នុងការអនុវត្ត SDGs នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការទំនាក់ទំនងតាមទូរស័ព្ទ តាមអ៊ីនធឺណែតត្រូវបានប្រើប្រាស់សម្រាប់ការសម្ភាសន៍។ បញ្ជីរាយនាមអ្នកផ្តល់ព័ត៌មានសំខាន់ៗសម្រាប់ការសម្ភាសន៍ស៊ីជម្រៅ គឺ មាននៅក្នុងឧបសម្ព័ន្ធA។

**ការរៀបចំ និងផ្សព្វផ្សាយរបាយការណ៍៖** តាំងពីដើមទីរហូតដល់ទីបញ្ចប់នៃដំណើរការសរសេររបាយការណ៍នេះ តំណាងមកពីរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍/ទីភ្នាក់ងារផ្តល់ជំនួយ និងអង្គការសង្គមស៊ីវិលបានចូលរួមដោយផ្ទាល់ និងដោយប្រយោល តាមរយៈមធ្យោបាយផ្សេងៗ ទាំងការស្ទង់មតិ ការសម្ភាសន៍ស៊ីជម្រៅ និងសិក្ខាសាលាផ្ទៀងផ្ទាត់។ ការងារទាំងនេះ បានធានាឱ្យមានការចូលរួមប្រកបដោយអត្ថន័យ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៅក្នុងVSR។ ខេត្តនីមួយៗ និងក្រុង ស្រុក ខណ្ឌមួយចំនួនត្រូវបានលើកទឹកចិត្តឱ្យមានការប្រជុំជាក្រុមជាមួយភាគីពាក់ព័ន្ធក្នុងមូលដ្ឋាន រួមទាំងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងតំបន់របស់ពួកគេ ដើម្បីចូលរួមចំណែកផ្តល់យោបល់ និងឆ្លើយសំណួរ។

**សិក្ខាសាលាផ្ទៀងផ្ទាត់៖** សិក្ខាសាលាផ្ទៀងផ្ទាត់ត្រូវបានរៀបចំឡើងនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ (ព្រឹក) នៅភោជនីយដ្ឋានបាយ័ន រាជធានីភ្នំពេញ ប្រទេសកម្ពុជា។ សិក្ខាសាលនេះត្រូវបានដឹកនាំដោយបុគ្គលសំខាន់ៗចំនួន៤រូប តំណាងឱ្យ MOI, MOP, MOWA និងPALC ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សយ កុសល** ប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន(NLC)។ សិក្ខាសាលានេះ មានការចូលរួមយ៉ាងពេញលេញដោយបុគ្គលសំខាន់ៗចំនួន៤៧រូប មកពី NLC, PALC, MOI, MOP, MOWA, API, UNDP និងក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទនៃទីស្តីការគណៈរដ្ឋមន្ត្រី។
ព្រឹត្តិការណ៍នេះបានដំណើរការទៅដោយឆ្លងកាត់ប្រធានបទចំនួន៤ គឺ (១) សេចក្តីផ្តើម និងសុន្ទរកថាបើកដោយឯកឧត្តម សយ កុសល។ (២) បទបង្ហាញនៃវិធីសាស្ត្រVSR ដែលបានអនុវត្ត ការរកឃើញការវិភាគសំខាន់ៗ និងអនុសាសន៍។ (៣) ការពិភាក្សាបើកចំហ និងការប្រមូលផ្តុំធាតុចូលពីអ្នកចូលរួមដើម្បីធ្វើសុពលភាពរបាយការណ៍VSR។ និង(៤) សុន្ទរកថាសង្ខេប និងបិទដោយឯកឧត្តម សយ កុសល។
នៅក្នុងសុន្ទរកថាបិទ ឯកឧត្តម សយ កុសល បានសង្កត់ធ្ងន់ថា សិក្ខាសាលានេះពិតជាបានសម្រេចគោលបំណងរបស់ខ្លួនយ៉ាងពិតប្រាកដមែន ព្រោះអ្នកចូលរួមបានជ្រួតជ្រាបអំពីការងារនិងលទ្ធផល SVR ធាតុចូលរបស់អ្នកចូលរួមត្រូវបានប្រមូលផ្តុំ ហើយលទ្ធផលSVR ត្រូវបានផ្ទៀងផ្ទាត់។ សូមមើលឧបសម្ព័ន្ធ E: កំណត់ចំណាំពីសិក្ខាសាលា។

  

ក្រៅពីវិធីសាស្ត្រដូចបានរៀបរាប់ខាងលើ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងអ្នកប្រឹក្សាVSR បានទំនាក់ទំនងជាមួយលេខាធិការដ្ឋាន UCLG តាមរយៈអ៊ីមែល និងសន្និសិទវីដេអូ ដើម្បីប្រមូលមតិយោបល់ ដើម្បីទទួលបានដំបូន្មាន និងធានាឱ្យបានថា របាយការណ៍VSRនេះបានបំពេញតាមទម្រង់ស្តង់ដារអន្តរជាតិ។

# ជំពូក ៣ ៖ គោលនយោបាយ និងបរិយាកាសអំណោយផលដល់ការធ្វើមូលដ្ឋានីយកម្មSDGs

## ៣.១. យុទ្ធសាស្ត្រជាតិសម្រាប់ការអនុវត្ត និងធ្វើមូលដ្ឋានីយកម្មSDGs

ក្នុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តរបៀបវារៈប្រកបដោយមហិច្ឆតា លើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ នៅក្នុងសម័យប្រជុំប្រចាំឆ្នាំនៃមហាសន្និបាតអង្គការសហប្រជាជាតិ។ ត្រលប់មកដល់ប្រទេសកម្ពុជាវិញ រដ្ឋាភិបាលបានអនុម័តយ៉ាងទូលំទូលាយនូវSDGs ដើម្បីឱ្យសមស្របបំផុតនៅក្នុងបរិបទនៃប្រទេសកម្ពុជា ដោយពិចារណាលើតម្រូវការជាតិ បញ្ហាប្រឈម និងសេចក្តីប្រាថ្នា (VNR, 2019)។ ក្នុងន័យនេះ កម្ពុជាបានបន្ថែមនូវគោលដៅចាំបាច់មួយបន្ថែមទៀត ដែលហៅថា "ការបញ្ចប់ផលប៉ះពាល់អវិជ្ជមាននៃគាប់មីន/សំណល់មិនទាន់ផ្ទុះសល់ពីសម័យសង្គ្រាម និងលើកកម្ពស់ជំនួយដល់ជនរងគ្រោះ"។ សរុបមក គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា(CSDGs) មាន១៨ ដែលមានសូចនាករគោលដៅ៨៨ ពាក់ព័ន្ធនឹងគោលដៅជាតិ និងសូចនាករគោលដៅចំនួន១៤៨ ពាក់ព័ន្ធត្រូវបានកំណត់ជាសកល និងជាលក្ខណៈមូលដ្ឋាន។ ទាំងនេះគូសបញ្ជាក់អំពីកម្រិតនៃការធ្វើជាតិតូបនីយកម្មនៃSDGs និងការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា(VNR, 2019)។

# តារាងទី២ ៖ គោលនយោបាយជាតិ គោលនយោបាយវិស័យ យុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រ

| កម្រិត | គោលនយោបាយ យុទ្ធសាស្ត្រ និង ផែនការយុទ្ធសាស្ត្រសំខាន់ៗ | ការឆ្លើយតប SDGs | | | | | | | | | | | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | |
| ជាតិ | 1. យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | ១៨ |
| | 2. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ | Y | Y | Y | Y | Y | Y | | Y | Y | Y | Y | | Y | | Y | Y | Y | | ១៤ |
| | 3. គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០២៣ | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | Y | ១៨ |
| | 4. គោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ | Y | Y | Y | Y | Y | | | Y | | Y | | | | | | | Y | | ៨ |
| វិស័យ | 5. គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ | Y | | | | | | | Y | Y | | | | | | | | Y | | ៤ |
| | 6. ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ២០១៣-២០៣០ | Y | Y | | Y | | | Y | Y | | | | | Y | | | | Y | | ៧ |
| | 7. យុទ្ធសាស្ត្រអព្យាក្រឹត្យកាបោនរយៈពេលវែង ២០២១ | Y | | | | Y | Y | Y | Y | | | Y | Y | Y | Y | Y | | Y | | ១១ |
| | 8. ផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ | Y | Y | | | Y | Y | Y | | | Y | | Y | Y | Y | Y | Y | Y | | ១២ |
| | 9. ផែនការសកម្មភាព និងយុទ្ធសាស្ត្រជីវៈចម្រុះជាតិ ២០១៦ - ២០២០ | Y | Y | Y | | Y | Y | Y | | Y | Y | | Y | Y | Y | Y | | Y | | ១៣ |
| | 10. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម ២០១៩-២០២៣ | Y | Y | | Y | | | | | Y | | | Y | Y | Y | Y | | Y | | ៩ |
| | 11. នារីរតនៈទី៥ (ផែនការយុទ្ធសាស្ត្រដើម្បីជំរុញការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី ២០១៩-២០២៣ | Y | | Y | Y | Y | | | Y | | Y | | | Y | | | | Y | | ៨ |
| | 12. ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០ | Y | | Y | | Y | | | | | Y | | | | | | | Y | | ៥ |
| | 13. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ | Y | | | Y | Y | | | | | Y | | | | | | | Y | | ៥ |
| | 14. គោលនយោបាយអន្តោប្រវេសន៍ពលកម្ម សម្រាប់កម្ពុជា ២០១៥-២០១៨ | Y | | | | | | | Y | | | | | | | | | Y | | ៣ |
| | 15. គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥ | Y | Y | | | | | | Y | | | | | | | | | Y | | ៤ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | ១៥ | ៩ | ៧ | ៨ | ១០ | ៦ | ៦ | ១០ | ៦ | ៩ | ៤ | ៦ | ៩ | ៦ | ៧ | ៤ | ១៥ | ២ | |

***ចំណាំ*** *៖ ការជ្រើសរើសគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រទាំងនេះមកសិក្សា គឺផ្អែកលើឆ្នាំដាក់ចេញឱ្យអនុវត្ត ពោលគឺ ចាប់ពីឆ្នាំ២០១៥ ដែលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពត្រូវបានប្រកាស។*

ជាទូទៅ ដំណើរការធ្វើមូលដ្ឋានីយកម្មនៃSDGs នៅកម្ពុជា គឺផ្អែកលើការវាយតម្លៃសមិទ្ធផល និងគោលដៅមិនទាន់បានបញ្ចប់ នៃគោលដៅនិងសូចនាករគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs)។ ជាក់ស្តែង CSDGs របស់កម្ពុជាត្រូវបានរួមបញ្ចូលយ៉ាងទូលំទូលាយ ហើយក៏ជាធាតុចូលចម្បងសម្រាប់យុទ្ធសាស្ត្រចតុកោណ(RS) ដំណាក់កាលទី៤ ក៏ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣(NSDP,2019-2023) ដែលជាក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិដ៏សំខាន់ និងជាឯកសារយោងសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍គ្រប់វិស័យនៅកម្ពុជា។ នៅក្នុងការពិនិត្យឡើងវិញរាល់ឯកសារទាំងនោះ គេឃើញថា ស្ទើរតែគ្រប់ផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យទាំងអស់បានយោងយ៉ាងទូលំទូលាយទៅលើNSDP និងRS ក្នុងការកំណត់គំនិត និងការកំណត់អាទិភាពរបស់ពួកគេ។ គេក៏បានរកឃើញថា ក្រសួងពាក់ព័ន្ធបានធ្វើសមាហរណកម្មខ្លួនយ៉ាងសកម្ម ដើម្បីអនុវត្តតួនាទីរបស់ពួកគេក្នុងការសម្រេចបាននូវការធ្វើជាតិតូបនីយកម្ម និងការធ្វើមូលដ្ឋានីយកម្មនៃSDGs នៅកម្ពុជា ជាពិសេស SDG 1, SDG 17, SDG 5, SDG 8, SDG 2, និងSDG 13 (សូមមើលតារាងទី២)។

ក្រសួងផែនការ បានទទួលខុសត្រូវក្នុងការសម្របសម្រួល និងបង្រួបបង្រួមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលប្រចាំឆ្នាំ(PIP) ចាប់តាំងពីឆ្នាំ១៩៩៦ មកម្លេះ។ កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលប្រចាំឆ្នាំ(PIP) ត្រូវបានរៀបចំដើម្បីផ្តល់អាទិភាពដល់រដ្ឋាភិបាលជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការស្វែងរកធនធាន និងជំនួយបច្ចេកទេសពីទីភ្នាក់ងារម្ចាស់ជំនួយ ដៃគូអភិវឌ្ឍន៍ និង/ឬវិស័យឯកជន ដើម្បីអនុវត្តNSDP យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ គោលនយោបាយ និងក្របខ័ណ្ឌ ក៏ដូចជា ផែនការអភិវឌ្ឍន៍ខេត្ត(PDP)។ ទាំងរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ(រាជធានី-ខេត្តចំនួន២៥) ទទួលខុសត្រូវក្នុងការរៀបចំ កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលប្រចាំឆ្នាំPIPs ផ្ទាល់ខ្លួនប្រចាំឆ្នាំ ដោយផ្អែកលើតម្រូវការផ្ទាល់ខ្លួន ការអភិវឌ្ឍន៍ និងរបៀបវារៈអាទិភាពនៃការវិនិយោគ ហើយបន្ទាប់មកដាក់ជូនក្រុមប្រឹក្សាខេត្ត ដើម្បីពិនិត្យ និងអនុម័ត មុននឹងបញ្ជូនទៅក្រសួងផែនការ(MOP)។ ទោះជាយ៉ាងណាក៏ដោយ ការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល ទើបត្រូវបានចាប់ផ្តើមនៅក្នុងឆ្នាំ២០០៩ និងបន្តរហូតដល់បច្ចុប្បន្ន។

លើសពីនេះ ក៏នៅមានក្របខ័ណ្ឌបទប្បញ្ញត្តិសំខាន់មួយចំនួនទៀត ដែលគេហៅថាប្រកាសអន្តរក្រសួង(ប្រកាស) រវាងក្រសួងមហាផ្ទៃ(MOI) និងក្រសួងផែនការ(MOP) ស្តីពី ការរៀបចំផែនការអភិវឌ្ឍន៍(ផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំPDP) និងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល(PIP) សម្រាប់រាជធានី ខេត្ត ក្រុង/ស្រុក/ខណ្ឌ ក្នុងប្រទេសកម្ពុជា ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០១០។ PDP គឺជាផែនទីបង្ហាញផ្លូវជាយុទ្ធសាស្ត្រសម្រាប់ក្របខ័ណ្ឌអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ ដើម្បីដោះស្រាយអាទិភាព

បន្ទាន់ជាយុទ្ធសាស្ត្រ រួមទាំង ចក្ខុវិស័យការអភិវឌ្ឍន៍ គោលដៅ របៀបវារៈ និងយុទ្ធសាស្ត្រ។ យើងសូមសង្កត់ធ្ងន់ថាPDP ក៏ត្រូវបានគេប្រើជាឯកសារយោងជាមូលដ្ឋានសម្រាប់ការរៀបចំ PIP ផងដែរ។ ផែនការទាំងពីរ គឺPDP និងPIP កំពុងឆ្លើយតបនឹងCSDGs ដោយប្រយោលតាមវិធីផ្សេងៗគ្នា ដោយផ្អែកលើមធ្យោបាយធនធាន និងអាទិភាពផ្ទាល់ខ្លួនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

បន្ទាប់ពីPIP ក្នុងឆ្នាំ២០១០ មក គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NC-SNDD) បានរៀបចំកម្មវិធីអនុវត្តរយៈពេលបីឆ្នាំដំបូង២០១១-២០១៣ (IP3) រួចត្រូវបានពង្រីកដល់ឆ្នាំ២០១៤។ IP3 ដំណាក់កាលទីពីរ(២៩១៥-២០១៧) និងIP3 ដំណាក់កាលទីបី(២០១៨-២០២០)។ IP3 បានដើរតួនាទីជាផែនទីបង្ហាញផ្លូវ និងជាកិច្ចដំណើរការដ៏សំខាន់សម្រាប់ការកំណត់មុខងារផ្តល់សេវា ក្នុងក្របខ័ណ្ឌវិមជ្ឈការ ផ្ទេរសិទ្ធិ/ប្រតិភូកម្ម ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន។ IP3 ផ្តោតលើការបង្កើតអភិបាលកិច្ច មុខងារ និងការត្រួតពិនិត្យរដ្ឋបាលថ្នាក់ក្រោមជាតិ(SNA) ដោយចាប់ផ្តើមពីស្រុក និងក្រុង ដើម្បីធានាបាននូវការគាំទ្រ និងកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលរវាងស្រុក/ក្រុង(DM) និងឃុំ/សង្កាត់(CS) ហើយវាក៏មានគោលបំណងពង្រឹងបន្ថែមនូវសមត្ថភាព និងភាពជាម្ចាស់របស់ឃុំ សង្កាត់ ព្រមទាំងការអភិវឌ្ឍន៍សមត្ថភាពរបស់រាជធានី និងខេត្ត ក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធទាំងអស់។

## ៣.២. យន្តការសម្របសម្រួលថ្នាក់ជាតិ

មានភ្នាក់ងារសម្របសម្រួល និងគាំទ្រសំខាន់ៗចំនួនពីរសម្រាប់ការអនុវត្ត និងការធ្វើមូលដ្ឋានីយកម្មSDGs នៅកម្ពុជា គឺ ក្រសួងផែនការ(MOP) និងក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព(NCSD)។ យន្តការទាំងពីរមានតួនាទី និងទំនួលខុសត្រូវផ្សេងៗគ្នា ប៉ុន្តែធ្វើការងារបំពេញឱ្យគ្នាទៅវិញទៅមក។

ទីមួយ ក្រសួងផែនការ(MOP) ត្រូវបានចាត់តាំងជាទីភ្នាក់ងារសម្របសម្រួល និងរាយការណ៍របស់កម្ពុជា ហើយក៏ត្រូវបានអនុញ្ញាតឱ្យដឹកនាំ និងសម្របសម្រួលការធ្វើជាតិតូបនីយកម្មនៃSDGs នៅកម្ពុជាផងដែរ។ នៅឆ្នាំ១៩៩៣ វិទ្យាស្ថានជាតិស្ថិតិ(NIS) ត្រូវបានបង្កើតឡើងដើម្បីបម្រើជាចំណុចគោលលើកិច្ចការស្ថិតិនៅក្នុងប្រទេសកម្ពុជា(សូមមើលរូបភាពទី៣)។ NIS ចងក្រង និងបង្រួបបង្រួមស្ថិតិដែលផ្តល់ដោយការិយាល័យវិមជ្ឈការ ហើយប្រមូលទិន្នន័យបឋមតាមរយៈការស្ទង់មតិគ្រួសារ និងចំនួនប្រជាជន ធ្វើជំរឿនកសិកម្ម និងសេដ្ឋកិច្ច។ ប្រទេសកម្ពុជាមានរចនាសម្ព័ន្ធស្ថិតិវិមជ្ឈការ។ មានន័យថា មានការិយាល័យស្ថិតិ ឬអង្គភាពស្ថិតិនៅក្នុងនាយកដ្ឋានផែនការ និងស្ថិតិគ្រប់ក្រសួង និងនៅក្នុងអង្គភាពផែនការ និងស្ថិតិក្នុងខេត្ត និងស្រុក/ក្រុង/ខណ្ឌ។ នេះហើយជាមូលហេតុដែល NIS មានតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចសមិទ្ធផល និងការធ្វើមូលដ្ឋានីយកម្មនៃSDGs ជាពិសេសការរៀបចំ និងគោលដៅអភិវឌ្ឍន៍ ការកំណត់គោលដៅ និងសូចនាករសម្រាប់កម្ពុជា។



រូបភាពទី៣ ៖ រចនាសម្ព័ន្ធវិទ្យាស្ថានជាតិស្ថិតិ(NIS)

ទីពីរ ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព(NCSD) ត្រូវបានបង្កើតឡើងក្នុងខែឧសភា ឆ្នាំ២០១៥ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន(MOE)។ NCSD ត្រូវបានបង្រួបបង្រួមពីស្ថាប័នចំនួនបួនគឺ (១) ក្រុមប្រឹក្សាជាតិនៃការលូតលាស់បៃតង និងលេខាធិការដ្ឋានរបស់ខ្លួន (២) គណៈកម្មាធិការជាតិបម្រែបម្រួលអាកាសធាតុ និងលេខាធិការដ្ឋានរបស់ខ្លួន (៣) លេខាធិការដ្ឋានសុវត្ថិភាពជីវៈចម្រុះ និង (៤) គណៈកម្មាធិការដឹកនាំជីវៈចម្រុះជាតិ(សូមមើលរូបភាពទី៤)។ NCSD មានតួនាទីត្រួតពិនិត្យកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសក្នុងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងជានាគុល្យភាពសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌របស់ប្រទេសជាតិ។ ក្រុមប្រឹក្សាជាតិនេះ ក៏មានកាតព្វកិច្ចរៀបចំ សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រពាក់ព័ន្ធ ឧបករណ៍ច្បាប់ ផែនការ និងកម្មវិធីលើគ្រប់វិស័យនៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព ព្រមទាំងត្រួតពិនិត្យ និងរាយការណ៍អំពីការអនុវត្តរបស់កម្ពុជាលើការប្តេជ្ញាចិត្តរបស់ខ្លួនជាមួយអន្តរជាតិ។ NCSD រួមមានក្រសួង ស្ថាប័នចំនួន៣៦ និងអភិបាលរាជធានី/ខេត្តចំនួន២៥។ ក្រុមប្រឹក្សាជាតិនេះមានកិច្ចប្រជុំប្រចាំឆ្នាំយ៉ាងហោចណាស់មួយលើក និងការប្រជុំបន្ថែមតាមការស្នើសុំរបស់សមាជិក។




**រូបភាពទី៤ ៖ រចនាសម្ព័ន្ធក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព(NCSD)**

ជាយុទ្ធសាស្ត្រNCSD គាំទ្រដល់ការតាក់តែង និងការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព ដែលផ្តោតលើសសរស្តម្ភសំខាន់ៗចំនួន៦៖

(1) គោលនយោបាយជាតិ និងក្របខ័ណ្ឌច្បាប់;

(2) ការប្រែប្រួលអាកាសធាតុ;

(3) ការអភិរក្សជីវៈចម្រុះ;

(4) សេដ្ឋកិច្ចបៃតង;

(5) វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា; និង

(6) ប្រតិបត្តិការ។

រហូតមកដល់ពេលនេះNCSD បានបង្កើតច្បាប់ និងគោលនយោបាយមួយចំនួនទាក់ទងនឹងការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា រួមមានៈ

(ក) ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិបរិស្ថាន២០១៦-២០២៣,

(ខ) ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិជីវៈចម្រុះ២០១៦-២០២០,

(គ) ផែនការយុទ្ធសាស្ត្រកំណើនបៃតងជាតិ២០១៣-២០៣០,

(ឃ) គោលនយោបាយជាតិស្តីពីកំណើនបៃតង,

(ង) ផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣,

(ច) ផែនការសកម្មភាពបម្រែបម្រួលអាកាសធាតុតាមវិស័យ២០១៤/៥-២០១៨,

(ឆ) យុទ្ធសាស្ត្រREDD+ ជាតិ២០១៧-២០២៦,

(ដ) ក្រមបរិស្ថាន និងធនធានធម្មជាតិ និង
(ឈ) របៀបវារៈសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

រដ្ឋបាលថ្នាក់ក្រោមជាតិក៏បានចូលរួមចំណែកក្នុងការតាក់តែងច្បាប់ និងគោលនយោបាយនៅថ្នាក់ជាតិ ផងដែរ ដោយឆ្លុះបញ្ចាំងពីស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ និងបានលើកឡើងពីកង្វល់ និងសំណើតាមរយៈការពិគ្រោះយោបល់ និងកិច្ចប្រជុំក្នុងនាមសមាជិកNCSD។
តាមរយៈNCSD ក្រសួងជាច្រើនបានអនុវត្តគម្រោងដែលទទួលបានការគាំទ្រថវិកាមួយចំនួន ដោយមានការគាំទ្រពីកម្មវិធីអន្តរជាតិ(ដូចជា GEF, UNDP, UNEP, UNIDO, IFAD, WB, FAO)។ គម្រោងដែលបានអនុវត្តទាំងនោះស៊ីគ្នាយ៉ាងទូលំទូលាយជាមួយSDG១១: ទីក្រុង និងសហគមន៍ប្រកបដោយនិរន្តរភាព SDG១២: ទំនួលខុសត្រូវការប្រើប្រាស់ និងផលិតកម្ម; SDG១៣: ការប្រែប្រួលអាកាសធាតុ; SDG ១៤: ជីវិតក្រោមទឹក; និង SDG១៥: ជីវិតនៅលើដី។

## ៣.៣. ការបង្កើនបរិយាកាសស្ថាប័នសម្រាប់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ

ចាប់តាំងពីឆ្នាំ១៩៩៦មក កម្ពុជាបានអនុវត្តកំណែទម្រង់ស៊ីជម្រៅជាច្រើនដើម្បីពង្រឹងវិមជ្ឈការ និងវិសហមជ្ឈការ(D&D)។ ដំណើរការកំណែទម្រង់បានចាប់ផ្តើមជាមួយនឹងកម្មវិធីសិលាក្នុងអំឡុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០។ បន្ទាប់មក នៅឆ្នាំ២០០១ កម្ពុជាបានអនុម័តច្បាប់ចំនួនពីរ ដែលនាំទៅដល់ការបោះឆ្នោតតាមបែបប្រជាធិបតេយ្យលើកដំបូងនៅថ្នាក់ឃុំ/សង្កាត់ក្នុងឆ្នាំ២០០២។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបានបន្តដោយកំណែទម្រង់សំខាន់ៗ ដើម្បីចាត់ចែង គ្រប់គ្រងថវិកា និងការផ្ទេរការគ្រប់គ្រង និងការធ្វើប្រតិភូកម្មប្រទេសកម្ពុជា ដែលអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានអំណាចធ្វើសេចក្តីសម្រេច និងសិទ្ធិអំណាចបន្ថែមកាន់តែច្រើន(សូមមើលតារាងទី៣)។ ក្រៅពីបទប្បញ្ញត្តិ ក៏មានយន្តការ និងក្របខ័ណ្ឌជាតិមួយចំនួនទៀត សំដៅពង្រឹងការអនុវត្តច្បាប់ ដូចជា ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធីជាតិស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ ដែលដឹកនាំដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) និងក្រសួងមហាផ្ទៃ។ ថ្មីៗនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវកម្មវិធីជាតិស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ២០២១-២០៣០ និងយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥។

ក្នុងចំណោមក្រសួងចំនួន៣៩ នៅថ្នាក់ជាតិ មាន២៨ក្រសួងដែលមានមន្ទីរនៅថ្នាក់រាជធានី/ខេត្ត និង មានការិយាល័យចំនួន១៣ នៅថ្នាក់ស្រុក/ក្រុង/ខណ្ឌ(ធនាគារពិភពលោកឆ្នាំ២០២១)។ គោលនយោបាយ និងបទប្បញ្ញត្តិមួយចំនួនធំ មិនត្រឹមតែបានចូលរួមកាត់បន្ថយគម្លាតរវាងគោលនយោបាយ(រួមទាំងCSDGs) ប៉ុណ្ណោះទេ តែថែមទាំងជួយសម្រួលគោលនយោបាយឱ្យទៅជាសកម្មភាព និងធានាបាននូវក្របខ័ណ្ឌដ៏មានប្រសិទ្ធភាពសម្រាប់ការផ្ទេរធនធានពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិទៀតផង។ យន្តការ ពហុកម្រិតរបស់រាជរដ្ឋាភិបាល គឺជា គន្លឹះកំណត់នូវភាពជោគជ័យនៃដំណើរអភិវឌ្ឍន៍របស់កម្ពុជាទៅកាន់ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក៏ដូចជា ការអនុវត្តCSDGs ឆ្នាំ២០៣០។

## តារាងទី៣ ៖ ច្បាប់ អនុក្រឹត្យ ប្រកាស គោលនយោបាយសំខាន់ៗ

| ល.រ | ចំណងជើង | ឆ្នាំ |
|---|---|---|
| **អភិបាលកិច្ច និងកំណែទម្រង់** | | |
| ១ | កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ២០០៤ |
| ២ | កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ | ២០១៩ |
| ៣ | ច្បាប់ ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ២០០៨ |
| ៤ | ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ | ២០០៨ |
| ៥ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ២០១០ |
| **វិមជ្ឈការសារពើពន្ធ** | | |
| ៦ | ច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០១១ |
| ៧ | អនុក្រឹត្យលេខ ៣២ ស្តីពី មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ | ២០១៦ |
| ៨ | អនុក្រឹត្យលេខ ០៦ ស្តីពី ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | ២០១៧ |
| ៩ | ប្រកាសលេខ ១៤៥៨ ស្តីពី ការបែងចែកចំណូលពន្ធដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ | ២០១៧ |
| **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** | | |
| ១០ | អនុក្រឹត្យលេខ ២១៩ ស្តីពី ផែនការអភិវឌ្ឍន៍ ផែនការវិនិយោគសាធារណៈ៣ឆ្នាំរំកិល សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ២០០៩ |
| ១១ | ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (រួមទាំងថ្នាក់ក្រោមជាតិ) | ២០១២ |
| **ការគ្រប់គ្រងបុគ្គលិក និងការអភិវឌ្ឍសមត្ថភាព** | | |
| ១២ | គោលនយោបាយស្តីអីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស នៅថ្នាក់ក្រោមជាតិ | ២០១៣ |
| ១៣ | ច្បាប់លក្ខន្តិកៈមន្ត្រីរាជការថ្នាក់ក្រោមជាតិ | ២០១៦ |
| ១៤ | អនុក្រឹត្យលេខ ២៤០ ស្តីពីការធ្វើប្រតិភូកម្មដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ក្នុងការគ្រប់គ្រងការងារមន្ត្រីរាជការថ្នាក់ក្រោមជាតិ | ២០១៧ |

កម្ពុជាបាននិងកំពុងខិតខំប្រឹងប្រែងជាច្រើនក្នុងការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែស៊ីជម្រៅ។ ជាលទ្ធផល មានការបង្កើនការផ្ទេរធនធាន និងការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ លើមុខងារគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ ក៏ដូចជាការប្រមូលចំណូល ដែលអាចឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានតួនាទីកាន់តែសំខាន់ និងមានប្រសិទ្ធភាពជាងមុន ក្នុងការអនុវត្ត និងធ្វើមូលដ្ឋានីយកម្មSDGs នៅកម្ពុជា។ ឧទាហរណ៍ រដ្ឋបាលខេត្ត និងស្រុកទទួលបានចំណូលបានមកពីចំណូលពន្ធ និងមិនមែនពន្ធ រួមទាំងចំណូលពីអចលនទ្រព្យថ្នាក់ក្រោមជាតិ ដីធ្លី អណ្តូងរ៉ែ សំណង់ និងការិយាល័យច្រកចេញចូលតែមួយ។ ការិយាល័យច្រកចេញចូលតែមួយត្រូវបានសាកល្បងដំបូងក្នុងឆ្នាំ

២០០៣ ហើយត្រូវបានពង្រីកទូទាំងប្រទេស។ បច្ចុប្បន្ននេះ ការិយាល័យច្រកចេញចូលតែមួយមានពីរកម្រិតផ្សេងគ្នា គឺ នៅកម្រិតរាជធានី-ខេត្ត(CP) និងកម្រិតស្រុក ក្រុង និងខណ្ឌ(DMK)។

ថ្វីត្បិតតែការចំណាយសាធារណៈនៅថ្នាក់ក្រោមជាតិ នៅកម្ពុជា ស្ថិតក្នុងចំណោមកម្រិតទាបបំផុតក្នុងពិភពលោកក៏ដោយ ប៉ុន្តែការចំណាយត្រូវបានបន្តកើនឡើងរៀងរាល់ឆ្នាំ នៅពេលដែលGDP ជាតិកើនឡើង។ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិបានកើនឡើង៤២% ជាមធ្យមក្នុងមួយឆ្នាំក្នុងរយៈពេល៨ ឆ្នាំចុងក្រោយនេះ ដែលមានប្រហែល១៩០ លានដុល្លារក្នុងឆ្នាំ២០១៣ ឡើងដល់៨២១ លានដុល្លារក្នុងឆ្នាំ២០២០ នេះបើយោងរបាយការណ៍ធនាគារពិភពលោកឆ្នាំ២០២១ (សូមមើលរូបភាពទី៥)។ ក្នុងឆ្នាំ២០២០ ប្រាក់ចំណូលថ្នាក់ក្រោមជាតិស្មើនឹង៣.៦% នៃផលិតផលដុលក្នុងស្រុកសរុប និង១៥.៧% នៃចំណូលសាធារណៈសរុបនៅថ្នាក់ជាតិ។ ការបែងចែកចំណូលសរុបដល់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺ មិនដូចគ្នាទេ ពោលគឺ កម្រិតរាជធានី/ខេត្តទទួលបានចំណូលពន្ធច្រើនជាងគេ ខណៈដែលថ្នាក់ DMK (សង្កាត់ ក្រុង ខណ្ឌ) និង CS (ឃុំ សង្កាត់) ទទួលបានចំណូលពីការផ្ទេរមូលនិធិជាតិច្រើនជាងគេ (សូមមើលរូបភាពទី៦)។




**រូបភាពទី៥ ៖ សរុបចំណាយរដ្ឋបាលថ្នាក់ក្រោមជាតិ (លានរៀល)**[1]

[1] The World Bank (2021): Cambodia Intergovernmental Fiscal Architecture Study




**រូបភាពទី៦ ៖ ការបែងចែកចំណូលជាតិ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩**

ក្នុងឆ្នាំ២០១២ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពី "ដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ" ដែលជាសមិទ្ធផលនៃសារពើពន្ធវិមជ្ឈការរដ្ឋបាលដ៏សំខាន់មួយទៀតនៅក្នុងប្រទេសកម្ពុជា។ អនុក្រឹត្យនេះបានផ្ទេរភារកិច្ចចាំបាច់មួយចំនួនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដំណើរការផ្ទេរមុខងារ និងធនធានពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រព័ន្ធ សមហេតុផល មានការសម្របសម្រួល មានការពិគ្រោះយោបល់ មានតម្លាភាព និងមានសមធម៌។ ក្នុងដំណាក់កាលទីមួយ ឆ្នាំ២០១២-២០១៣ វិស័យសំខាន់ៗ និងក្រសួងដែលបានឯកភាពលើការផ្ទេរមុខងារមានចំនួន២៨ រួមមាន អប់រំ សាធារណៈការនិងដឹកជញ្ជូន បរិស្ថាន កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អភិវឌ្ឍន៍ជនបទ សង្គមកិច្ច ទេសចរណ៍ និងធារាសាស្ត្រ។ វិមជ្ឈការនេះអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃសេវាសាធារណៈ (មានភាពងាយស្រួល មានតម្លាភាព និងមានគណនេយ្យភាពកាន់តែច្រើន) ហើយមានសក្តានុពលរួមចំណែកក្នុងការសម្រេចបាននូវការធ្វើមូលដ្ឋានីយកម្មនៃSDGs នៅកម្ពុជា (សូមមើលតារាងទី៤)។

**តារាងទី៤ ៖ ការផ្ទេរមុខងារពាក់ព័ន្ធនឹងSDGs ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដំណាក់កាលទី១**

| ល.រ | វិស័យគោលដៅ(២០១២-២០១៣) | ឆ្លើយតបដោយផ្ទាល់នឹង SDGs |
|---|---|---|
| ១ | កសិកម្ម | ១, ២ |
| ២ | អប់រំ | ១, ៤ |
| ៣ | ព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន | ១, ២, ១២, ១៣, ១៤, ១៥ |
| ៤ | ឧស្សាហកម្ម និងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច | ៨, ៩ |
| ៥ | ការប្រើប្រាស់ដីធ្លី សូរិយោដី និងសំណង់ | ៦, ១១ |
| ៦ | ការផលិត និងចែកចាយអគ្គីសនី | ៧ |
| ៧ | ការគ្រប់គ្រងសំណល់ | ៦ |

| | | |
|---|---|---|
| ៨ | សង្គមកិច្ច | ១, ២, ៣, ១០ |
| ៩ | អភិវឌ្ឍន៍ជនបទ | ១, ១០ |
| ១០ | សុខាភិបាល អាហារូបត្ថម្ភ និងសេវាគាំពារ បុរស ស្ត្រី យុវជន កុមារ ក្រុមងាយរងគ្រោះ និងជនជាតិដើមភាគតិចប្រកបដោយបរិយាប័ន្ន | ៣, ៥ |
| ១១ | ឆ្លើយតបតម្រូវការពិសេស រួមទាំងតំបន់ទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រ កេរ្តិ៍មរតកវប្បធម៌ | ១, ២, ១០ |

កាលពីខែធ្នូ ឆ្នាំ២០១៩ ការគ្រប់គ្រងសេវាសុខាភិបាលទាំងមូលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈអនុក្រឹត្យលេខ១៩៣ ។ ឯកសារនេះចូលជាធរមានក្នុងខែមករា ឆ្នាំ២០២០ ហើយបានតែងតាំង និងប្រគល់ការគ្រប់គ្រងមន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ និងសេវាសុខាភិបាល ក្នុងចំណោមសេវាផ្សេងៗទៀត ឱ្យដល់រដ្ឋបាលរាជធានី និងខេត្ត (ចូលក្នុងក្រុមCPA)។ លើសពីនេះ ការពិភាក្សាកំពុងបន្ត ដើម្បីបង្កើនទំនួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា និងក្នុងការដោះស្រាយបញ្ហាប្រឈមបម្រែបម្រួលអាកាសធាតុ តាមរយៈការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធកាន់តែប្រសើរឡើង។

ក្នុងរយៈពេលដប់ឆ្នាំ(២០១០–២០២០) ធនធានមនុស្ស ធនធានសម្ភារៈ និងធនធានហិរញ្ញវត្ថុត្រូវបានបែងចែកទៅថ្នាក់ក្រោមជាតិ ពោលគឺ ថ្នាក់រាជធានី ខេត្ត ថ្នាក់ស្រុក ក្រុង ខណ្ឌ និងថ្នាក់ឃុំ/សង្កាត់។ មូលនិធិជាង១៤,៦៤៣ពាន់លានរៀលត្រូវបានបែងចែកក្នុងកំឡុងឆ្នាំ២០១០ ដល់២០២០។ មូលនិធិឃុំ សង្កាត់មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។












**រូបភាពទី៧ ៖ មូលនិធិវិភាជន៍ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ (របាយការណ៍ និងបទបង្ហាញMOI/NCDD)**

នៅឆ្នាំ២០១៦ មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ(SNIF) ត្រូវបានបង្កើតឡើងដើម្បីផ្តល់មូលនិធិពីរដ្ឋាភិបាលជាតិ និងប្រភពផ្សេងទៀតសម្រាប់គម្រោងវិនិយោគសាធារណៈដែលរៀបចំ និងអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ មូលនិធិនេះត្រូវបានកំណត់ត្រឹម0.0២% នៃថវិកាជាតិ ហើយដែលត្រូវបានគេរំពឹងថានឹងកើនឡើង0.0៧% ក្នុងឆ្នាំ២០២០។ ក្រុមប្រឹក្សាភិបាលSNIF ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងពីររូប(ម្នាក់មកពីMEF និងម្នាក់មកពីMoI) និងសមាជិក១៨រូបមកពីក្រសួងសំ

ខាន់ៗ។ មូលនិធិនេះត្រូវបានបង្កើតឡើងតាមរយៈដំណើរការជ្រើសរើសគម្រោងដែលមានការប្រកួតប្រជែង ហេតុដូច្នេះហើយទើបមូលនិធិនេះត្រូវបានបែងចែកទៅឱ្យតែស្រុកណាដែលបានជ្រើសរើសគម្រោងតែប៉ុណ្ណោះ។ ក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានចូលរួមចំណែកចំនួន១,៥លានដុល្លារអាមេរិកទៅក្នុងSNIF ហើយធនាគារអភិវឌ្ឍន៍អាស៊ី(ADB) បានចូលរួមចំណែកចំនួន៥លានដុល្លារអាមេរិក។ រដ្ឋបាលខណ្ឌចំនួន១៥ ត្រូវបានជ្រើសរើសដើម្បីទទួលបានមូលនិធិពីការរួមចំណែករបស់រាជរដ្ឋាភិបាល។ ចំណែកខណ្ឌចំនួន៣០ទៀត ក្រុងចំនួន៨ និងខណ្ឌចំនួន៤ទៀតត្រូវបានជ្រើសរើសដើម្បីទទួលបានមូលនិធិពីADB។ ថវិកាSNIF សម្រាប់ឆ្នាំ២០២០ ត្រូវបានគេប៉ាន់ប្រមាណថាមានប្រហែល២លានដុល្លារអាមេរិក ដែលប្រហែលជា0,៥ លានដុល្លារអាមេរិកត្រូវបានបែងចែកសម្រាប់លេខាធិការដ្ឋានSNIF និង១,៥លានដុល្លារផ្សេងទៀត គឺ សម្រាប់គម្រោងអភិវឌ្ឍន៍ក្នុងស្រុកចំនួន១២ នៅ៩ខេត្ត(គ.ជ.អ.ប ២០១៩)។ នេះគឺជាប្រភពហិរញ្ញវត្ថុដ៏មានសក្តានុពលមួយ ដើម្បីលើកកម្ពស់ការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្ត SDGs នៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា។

នៅក្នុងឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានដាក់ចេញនូវ "យុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកា ២០១៩-២០២៥" ដែលជាសសរស្តម្ភស្នូលនៃកម្មវិធីកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(PFM) នៅក្នុងប្រទេសកម្ពុជា។ យុទ្ធសាស្ត្រនេះមានគោលបំណងបំប្លែងប្រព័ន្ធថវិកាកម្ពុជាបន្តិចម្តងៗ ទៅជាប្រព័ន្ធប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ស្របតាមបទដ្ឋានប្រតិបត្តិល្អអន្តរជាតិ។ អាស្រ័យហេតុនេះ យុទ្ធសាស្ត្របានផ្តោតលើទិដ្ឋភាពសំខាន់ៗចំនួនបួនសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ៖ (១) ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី/ខេត្ត (២) ការរៀបចំថវិកា ការចរចា និងការអនុម័តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (៣) ការអនុវត្ត និងត្រួតពិនិត្យថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង(៤) ប្រព័ន្ធរាយការណ៍ ការត្រួតពិនិត្យ និងវាយតម្លៃថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាគោលការណ៍ យុទ្ធសាស្ត្រនេះបានរួមបញ្ចូលគ្នានូវថវិការដ្ឋបាលជាតិ និងថ្នាក់ក្រោមជាតិ(SNA) តាមរយៈការតម្រឹមសកម្មភាព កម្មវិធី និងការរៀបចំរដ្ឋបាល(សូមមើលរូបភាពទី៨)។ បច្ចុប្បន្ន យុទ្ធសាស្ត្រនេះ ស្ថិតនៅដំណាក់កាលទីបី ដែលហៅថា "ការភ្ជាប់គោលនយោបាយថវិកា"។




**រូបភាពទី៨ ៖ តំណរភ្ជាប់រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការអនុវត្តគោលនយោបាយអាទិភាព**[2]

បន្ទាប់មក នៅក្នុងខែឧសភា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានដាក់ចេញនូវ "យុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥"។ យុទ្ធសាស្ត្រនេះ គឺជាកំណែទម្រង់ប្រព័ន្ធថវិការយៈពេលវែង និងទូលំទូលាយនៅកម្ពុជា។ វាមានគោលបំណងធានាឱ្យមានការផ្សាភ្ជាប់គ្នារវាងគោលនយោបាយថវិកា ជាពិសេសគោលបំណងនៃគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែស្របគ្នានឹងគោលដៅ/អាទិភាពនៃគោលនយោបាយជាតិ។ មិនតែប៉ុណ្ណោះ ផែនការ/កម្មវិធីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវតែភ្ជាប់ទំនាក់ទំនងគ្នា និងបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក តាមរយៈការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកា។ ការសិក្សាពីបទពិសោធន៍ពីមុន និងការសិក្សាលើ "ក្របខ័ណ្ឌនៃការគ្រប់គ្រងការវិនិយោគសាធារណៈ៖ ផ្ដែកលើការអនុវត្តជាសកល និងបរិបទកម្ពុជា" រាជរដ្ឋាភិបាលកម្ពុជា(RGC) បានដាក់ចេញនូវ "យុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ២០១៩-២០២៥" ក្នុងខែតុលា ឆ្នាំ២០១៩ ដែលដឹកនាំដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)។ យុទ្ធសាស្ត្រនេះមានគោលបំណងបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមបញ្ចូលគ្នាសម្រាប់ថ្នាក់ជាតិដែលមានការឆ្លើយតប មានប្រសិទ្ធភាព មានប្រសិទ្ធផល មានតម្លាភាព មានគណនេយ្យភាព និងមាននិរន្តរភាព ក្នុងការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈ។ វាមានចក្ខុវិស័យ គឺ សម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយនិរន្តរភាព និងបរិយាប័ន្នឆ្ពោះទៅសម្រេចឱ្យបានជោគជ័យនូវទិសដៅកម្ពុជាឆ្នាំ២០២៣០ និងចក្ខុវិស័យឆ្នាំ២០៥០។

នៅខែធ្នូ ឆ្នាំ២០២១ កម្ពុជាបានអនុម័តដំណាក់កាលទីពីរនៃកម្មវិធីជាតិស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលត្រូវអនុវត្តនៅចន្លោះឆ្នាំ២០២១ ដល់ឆ្នាំ២០៣០។ គោលបំណងនៃផែនការថ្មីនេះ គឺ "ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ បរិយាប័ន្ន សមធម៌ និងយុត្តិធម៌ តាមរយៈទំនើបកម្មនៃអភិបាលកិច្ចថ្នាក់ក្រោមជាតិ និងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួល

[2] Source: Budget System Reform Strategy 2018-2025 (with statistical adjustment for 2022)

បានសេវាសាធារណៈប្រកបដោយគុណភាព"។ កម្មវិធីត្រូវបានរៀបចំឡើងជុំវិញផ្នែកសំខាន់ៗចំនួនប្រាំ គឺកំណែទម្រង់ភាពជាអ្នកដឹកនាំនិងការសម្របសម្រួល រចនាសម្ព័ន្ធនិងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្ស វិមជ្ឈការសារពើពន្ធនិងការរៀបចំផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្តល់សេវានិងការអភិវឌ្ឍន៍មូលដ្ឋាន។ កម្មវិធីនេះក៏បានផ្តោតលើអន្តរវិស័យផងដែរ តួយ៉ាងដូចជា សមភាពយេនឌ័រ សមភាពសង្គម និងការបញ្ជ្រាបនូវបរិយាប័ន្ន ភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងធ្ងន់ធ្ងរនានា។ ការអនុវត្តកម្មវិធីថ្មីនេះត្រូវការការរៀបចំផែនការរយៈពេលប្រាំឆ្នាំចំនួនពីរ ដែលរៀបរាប់លម្អិតអំពីសកម្មភាព ពេលវេលា និងថវិកា។ ផែនការប្រាំឆ្នាំដំបូង(IP-5 I) ត្រូវបានគាំទ្រដោយរដ្ឋាភិបាលកណ្តាលនៅខែកញ្ញា ឆ្នាំ ២០២២ ។

# ជំពូក ៤ ៖ សកម្មភាពក្នុងមូលដ្ឋានក្នុងការធ្វើមូលដ្ឋានីយកម្មSDGs

## ៤.១. សកម្មភាពលើកកម្ពស់ការយល់ដឹង និងភាពជាម្ចាស់លើSDGs

យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ បានកំណត់ទិសដៅយុទ្ធសាស្រ្តច្បាស់លាស់ និងរឹងមាំសម្រាប់ "កំណើនការងារ សមធម៌ និងប្រសិទ្ធភាព" ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដែលអនុវត្តមិនត្រឹមតែសម្រាប់រដ្ឋបាលជាតិប៉ុណ្ណោះទេ ថែមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ ម្យ៉ាងទៀត វាបង្កើតនិងបើកបរិយាកាសក្នុងការកសាងកម្មសិទ្ធិក្នុងមូលដ្ឋាន ហើយមិនទុកអ្នកណានៅពីក្រោយការអភិវឌ្ឍ ក្នុងប្រទេសកម្ពុជាឡើយ។

ការពិត សកម្មភាពសំខាន់ៗត្រូវបានធ្វើឡើងដើម្បីបង្កើតការយល់ដឹង និងកម្មសិទ្ធិក្នុងតំបន់លើCSDGs។ ការត្រួតពិនិត្យផ្អែកលើភស្តុតាងបានបញ្ជាក់ថាNLC/NACPC គឺជា ផ្នែកសកម្មបំផុតមួយក្នុងការកសាងសមត្ថភាព និងការលើកកម្ពស់ការយល់ដឹងលើការធ្វើមូលដ្ឋានីយកម្មCSDGs។ យ៉ាងហោចណាស់សកម្មភាពសំខាន់ៗចំនួន៣៨ ត្រូវបានអនុវត្តនៅចន្លោះខែមីនា ដល់ខែមេសា ឆ្នាំ២០១៩។ មានសិក្ខាសាលាបណ្តុះបណ្តាលមួយដែលបានធ្វើឡើងនៅខែមេសា ឆ្នាំ២០១៩ នៅខេត្តសៀមរាប ដើម្បីផ្តល់ឱ្យអ្នកចូលរួមរាប់រយនាក់នូវការយល់ដឹង ភាពជាម្ចាស់ និងការកសាងសមត្ថភាពក្នុងការធ្វើមូលដ្ឋាននីយកម្ម និងការអនុវត្តCSDGs នៅក្នុងមូលដ្ឋានរបស់ពួកគេ ហើយថ្មីៗនេះNLC បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលដល់បុគ្គលសំខាន់ៗចំនួន២៤នាក់ លើមុខវិជ្ជាដែលបានរៀបរាប់ខាងលើនៅខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២៣។ លើសពីនេះNLC/NACPC បានបញ្ចូលប្រធានបទនេះ និងរំលឹកអ្នកចូលរួមរាល់កិច្ចប្រជុំ និងសិក្ខាសាលាដែលពួកគេបានរៀបចំ។ អាស្រ័យហេតុនេះ សមាគមថ្នាក់មូលដ្ឋាន ថ្នាក់ដឹកនាំឃុំសង្កាត់ និងអ្នកចូលរួមអាចផ្តល់សារខាងលើបន្ត ទៅ MDK និងC/S (សូមមើលរូបភាពទី១៣)។

រួមជាមួយនឹងការខិតខំប្រឹងប្រែងខាងលើ MOI, MOP, MOWA, CARD/CM និង DP/DA បានផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានស្តីពីការធ្វើមូលដ្ឋានីយកម្មCSDGs និងភាពជាម្ចាស់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

ដោយមានការគាំទ្រជាសម្ភារៈជំនួយស្មារតី (IEC៖ ព័ត៌មាន ការអប់រំ និងទំនាក់ទំនង) ដែលពួកគេបានផលិត ។ លើសពីនេះ សម្ភារៈជំនួយស្មារតី (IEC) ជាច្រើនដែលទាក់ទងនឹងការលើកកម្ពស់ការយល់ដឹង CSDG អាចរកបាននៅលើគេហទំព័ររបស់ក្រសួង/ស្ថាប័នជាតិ និងនៅលើគេហទំព័រWB, ADB និង DP/DA ផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ ចំណេះដឹង និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅMDK និងC/S ក្នុងការចូលទៅកាន់/និងប្រើប្រាស់សម្ភារៈជំនួយស្មារតីទាំងនោះ តាមអនឡាញសម្រាប់ជាទុនក្នុងការកសាងផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគេ គឺ នៅទាបជាងការរំពឹងទុក។

តាមការវិភាគ ពិចារណា VSR នេះបានរកឃើញថា ប្រមាណ ៦១% នៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ដែលបានឆ្លើយតបនឹងការស្ទង់មតិ (៦០) បានបញ្ជាក់ថា វា "ចាំបាច់" ហើយប្រហែល ៣២% បាននិយាយថា "ចាំបាច់ណាស់" ដើម្បីធ្វើមូលដ្ឋានីយកម្ម CSDGs នៅក្នុងអង្គភាព ខេត្ត ក្រុងរបស់ពួកគេ (សូមមើលរូបភាពទី៩)។ ដោយសារតែពួកគេជឿថា ការសម្រេចបាននូវCSDGs នាំឱ្យមានអត្ថប្រយោជន៍សំខាន់ៗ ដូចជា ការដោះស្រាយបញ្ហាជាក់ស្តែងនៅក្នុងបរិបទក្រុង ឬខេត្តរបស់ពួកគេ និងជាពិសេសការភ្ជាប់ទំនាក់ទំនងអន្តរស្ថាប័នជាមួយអ្នកពាក់ព័ន្ធផ្សេងៗ (សាធារណៈ ឯកជន និងប្រជាជន) (សូមមើលរូបភាពទី១០)។




**រូបភាពទី៩ ៖ ទស្សនៈរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពី មូលដ្ឋានីយកម្មCSDGs**




**រូបភាពទី១០ ៖ ផលប្រយោជន៍នៃការសម្រេចបាននូវCSDGs**

បច្ចុប្បន្ន ស្ថានភាពទូទៅនៃការធ្វើមូលដ្ឋានីយកម្មCSDGs នៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺ ស្ថិតនៅក្នុងដំណាក់កាលយល់ដឹង និងការកំណត់ទស្សនៈទាននិងសកម្មភាពសម្រាប់អនុវត្ត(រូបភាពទី១១)។




**រូបភាពទី១១៖ ស្ថានភាពទូទៅនៃមូលដ្ឋានីយកម្មCSDGs នៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ទាក់ទងទៅនឹងការយល់ដឹង អំពីCSDGs រដ្ឋបាលថ្នាក់ក្រោមជាតិ តាមតំបន់ ដូចបង្ហាញក្នុងរូបភាពទី១២ គឺមាន៦៧% នៃរដ្ឋបាលថ្នាក់ក្រោមជាតិ(៤០) ការយល់ដឹងមានកម្រិត ហើយមានតែ ២៥% (១៥នាក់) ប៉ុណ្ណោះដែលបានចាត់ទុកថា បុគ្គលិកភាគច្រើនរបស់គេយល់ដឹង និងប្រើប្រាស់SDGs ជា

ឯកសារយោង នៅក្នុងការកសាងផែនការ និងយកមកប្រើជាយុទ្ធសាស្ត្រក្នុងមូលដ្ឋាន។ តំបន់ដែលមានរដ្ឋបាលថ្នាក់ក្រោមជាតិមានការយល់ដឹងមានកម្រិតទាប គឺ តំបន់ខ្ពង់រាប/ភ្នំ(១៩) និងឆ្នេរសមុទ្រ និងសមុទ្រ(១២) បន្ទាប់មក តំបន់ដែលមានការយល់ដឹងកាន់តែច្រើន គឺ តំបន់ទំនាបកណ្តាល(៨) និងទីពីរ គឺ តំបន់ជុំវិញបឹងទន្លេសាប(៤)។

ការស្ទង់មតិនេះក៏បង្ហាញផងដែរថា រដ្ឋាភិបាលជាតិដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងអំពីCSDGs នៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា(មាន៣៤%) ក្រៅពីនេះ ពួកគេយល់ដឹងតាមរយៈសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន/សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត(NLC, NACPC) ឬ/និងតាមរយៈសហភាពទីក្រុង និងអភិបាលកិច្ចមូលដ្ឋាន(UCLG ASPAC, Citynet ជាដើម) ដែលមាន(២៤%) និងដៃគូអភិវឌ្ឍន៍ និង/ឬភ្នាក់ងារផ្តល់ជំនួយ(មាន១៩%) (សូមមើលរូបភាពទី១៣)។




**រូបភាពទី១២ ៖ កម្រិតយល់ដឹង ពីSDGs របស់រដ្ឋបាលថ្នាក់ក្រោមជាតិ[3]**

[3] *ចម្លើយរបស់ពួកគេចំពោះការស្ទង់មតិ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានចាត់ថ្នាក់ជា ៤ ប្រភេទ៖*
*ប្រភេទ A: មានបុគ្គលតិចតួចណាស់នៅក្នុងអង្គភាពនេះស្គាល់ពីSDGs។ ប្រភេទ B: មនុស្សជាច្រើនបានឮអំពីSDGs ប៉ុន្តែមិនដឹងអំពីភាពពាក់ព័ន្ធរបស់ពួកគេទេ។ ប្រភេទ C: បុគ្គលិករបស់យើងភាគច្រើនបានដឹង និងធ្វើសេចក្តីយោងទៅលើSDGs ប៉ុន្តែវាមិនមែនជាអាទិភាពខ្ពស់នៅក្នុងការងាររបស់យើងទេ។ ប្រភេទ D: SDGs ត្រូវបានគេស្គាល់យ៉ាងច្បាស់នៅក្នុងស្ថាប័នរបស់យើង ហើយត្រូវបានគេប្រើជាឯកសារយោងដ៏សំខាន់នៅក្នុងផែនការអភិវឌ្ឍន៍ ផែនការវិនិយោគ និង/ឬយុទ្ធសាស្ត្ររបស់យើង។*




**រូបភាពទី១៣ ៖ ប្រភពព័ត៌មានផ្តល់ការសិក្សាពីSDGs**

ទោះបីជាការយល់ដឹងនៅតែស្ថិតក្នុងដំណាក់កាលដំបូងក៏ដោយ តែការពិនិត្យឡើងវិញនៃផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ(PDP) និងកម្មវិធីវិនិយោគសាធារណៈ(PIP) បានបង្ហាញថាមានកម្មវិធីផ្តួចផ្តើមគំនិតគ្រប់គ្រងដោយរដ្ឋបាលក្រុង និងការអនុវត្តប្រកបដោយភាពច្នៃប្រឌិតដោយសាលាក្រុងមួយចំនួន ដែលបានរួមចំណែកដល់ការធ្វើមូលដ្ឋានីយកម្មSDGs នៅក្នុងប្រទេសកម្ពុជា ទោះបីជាពួកគេមិនភ្ជាប់គំនិតផ្តួចផ្តើមទាំងនេះទៅនឹងCSDGs ក៏ដោយ។ គម្រោង/កម្មវិធីទាំងនោះ ជាករណីពិសេសសម្រាប់សុខភាពសាធារណៈ និងអនាម័យ និរន្តរភាពបរិស្ថាន និងអភិបាលកិច្ចមូលដ្ឋាន (សូមមើលខាងក្រោមជំពូក៤.៣ និងប្រអប់ទី១-៧ ក្នុងផ្នែក៤.៣)។

លើសពីនេះទៅទៀត រដ្ឋបាលថ្នាក់ក្រោមជាតិដើរតួនាទីយ៉ាងសំខាន់ៗជាច្រើនក្នុងការចូលរួមជាមួយDA/DP (ទីភ្នាក់ងារអភិវឌ្ឍន៍/ដៃគូអភិវឌ្ឍន៍) និង/ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងការអនុវត្ត និងធ្វើមូលដ្ឋានីយកម្មCSDGs នៅក្នុងដែនសមត្ថកិច្ចរបស់ពួកគេ ដែលរួមបញ្ចូលផងដែរនូវ (i) ណែនាំពីទីតាំង/កន្លែងសម្រាប់អនុវត្ត; (ii) ណែនាំ ឬជ្រើសរើសក្រុមគោលដៅនៃជនងាយរងគ្រោះ ឬសហគមន៍ដែលទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីគម្រោង/កម្មវិធី/សកម្មភាព។ (iii) សម្រាប់គម្រោងដែលទាក់ទងនឹងសំណង់ អាជ្ញាធរមូលដ្ឋានធ្វើការត្រួតពិនិត្យរួមគ្នា និងត្រួតពិនិត្យប្រចាំថ្ងៃ ដើម្បីធានាថាការងារសំណង់គោរពតាមបទប្បញ្ញត្តិក្នុងមូលដ្ឋាន និងដោះស្រាយការតាំងទីលំនៅថ្មីនិងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន/សង្គម ប្រសិនបើមាន និង (iv) បង្កើតយន្តការយូរអង្វែង ដើម្បីពង្រឹងការអនុវត្តគម្រោងក៏ដូចជាភាពជាម្ចាស់របស់មូលដ្ឋាន នៅក្រោយពេលគម្រោងត្រូវបានបញ្ចប់។

នៅក្នុងលក្ខខណ្ឌនៃចំណាត់ថ្នាក់អាទិភាពនៃCSDGs ការស្ទង់មតិបានបង្ហាញថា គោលដៅទី១: គ្មានភាពក្រីក្រនៅតែជាអាទិភាពសំខាន់បំផុតនៅគ្រប់កម្រិតទាំងអស់(សូមមើលរូបភាពទី១៤)។ ទន្ទឹមនឹងនេះ គោលដៅទី៦៖ ទឹកស្អាត និងអនាម័យ គឺជាអាទិភាពទីពីរសម្រាប់MDK ហើយ គោលដៅទី២៖ គ្មានភាពអត់ឃ្លាន គឺជា អាទិភាពសំខាន់ទីពីរនៅកម្រិតCP។ បន្តដោយគោលដៅទី៣៖ សុខភាពល្អ និងសុខុមាលភាព និងគោលដៅទី៤៖ ការអប់រំប្រកបដោយគុណភាព។ ទោះជាយ៉ាងណាក៏ដោយ ចំណាត់ថ្នាក់រួមដែលបង្ហាញថាSDG១ គឺជាអាទិភាពកំពូល ខណៈពេលដែលSDG ៤ គឺជាអាទិភាពទីពីរ ហើយSDG ៣ គឺជាអាទិភាពទីបី។









**រូបភាពទី១៤ ៖ ការចាត់អាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើសារៈសំខាន់CSDGs**

មានប្រភពព័ត៌មានសំខាន់ៗមួយចំនួនដែលបច្ចុប្បន្នមាននៅនឹងកន្លែងដើម្បីលើកទឹកចិត្ត "**កម្មវិធីអន្តរាគមន៍ផ្អែកលើភស្តុតាង**" សម្រាប់ការអនុវត្តCSDGs នៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា សម្រាប់DP/DA និង NGOs ដូចជា (១) ប្រព័ន្ធមូលដ្ឋានទិន្នន័យឃុំ(CDS), (២) ស្ថិតិថ្នាក់ក្រោមជាតិ (SNS), (៣) ជំរឿនប្រជាជនទូទៅ(GPC) ឆ្នាំ២០១៩, និង (៤) ការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ ២០២១។ ក្នុងកម្រិតខ្លះ ទិន្នន័យទាំងនេះអាចត្រូវបានគេបំបែកចេញពីគ្នា។ ដើម្បីធ្វើឱ្យវាកាន់តែមានប្រសិទ្ធភាព ឬកាន់តែមានឥទ្ធិពល ទិន្នន័យ/ព័ត៌មានទាំងអស់គួរមានប្រព័ន្ធគ្រប់គ្រងទិន្នន័យដ៏ទូលំទូលាយបន្ថែមទៀតជាមួយនឹងការធ្វើបច្ចុប្បន្នភាពជាទៀងទាត់។ ព័ត៌មានបែបនេះនឹងជួយកំណត់អត្តសញ្ញាណក្រុមណាដែលត្រូវការជំនួយអភិវឌ្ឍន៍បំផុត និងទីតាំងដែលពួកគេកំពុងរស់នៅ។

NLC និង NACPC ក៏កំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្ត និងការធ្វើមូលដ្ឋានីយកម្ម SDGs នៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ(សូមមើលរូបភាពទី១៥)។ យោងតាមផែនការយុទ្ធសាស្ត្រទីបីរបស់NLC(២០១៨-២០២២) យុទ្ធសាស្ត្របីក្នុងចំណោមយុទ្ធសាស្ត្រប្រាំពីរ គឺ សំដៅជំរុញការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តCSDGs នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រទាំងបីនោះ គឺ (១) ផ្តល់សេវាចាំបាច់បន្ថែមដល់ក្រុមប្រឹក្សាមូលដ្ឋានដើម្បីសម្រេចបានSDGs។ (២) ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់(LED) ដោយផ្តោតលើការប្រែប្រួលអាកាសធាតុ និង(៣) បញ្ជ្រាបស្ត្រីក្នុងនយោបាយមូលដ្ឋាន និងលើកកម្ពស់សង្គមប្រកបដោយបរិយាប័ន្ន។ រហូតមកដល់ពេលនេះ ទាំងNLC និងNACPC បានអនុវត្តគម្រោងថវិកាមួយចំនួនពីដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងអន្តរជាតិ ពីទីភ្នាក់ងារផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ដោយចាប់ដៃគូជាមួយរដ្ឋបាលរាជធានី-ខេត្ត និងMDK។ គម្រោងទាំងនោះត្រូវបានបង្កើតឡើងជាទូទៅដើម្បីកែលម្អរដ្ឋបាលថ្នាក់ក្រោមជាតិ និងកសាងសមត្ថភាពរបស់ពួក

គេ ដើម្បីធានាបាននូវ "សេវាសាធារណៈរួមបញ្ចូល" និង "មិនទុកឱ្យនរណាម្នាក់នៅពីក្រោយ" នៅក្នុងវិស័យរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់(LED) និងភាពជាអ្នកដឹកនាំរបស់ស្ត្រី (សូមមើលឧបសម្ព័ន្ធ ខ)។




**រូបភាពទី១៥ ៖ តួនាទីរបស់ NLC និង NACPC ក្នុងការធ្វើមូលដ្ឋានីយកម្ម CSDGs ថ្នាក់ក្រោមជាតិSNA**

## ៤.២. កិច្ចខិតខំប្រឹងប្រែង និងវិធីសាស្ត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តCSDGs

តាមចម្លើយស្ទង់មតិនេះ ៥៨% នៃរដ្ឋបាលថ្នាក់ក្រោមជាតិ បានបញ្ជាក់ថា ស្ថាប័ន/អង្គភាពរដ្ឋរបស់ពួកគេ(រដ្ឋាភិបាល) មានការប្តេជ្ញាចិត្តធ្វើមូលដ្ឋានីយកម្មCSDGs មួយចំនួន។ ដូចដែលបានបង្ហាញក្នុងរូបភាពទី១៦ តំបន់បឹងទន្លេសាបមានការប្តេជ្ញាចិត្តខ្ពស់បំផុតក្នុងចំណោមដទៃទៀតនៃប្រទេសកម្ពុជា (២៧% នៃរដ្ឋបាលថ្នាក់ក្រោមជាតិ) បន្ទាប់មក រដ្ឋបាលថ្នាក់ក្រោមជាតិមកពីតំបន់ទំនាបកណ្តាល (១៤%) និងតំបន់ឆ្នេរ និងសមុទ្រ(១១%)។







**រូបភាពទី១៦ ៖ ការប្តេជ្ញាចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធ្វើមូលដ្ឋានីយកម្មSDGs**

ក្នុងការស្វែងយល់ឱ្យកាន់តែស៊ីជម្រៅ អំពីកិច្ចខិតខំប្រឹងប្រែង និងវិធីសាស្ត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តCSDGs គេឃើញថា គោលដៅជាក់លាក់CSDGs ចំនួនប្រាំបីត្រូវបានពិភាក្សាយ៉ាងល្អិតល្អន់នៅក្នុងការសិក្សានេះ។ គោលដៅទាំងនោះផ្តោតជាសំខាន់លើវិធីសាស្ត្រ និងប្រធានបទដែលរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់ និង/ឬបានអនុវត្តដើម្បីសម្រេចបាននូវគោលដៅជាក់លាក់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយអាស្រ័យផងដែរទៅនឹងប្រភពមូលនិធិ។ ទោះជាយ៉ាងណាក៏ដោយ ការវិភាគនេះមិនគ្របដណ្តប់លើប្រសិទ្ធភាពនៃវិធីសាស្ត្រទាំងនោះទេ ដោយសារតែទិន្នន័យនៅមានដែនកំណត់។ ទោះយ៉ាងណាក៏ដោយ ឧបសម្ព័ន្ធ D បង្ហាញពីសូចនាករមួយភាគធំមានវឌ្ឍនភាពដោយថ្នាក់ជាតិបានធ្វើឡើង។

សម្រាប់ការធ្វើមូលដ្ឋានីយកម្មនៃCSDG១ ជំនួយសង្គមដែលពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុ និង/ឬជំនួយសាច់ប្រាក់ គឺជា វិធីសាស្ត្រដ៏ញឹកញាប់ ឬពេញនិយមបំផុតដើម្បីសម្រេចបាននូវគោលដៅ គ្មានភាពក្រីក្រដោយរដ្ឋបាលថ្នាក់ក្រោមជាតិ អមដោយការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ (ដូចជាគម្រោងផ្លូវ) កម្មវិធី ID Poor និងការគាំទ្រជនក្រីក្រនិងកសិករ ដូចជា ការយល់ដឹងជាសាធារណៈ ជំនួយស្បៀងអាហារ អាហារូបត្ថម្ភ អាហារូបករណ៍។ល។ (សូមមើលរូបទី១៧ និងប្រអប់ទី៥ និងទី៧ ក្នុងផ្នែកទី៤.៣)។ មានតែ ៥% នៃកម្មវិធី/គម្រោង/សកម្មភាពទាំងនោះប៉ុណ្ណោះដែលបញ្ជាក់ថា ជាកិច្ចសហការរួមគ្នារវាងរដ្ឋាភិបាល និងDAs/DP/NGOs។






**រូបភាពទី១៧ ៖ វិធីសាស្រ្តអនុវត្តមូលដ្ឋានីយកម្ម គោលដៅ ១**

ចំពោះការធ្វើមូលដ្ឋានីយកម្មនៃCSDG លេខ ៣ រដ្ឋបាលថ្នាក់ក្រោមជាតិភាគច្រើនបានផ្តោតលើការកែលម្អគុណភាពនៃសេវាសុខភាពសាធារណៈ រួមទាំងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បង្គន់សាធារណៈ ជំនួយហិរញ្ញវត្ថុ កម្មវិធីថែទាំកុមារ អាហារូបត្ថម្ភ មេរោគអេដស៍ ការឆ្លើយតបបន្ទាន់ និងការអនុវត្តច្បាប់។ល។ ខណៈពេលដែលការយល់ដឹងជាសាធារណៈ និងការមានគភ៌ និងកម្មវិធីថែទាំកុមារត្រូវបានដាក់នៅលំដាប់ទីពីរ និងទីបី( សូមមើលរូបភាពទី១៨ និងប្រអប់ទី៦ ក្នុងផ្នែកទី៤.៣)។ FCM, WaterAid និង Bread for the World (BFDW) ត្រូវបានរដ្ឋបាលថ្នាក់ក្រោមជាតិលើកឡើង ថាជាភ្នាក់ងារផ្តល់ជំនួយ និង/ឬអង្គការមិនមែនរដ្ឋាភិបាលសកម្មដែលកំពុងធ្វើការលើបញ្ហាជាច្រើន ហើយមានការគាំទ្រសកម្មភាព/កម្មវិធី/គម្រោងប្រមាណ១៤% នៃសកម្មភាព/កម្មវិធី/គម្រោងទាំងអស់។




**រូបភាពទី១៨ ៖ វិធីសាស្រ្តអនុវត្តមូលដ្ឋានីយកម្ម គោលដៅ ៣**

នៅក្នុងCSDG ៥៖ សមភាពយេនឌ័រ អ្នកឆ្លើយសំណួរបានបញ្ជាក់ថា ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ តាមរយៈសម្ភារៈជំនួយស្មារតី(IEC) ប្រព័ន្ធផ្សព្វផ្សាយសង្គម និងការអប់រំផ្ទាល់ គឺជាវិធីសាស្រ្តសំខាន់បំផុតដែលត្រូវបានអនុវត្ត ហើយការបញ្ជ្រាបយេនឌ័រ និងការពង្រឹងសិទ្ធិអំណាចស្ត្រី គឺជា

វិធីសាស្ត្រទីពីរដែលបានអនុវត្ត(រូបភាពទី១៩)។ វិធីសាស្ត្រទាំងពីរ គឺ ការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ និងការពង្រឹងសិទ្ធិអំណាចស្ត្រីត្រូវបានយកមកគិតគូខ្លាំង ហើយបានរំលេចនៅក្នុងសកម្មភាពភាគច្រើនដែលបានអនុវត្ត។ ទន្ទឹមនឹងនេះ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការកសាងសមត្ថភាពស្ត្រី និងកុមារីក៏ជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពមួយក្នុងការផ្តល់សិទ្ធិអំណាចដល់ពួកគេឱ្យក្លាយជាអ្នកដឹកនាំសេដ្ឋកិច្ចផងដែរ។ សកម្មភាពទាំងអស់នេះត្រូវបានចាត់ទុកថាជាការអនុវត្តCSDG ៥ (សូមមើលតារាងទី៥)។




**រូបភាពទី១៩ ៖ វិធីសាស្ត្រអនុវត្តមូលដ្ឋានីយកម្ម គោលដៅ ៥**

ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងទីក្រុង ត្រូវបានគេមើលឃើញថា ជាវិធីសាស្ត្រដ៏សំខាន់បំផុតដែលរដ្ឋបាលថ្នាក់ក្រោមជាតិកម្ពុជាបានយកចិត្តទុកដាក់ក្នុងការធ្វើមូលដ្ឋានីយកម្ម និងសម្រេចបាន CSDG ៦ បន្ទាប់មកគឺការផ្គត់ផ្គង់ទឹកជនបទ (ដូចជា ស្រះសហគមន៍ អណ្តូង ទំនប់ទឹក ធុងទឹក ទឹកភ្លៀង ប្រភពទឹកធន់នឹងអាកាសធាតុ។ល។) (សូមមើលរូបភាពទី២០)។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋបាលថ្នាក់ក្រោមជាតិក៏បានលើកកម្ពស់អនាម័យមនុស្ស អនាម័យសាធារណៈ និងការប្រើប្រាស់បង្គន់អនាម័យថាជារបៀបវារៈរបស់ពួកគេ ដើម្បីសម្រេចគោលដៅនេះ។ វាក៏មានការរួមចំណែកពីវិស័យឯកជនផងដែរ បើទោះបីជាវាមានទ្រង់ទ្រាយតូច(ត្រឹម១%) ក៏ដោយ ប៉ុន្តែវាត្រូវបានគេមើលឃើញតែនៅក្នុងគោលដៅនេះប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតDAs/DPs/NGOs ក្នុងស្រុក និងអន្តរជាតិជាច្រើនបានចូលរួមយ៉ាងសកម្មក្នុងគោលដៅនេះ រួមមាន EU, UNIDO, ADB, WB, JICA, WA, SNV, IFAD, EIB, WaterAid, WaterSHED, Plan International និង CAOD ។ ល។ (សូមមើលប្រអប់១, ៦ និង៧ ក្នុងផ្នែក៤.៣)។




## រូបភាពទី២០ ៖ វិធីសាស្ត្រអនុវត្តមូលដ្ឋានីយកម្ម គោលដៅ ៦

ថាមពលពន្លឺព្រះអាទិត្យបានក្លាយជាមធ្យោបាយឈានមុខគេក្នុងការដោះស្រាយបញ្ហាថាមពលស្អាត និងតម្លៃសមរម្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា(CSDG ៧)។ ពិសេសជាងនេះទៅទៀត រដ្ឋបាលថ្នាក់ក្រោមជាតិការដំឡើងភ្លើងបំភ្លឺផ្លូវដើរដោយថាមពលពន្លឺព្រះអាទិត្យសម្រាប់សាធារណៈជនប្រើប្រាស់(សូមមើលរូបភាពទី២១)។ ខណៈពេលជាមួយគ្នានេះ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធបណ្តាញក៏ត្រូវបានដាក់ក្នុងរបៀបវារៈតាមរយៈគម្រោងវិនិយោគរបស់វិស័យឯកជនផងដែរ។ ដើម្បីសម្រេចគោលដៅនេះ ការយល់ដឹងជាសាធារណៈ ការអនុវត្តច្បាប់ និងការកសាងសមត្ថភាពត្រូវបានអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជាផងដែរ។ (សូមមើលប្រអប់ ២ និង ៧ នៅក្នុងផ្នែក៤.៣)។




## រូបភាពទី២១ ៖ វិធីសាស្ត្រអនុវត្តមូលដ្ឋានីយកម្ម គោលដៅ ៧

កម្មវិធីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការបំប៉នសមត្ថភាព រួមទាំងការអនុវត្តច្បាប់ គឺជា វិធីសាស្រ្តឈានមុខគេដែលត្រូវបានអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ដើម្បីសម្រេច CSDG ១០ ៖ កាត់បន្ថយវិសមភាព។ ទន្ទឹមនឹងនោះ ការជួយសហគមន៍ក្រីក្រ តាមរយៈការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធធ្វើគមនាគមន៍សម្រាប់ទាំងអស់គ្នាក៏ជារបៀបវារៈសំខាន់មួយទៀតផងដែរ (សូមមើលរូបភាពទី២២)។ យ៉ាងណាក៏ដោយ វាគួរឱ្យចាប់អារម្មណ៍ដែលឃើញថា ការបញ្ជ្រាបយេនឌ័រ និងការពង្រឹងសិទ្ធិអំណាចស្ត្រី/ក្មេងស្រី ក៏ត្រូវបានប្រើប្រាស់ជាឧបករណ៍ដើម្បីកាត់បន្ថយវិសមភាពដោយរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ WaterAid, GIZ និង GAD-C គឺជា អង្គការមិនមែនរដ្ឋាភិបាលសកម្មមួយ ដែលបាននិងកំពុងធ្វើការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសម្រេចគោលដៅនេះ។ (សូមមើលប្រអប់ទី២, ៣, ៤ និង ៧ នៅក្នុងផ្នែក៤.៣)។




**រូបភាពទី២២ ៖ វិធីសាស្រ្តអនុវត្តមូលដ្ឋានីយកម្ម គោលដៅ ១០**

វិធីសាស្រ្តអន្តរវិស័យផ្សេងៗគ្នាជាច្រើនត្រូវបានប្រើប្រាស់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសម្រេចCSDG ១១ ៖ទីក្រុង និងសហគមន៍ប្រកបដោយនិរន្តរភាព។ ការងារពេញនិយមបំផុត គឺ ការគ្រប់គ្រង និងការកែលម្អបរិស្ថានទីក្រុង ដែលរួមមានការអនុវត្តច្បាប់ ការគ្រប់គ្រងកាកសំណល់ និងការគ្រប់គ្រងកន្លែងចាក់សំរាម។ល។(សូមមើលរូបភាពទី២៣)។ បន្ថែមពីលើនោះ ក៏មានកម្មវិធីដែលហៅថា "កម្មវិធីគំនិតផ្តួចផ្តើមបៃតង" ដែលត្រូវបានរៀបចំឡើងសម្រាប់ក្រុងទាំងអស់ក្នុងប្រទេសកម្ពុជា ដើម្បីប្រកួតប្រជែងដណ្តើមពានរង្វាន់ជាតិ និងអន្តរជាតិ ដូចជា ពានរង្វាន់ទីក្រុងទេសចរណ៍ស្អាតកម្ពុជា និងអាស៊ាន ជាដើម។ ទោះជាយ៉ាងណាក៏ដោយ ការចូលរួមរបស់សហគមន៍ និងការអភិវឌ្ឍន៍សហគមន៍ក្នុងទម្រង់ DMO, CBET និង NRM ក៏ត្រូវបានរកឃើញថាមានតិចតួចបំផុត។ ជាចុងក្រោយ អ្វីដែលគួរឱ្យចាប់អារម្មណ៍ខ្លាំង គឺ ឃើញថាមានតួអង្គសំខាន់ៗជាច្រើនបានចូលរួមចំណែកក្នុងវិស័យនេះ រួមមាន ADB, USAID, GIZ, WCS, WA, DANIDA និង API ។ (សូមមើលប្រអប់ ១, ២ និង៤ នៅក្នុងផ្នែក ៤.៣)។




**រូបភាពទី២៣ ៖ វិធីសាស្រ្តអនុវត្តមូលដ្ឋានីយកម្ម គោលដៅ ១១**

មានគំនិតផ្តួចផ្តើមពីរចំបង គឺ (១) គំនិតផ្តួចផ្តើមបៃតងប្រកបដោយនិរន្តរភាព និង (២) ការកសាងភាពធន់នឹងអាកាសធាតុ និងកសិកម្មឆ្លាតវៃ គឺជា វិធីសាស្រ្តពេញនិយមបំផុតដែលត្រូវបានណែនាំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសម្រេចCSDG ១៣(សូមមើលរូបភាពទី២៤)។ តាមពិត មានទម្រង់ជាច្រើននៃគំនិតផ្តួចផ្តើមបៃតងប្រកបដោយនិរន្តរភាព ដូចជាNRM គម្រោងREDD+ ការដាំដើមឈើលើកកម្ពស់ថាមពលកកើតឡើងវិញ និងគំនិតផ្តួចផ្តើមផ្សេងៗទៀត។ សកម្មភាពទប់ស្កាត់គ្រោះមហន្តរាយ និងការឆ្លើយតបពេលមានអាសន្ន(ឧ.EWS) ការយល់ដឹងជាសាធារណៈ និងការអនុវត្តច្បាប់ ក៏ត្រូវបានលើកយកមកពិចារណាដោយរដ្ឋបាលថ្នាក់ក្រោមជាតិដែរ។ WB, ADB, WCS, USAID, World Vision និង API ត្រូវបានគេចាត់ទុកជាតួអង្គសំខាន់ក្នុងគោលដៅនេះ។ (សូមមើលប្រអប់ទី៧ នៅក្នុងផ្នែក៤.៣)។




**រូបភាពទី២៤ ៖ វិធីសាស្រ្តអនុវត្តមូលដ្ឋានីយកម្ម គោលដៅ ១៣**

សរុបមក គេអាចនិយាយបានថា មានវិធីសាស្ត្រទូលំទូលាយមួយចំនួន ដែលរដ្ឋបាលថ្នាក់ក្រោមជាតិ បានអនុវត្តក្នុងប្រទេសកម្ពុជា ហើយវិធីសាស្ត្រទាំងអស់នោះអាចអនុវត្តបានចំពោះគោលដៅទាំងអស់ គឺ កម្មវិធីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការកសាងសមត្ថភាព។ ខណៈពេលដែលការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក៏បានរួមវិភាគទានដល់ការសម្រេចគោលដៅជាច្រើនផងដែរ។ ទោះយ៉ាងណាក៏ដោយ នៅក្នុងករណីជាច្រើន វានៅមានដែនកំណត់នៃការចូលរួមជាលក្ខណៈបុគ្គល និងការរួមចំណែករបស់វិស័យឯកជនក្នុងការសម្រេចគោលដៅ ។ រហូតមកដល់ពេលនេះ គេឃើញការចូលរួមពីវិស័យឯកជនមានតែក្នុងគោលដៅទី៦ និង១១ ប៉ុណ្ណោះ។

**តារាងទី៥ ៖ សកម្មភាពកម្មវិធីដែលបានអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ តាមCSDGs**

| គោលដៅ | ល.រ | សកម្មភាពកម្មវិធីទទួលបាន | ភាគរយ |
|---|---|---|---|
| គោលដៅ១ ៖ កាត់បន្ថយភាពក្រីក្រ | 1 | វគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ | 7% |
| | 2 | ជំនួយសង្គម | 31% |
| | 3 | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | 23% |
| | 4 | កម្មវិធីកំណត់អត្តសញ្ញាណភាពក្រីក្រ | 12% |
| | 5 | គាំទ្រអ្នកក្រ និងកសិករ (ការផ្សព្វផ្សាយ ចំណីអាហារ អាហារូបត្ថម្ភ) | 11% |
| | 6 | ជំនាញកសិកម្ម | 11% |
| | 7 | ផ្សេងៗ | 4% |
| គោលដៅ៣ ៖ សុខភាពល្អ និងសុខមាលភាព | 1 | ការកែលម្អគុណភាពសេវាសុខាភិបាលសាធារណៈ | 37% |
| | 2 | ការអប់រំផ្សព្វផ្សាយសាធារណៈពីការថែទាំសុខភាព | 24% |
| | 3 | កម្មវិធីថែទាំស្ត្រីមានផ្ទៃពោះ ការពិគ្រោះយោបល់ បញ្ចប់អំពើហឹង្សា កញ្ចប់ជំនួយ | 22% |
| | 4 | យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ១៩ | 17% |
| គោលដៅ៥ ៖ សមធម៌យេនឌ័រ | 1 | ការអប់រំផ្សព្វផ្សាយសាធារណៈ | 35% |
| | 2 | ការបញ្ជ្រាបយេនឌ័រ ការផ្ដល់អំណាចដល់ស្ត្រី (ការចូលរួមរបស់ស្ត្រី និងយន្តការស្ថាប័ន) | 24% |
| | 3 | ការកសាងសមត្ថភាព វគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈ ការលើកកម្ពស់ជីវភាពគ្រួសារ | 18% |
| | 4 | ការបញ្ចប់អំពើហឹង្សា ការជំរុញការអនុវត្តច្បាប់ ការទប់ស្កាត់ការជួញដូរមនុស្ស ការឆ្លើយតបបន្ទាន់ | 17% |
| | 5 | ផ្សេងៗ (សុខភាពសាធារណៈ សេវាពិគ្រោះយោបល់) | 5% |
| គោលដៅ៦ ៖ ទឹកស្អាត និងអនាម័យ | 1 | ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន | 33% |
| | 2 | កែលម្អប្រភពទឹកជនបទ (ស្រះសហគមន៍ អណ្ដូងទឹក) | 28% |
| | 3 | ការលើកកម្ពស់អនាម័យ បង្គន់អនាម័យ ការប្រើប្រាស់បង្គន់ | 14% |
| | 4 | ការអប់រំផ្សព្វផ្សាយសាធារណៈ | 11% |

| គោលដៅ | ល.រ | សកម្មភាពកម្មវិធីទទួលបាន | ភាគរយ |
|---|---|---|---|
| | 5 | ការគ្រប់គ្រងបរិស្ថានទីប្រជុំជន និងជនបទ | 8% |
| | 6 | ការគ្រប់គ្រងគុណភាពទឹកប្រើប្រាស់ | 6% |
| គោលដៅ៧ ៖ ថាមពលកកើតឡើងវិញមានតម្លៃសមរម្យ | 1 | ថាមពលសូឡា (សូឡាបំភ្លឺតាមផ្លូវ) | 36% |
| | 2 | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធអគ្គីសនី (រដ្ឋ ឯកជន) | 28% |
| | 3 | ការអប់រំផ្សព្វផ្សាយសាធារណៈ ការជំរុញការអនុវត្តច្បាប់ និងការកសាងសមត្ថភាព | 18% |
| | 4 | ការពង្រីកបណ្តាញអគ្គីសនីនៅទីជនបទ | 13% |
| | 5 | ការសាងសង់វារីអគ្គីសនី | 5% |
| គោលដៅ១០ ៖ កាត់បន្ថយវិសមភាព | 1 | ការអប់រំផ្សព្វផ្សាយសាធារណៈ និងការកសាងសមត្ថភាព (ការជំរុញការអនុវត្តច្បាប់) | 57% |
| | 2 | ជួយប្រជាពលរដ្ឋ និងសហគមន៍ក្រីក្រ (ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ក្នុងមូលដ្ឋាន) | 19% |
| | 3 | ជំនួយសង្គ្រោះបន្ទាន់ និងជំនួយសាច់ប្រាក់ដល់អ្នកក្រ | 14% |
| | 4 | ការបញ្ជ្រាបយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី | 11% |
| គោលដៅ១១ ៖ និរន្តរភាពទីក្រុង និងសហគមន៍ | 1 | កម្មវិធីគំនិតផ្តួចផ្តើមបៃតង (កម្មវិធីទីក្រុងស្អាត) | 23% |
| | 2 | ការអប់រំផ្សព្វផ្សាយសាធារណៈ ការលើកកម្ពស់ជីវភាពគ្រួសារ ការដោះស្រាយវិវាទដីធ្លី | 20% |
| | 3 | ការកែលម្អការគ្រប់គ្រងបរិស្ថានទីក្រុង | 31% |
| | 4 | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង (សួនច្បារ ផ្លូវថ្នល់) | 13% |
| | 5 | កម្មវិធីអភិវឌ្ឍន៍សហគមន៍ (មូលនិធិសហគមន៍ ការគ្រប់គ្រងធនធានធម្មជាតិសហគមន៍។ល។) | 13% |
| គោលដៅ១៣ ៖ សកម្មភាពក្នុងបម្រែបម្រួលអាកាសធាតុ | 1 | ការទប់ស្កាត់គ្រោះមហន្តរាយ និងការឆ្លើយតបបន្ទាន់ | 21% |
| | 2 | ការបន្សាំនឹងបម្រែបម្រួលអាកាសធាតុ និងការធ្វើកសិកម្មឆ្លាតវៃ | 23% |
| | 3 | គំនិតផ្តួចផ្តើមទីក្រុងបៃតងដែលមាននិរន្តរភាព និងការគ្រប់គ្រងធនធានធម្មជាតិ | 23% |
| | 4 | ការអប់រំផ្សព្វផ្សាយសាធារណៈ និងការជំរុញការអនុវត្តច្បាប់ | 19% |
| | 5 | ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ រួមទាំងជំនួយស្បៀងអាហារ កញ្ចប់សាច់ប្រាក់ដល់ជនរងគ្រោះនិងជនរងផលប៉ះពាល់ | 14% |

## ៤.៣. វឌ្ឍនភាពនៃការអនុវត្តគោលដៅចំបងៗ

ដូចដែលបានបង្ហាញនៅក្នុងផ្នែកមុនៗ រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗគ្នាកំពុងខិតខំប្រឹងប្រែងដើម្បីបន្សុំផែនការ និងគម្រោងរបស់ពួកគេជាមួយCSDGs។ វិធីសាស្រ្តផ្សេងៗ និងការអនុវត្តប្រកបដោយភាពច្នៃប្រឌិត ត្រូវបានធ្វើឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធ្វើមូលដ្ឋានីយកម្មនៃCSDGs ពីខេត្តមួយទៅក្រុងមួយទៀត ដូច្នេះការវិវឌ្ឍន៍ក៏ត្រូវបានគេមើលឃើញក្នុងកម្រិតផ្សេងៗគ្នាផងដែរ។ អ្នកឆ្លើយសំណួរបានចាត់ទុកថា គោលដៅចំនួន៤ មានការរីកចម្រើនខ្លាំងនៅក្នុងក្រុមA ខណៈពេលដែលក្រុមB ចាត់ទុកថាមានវឌ្ឍនភាពខ្ពស់ដូចគ្នានៃគោលដៅចំនួន៣ ហើយក្រុមC បានចាត់ទុកថាគោលដៅចំនួន៤ មានការរីកចម្រើនក្នុងកម្រិតមធ្យម និង គោលដៅ៤ ទៀត មានកម្រិតទាប(សូមមើលតារាងទី៦)។

**តារាងទី៦ ៖ វឌ្ឍនភាពនៃមូលដ្ឋានីយកម្មCSDGs ទាំង៨ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

| ល.រ | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា | គំនិតផ្តួចផ្តើម | | |
|---|---|---|---|---|
| | | ក្រុម A | ក្រុម B | ក្រុម C |
| 1 | គោលដៅ១ ៖ កាត់បន្ថយភាពក្រីក្រ | ខ្ពស់ | មធ្យម | ទាប |
| 2 | គោលដៅ៣ ៖ សុខភាពល្អ និងសុខមាលភាព | មធ្យម | មធ្យម | ទាប |
| 3 | គោលដៅ៥ ៖ សមធម៌យេនឌ័រ | ខ្ពស់ | ខ្ពស់ | ទាប |
| 4 | គោលដៅ៦ ៖ ទឹកស្អាត និងអនាម័យ | មធ្យម | មធ្យម | មធ្យម |
| 5 | គោលដៅ៧ ៖ ថាមពលកកើតឡើងវិញមានតម្លៃសមរម្យ | មធ្យម | មធ្យម | មធ្យម |
| 6 | គោលដៅ១០ ៖ កាត់បន្ថយវិសមភាព | មធ្យម | មធ្យម | ទាប |
| 7 | គោលដៅ១១ ៖ និរន្តរភាពទីក្រុង និងសហគមន៍ | ខ្ពស់ | ខ្ពស់ | មធ្យម |
| 8 | គោលដៅ១៣ ៖ សកម្មភាពក្នុងបម្រែបម្រួលអាកាសធាតុ | ខ្ពស់ | ខ្ពស់ | មធ្យម |

***ចំណាំ*** *៖ វឌ្ឍនភាពត្រូវបានគណនាដោយផ្អែកលើចំនួន PPAs ៖ (១) ខ្ពស់ = យ៉ាងហោចណាស់ 100 PPAs; (២) មធ្យម = ចន្លោះពី 50-100 PPAs; និង (៣) ទាប = តិចជាង 50 PPAs*

- *ក្រុម A= គំនិតផ្តួចផ្តើមធ្វើឡើងដោយ CP/MDK ក្រោមការគាំទ្រផ្នែកហិរញ្ញវត្ថុ និង/ឬបច្ចេកទេសពីរដ្ឋាភិបាលជាតិ។*
- *ក្រុម B = គំនិតផ្តួចផ្តើមធ្វើឡើងដោយ CP/MDK ក្រោមជំនួយផ្នែកហិរញ្ញវត្ថុ និង/ឬបច្ចេកទេសពី DP/DA ឬ NGOs ។*
- *ក្រុម C= គំនិតផ្តួចផ្តើមធ្វើឡើងដោយវិស័យឯកជនក្នុងភាពជាដៃគូជាមួយ CP/MDK*

និយាយឱ្យកាន់តែជាក់លាក់ អំពីវឌ្ឍនភាព និងសមិទ្ធផលសំខាន់ៗមួយចំនួនដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានធ្វើមូលដ្ឋានីយកម្មCSDGs ករណីសិក្សាចំនួនប្រាំពីរផ្សេងគ្នាត្រូវបានជ្រើសរើស។ ដំណើរការជ្រើសរើស គឺ ផ្អែកលើផលប៉ះពាល់ជាសក្តានុពលរបស់គម្រោងក្នុងការសម្រេចCSDGs ព្រមទាំងសក្តានុពលក្នុងការពង្រីកវិសាលភាព និងការអនុវត្តប្រកបដោយភាពច្នៃប្រឌិត ព្រមទាំងសារៈសំខាន់នៃការចូលរួមរបស់វិស័យឯកជន ។

## ៤.៤. គោលដៅអាទិភាពទាំងដប់សម្រាប់អនុវត្តក្រោយវិបត្តិ Covid-19

ផ្អែកលើទស្សនៈរបស់អ្នកឆ្លើយសំណួរSDGs ចំនួនប្រាំមួយក្នុងចំណោមSDGs ចំនួនដប់ត្រូវបានផ្តល់អាទិភាពសម្រាប់ការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្ត ក្រោយវិបត្តិCovid-19។ SDG#១: ការកាត់បន្ថយភាពក្រីក្រ, SDG#៣: សុខភាពល្អ និងសុខុមាលភាព, SDG#៤: ការអប់រំប្រកបដោយគុណភាព, SDG#៨: ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច, SDG#៦: ទឹកស្អាត និងអនាម័យ និង SDG#៩: ឧស្សាហកម្ម, ការច្នៃប្រឌិត និងហេដ្ឋារចនាសម្ព័ន្ធ នៅតែជាអាទិភាពខ្ពស់ក្នុងចំណោមដប់ (សូមមើលរូបភាពទី២៥)។ ដូចគ្នានេះដែរ តារាងទី៧ ខាងក្រោមកំពុងបង្ហាញពីSDGs អាទិភាពតាមតំបន់។ តំបន់ទន្លេសាបជាប់ចំណាត់ថ្នាក់អាទិភាពខ្ពស់ស្ទើរតែគ្រប់SDGs។ ទិន្នន័យនេះបញ្ជាក់ថា កិច្ចខិតខំប្រឹងប្រែងជាច្រើនទៀតត្រូវតែធ្វើឡើងក្នុងតំបន់នោះ។ ទោះជាយ៉ាងណាក៏ដោយSDG#១ នៅតែជាចំណុចផ្តោតសំខាន់នៅគ្រប់តំបន់ទាំងអស់សម្រាប់ពេលក្រោយវិបត្តិCovid-19 បន្ទាប់មក SDG#៣, SDGs#៤ និងSDG#៨។




**រូបភាពទី២៥ ៖ គោលដៅអាទិភាពទាំង១០ ក្រោយវិបត្តិកូវី១៩**

## តារាងទី៧ ៖ ការចាត់អាទិភាពគោលដៅសំខាន់ៗទាំង១០ (១ដល់១៨) សម្រាប់ផ្តោតការយកចិត្តទុកដាក់ខ្លាំង នៅក្រោយវិបត្តិ កូវីដ១៩

| អាទិភាព តាមតំបន់ | | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 |
| អាទិភាព ១ | តំបន់ទំនាបកណ្តាល | 6 | | | | | | | | | | | | | | | | | |
| | តំបន់ឆ្នេរសមុទ្រ | 7 | | 2 | 1 | | 1 | | | 1 | | | | | | | 1 | | |
| | តំបន់ខ្ពង់រាប | 5 | 1 | | | | 1 | | | | | | | | | | | | |
| | តំបន់ទន្លេសាប | 12 | | 3 | 3 | | 1 | | | | | | | | | | 3 | | |
| អាទិភាព ២ | តំបន់ទំនាបកណ្តាល | | 4 | 5 | | | | | 1 | | | | | | | | | | |
| | តំបន់ឆ្នេរសមុទ្រ | 1 | 4 | 3 | | | | 3 | | | | 1 | | | | | | 1 | |
| | តំបន់ខ្ពង់រាប | | | 5 | 2 | | | | | | | | | | | | | | |
| | តំបន់ទន្លេសាប | 2 | 6 | 6 | | | | | 1 | 1 | | | | | | | | 1 | |
| អាទិភាព ៣ | តំបន់ទំនាបកណ្តាល | | | | 1 | | | | 4 | 1 | | | | | | | | | |
| | តំបន់ឆ្នេរសមុទ្រ | | | 1 | 3 | | 3 | 1 | 2 | | | | | | | | | 1 | |
| | តំបន់ខ្ពង់រាប | | | 2 | 2 | | 1 | | | | | | | | | | | 1 | |
| | តំបន់ទន្លេសាប | 1 | 3 | 4 | 5 | 3 | | | 1 | 1 | | | | 1 | | | | | |
| អាទិភាព ៤ | តំបន់ទំនាបកណ្តាល | | | 1 | 3 | 1 | | | | 1 | | | | | | | | | |
| | តំបន់ឆ្នេរសមុទ្រ | | | 2 | 4 | 2 | | | 3 | | | | | 1 | | | | | |
| | តំបន់ខ្ពង់រាប | | | | | 2 | 1 | | 2 | | | 1 | | | | | | | |
| | តំបន់ទន្លេសាប | | 1 | | 7 | 3 | 2 | 1 | 3 | | 1 | | 1 | | | | | | |
| អាទិភាព ៥ | តំបន់ទំនាបកណ្តាល | | | | 1 | 3 | 2 | | | | | | | | | | | | |
| | តំបន់ឆ្នេរសមុទ្រ | | 1 | 2 | | | 2 | | 6 | 2 | | | 1 | | | | | | |
| | តំបន់ខ្ពង់រាប | | | | | | 3 | | 1 | | 1 | | | 1 | | | | | |
| | តំបន់ទន្លេសាប | | 1 | 1 | 5 | 2 | 5 | 2 | 2 | | | | | | | | | | |
| អាទិភាព ៦ | តំបន់ទំនាបកណ្តាល | | | | | | 4 | | 1 | | | | | 1 | | | | | |
| | តំបន់ឆ្នេរសមុទ្រ | | | 3 | 1 | | 2 | 4 | | | | 1 | | 1 | | | | 1 | |
| | តំបន់ខ្ពង់រាប | | | | | 2 | | 2 | | | 1 | 1 | | | | | | | |
| | តំបន់ទន្លេសាប | | 1 | 2 | 1 | 1 | 5 | 3 | 2 | 1 | 1 | | | 1 | | | 1 | | |

| អាទិភាព តាមតំបន់ | | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 |
| អាទិភាព ៧ | តំបន់ទំនាបកណ្ដាល | | | | 1 | 1 | | | | 1 | | 3 | | | | | | | |
| | តំបន់ឆ្នេរសមុទ្រ | 1 | | | | 3 | | 3 | 1 | 1 | | 2 | | 1 | | | 1 | | |
| | តំបន់ខ្ពង់រាប | 2 | | | 1 | | | | 1 | | | | | | | | 1 | 1 | |
| | តំបន់ទន្លេសាប | | | 1 | 1 | | 3 | 1 | 3 | 2 | 2 | 1 | | 1 | | | 1 | 1 | |
| អាទិភាព ៨ | តំបន់ទំនាបកណ្ដាល | | | | | | | 1 | | 3 | | 1 | | | | 1 | | | |
| | តំបន់ឆ្នេរសមុទ្រ | 2 | 1 | | | | 1 | 1 | 1 | 1 | 1 | 1 | 3 | | | 1 | | | |
| | តំបន់ខ្ពង់រាប | | | | | | | | | 2 | | | | 1 | | | | 3 | |
| | តំបន់ទន្លេសាប | | 1 | | | | | 1 | 4 | 4 | | 1 | | 2 | | | 2 | 2 | 1 |
| អាទិភាព ៩ | តំបន់ទំនាបកណ្ដាល | | | | | | | 3 | | | | | 1 | | 1 | | | 1 | |
| | តំបន់ឆ្នេរសមុទ្រ | 1 | | | | 1 | 2 | | | 3 | 1 | 1 | | 2 | | | 1 | | |
| | តំបន់ខ្ពង់រាប | | | | | | | 1 | 1 | 2 | | | | 1 | | | | | 1 |
| | តំបន់ទន្លេសាប | 1 | | | | 2 | | | | 1 | 4 | 1 | 2 | 1 | | | 3 | 2 | |
| អាទិភាព ១០ | តំបន់ទំនាបកណ្ដាល | | | | | | | | | | | | 3 | | 1 | 1 | | | 1 |
| | តំបន់ឆ្នេរសមុទ្រ | | | | 2 | 1 | | | | 1 | 3 | | | 1 | | | 1 | 1 | 1 |
| | តំបន់ខ្ពង់រាប | 1 | | | | | | | | 2 | | | | | | | 2 | 1 | |
| | តំបន់ទន្លេសាប | 1 | 1 | | | 2 | | | | 1 | 1 | 1 | 1 | | | | 2 | 5 | 2 |
| | | 43 | 25 | 43 | 44 | 29 | 39 | 27 | 40 | 32 | 16 | 16 | 12 | 16 | 2 | 3 | 19 | 22 | 6 |

## ប្រអប់ទី១ ៖ គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ទីក្រុងឆ្លាតវៃ នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង




**ប្រវត្តិ៖** ខេត្តបាត់ដំបង គឺជាខេត្តធំទីពីររបស់ប្រទេសកម្ពុជា ដែលមានទីតាំងនៅភាគពាយព្យនៃប្រទេសកម្ពុជា ចម្ងាយប្រហែល៣០០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។ ខេត្តនេះមានទីក្រុងមួយហៅថា ក្រុងបាត់ដំបង ដែលមានប្រជាជនរស់នៅសរុបប្រមាណ ១៥២.០៣២នាក់ និងមានផ្ទៃដីសរុប ១១៥.៤៤ គីឡូម៉ែត្រក្រឡា (១.៣១៧នាក់/គ.ម២)។ ទីក្រុងនេះត្រូវបានគេស្គាល់ថាជាមជ្ឈមណ្ឌលផលិតកម្មស្រូវ និងជាទីក្រុងស្ថាបត្យកម្មបារាំងដែលមានបរិយាកាសរស់នៅល្អ។



ទីក្រុងបាត់ដំបងមានការរីកចម្រើនមិនគួរឱ្យជឿក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ដោយផ្ទៃដីសាងសង់ក្នុងទីក្រុងបានពង្រីកពីប្រមាណ១.៥០០ហិកតា ក្នុងឆ្នាំ១៩៩០ ដល់ជាង៤.៥០០ហិកតា ក្នុងឆ្នាំ២០១៦។ នគរូបនីយកម្មយ៉ាងឆាប់រហ័សនាំមកឱ្យទីក្រុងនេះទាំងឱកាស និងបញ្ហាប្រឈម ជាពិសេសផែនការប្រើប្រាស់ដីក្នុងទីក្រុង។ ជាលទ្ធផល ក្នុងឆ្នាំ២០១៥ ខេត្តបាត់ដំបងបានបង្កើតផែនការមេការប្រើប្រាស់ដីធ្លីឆ្នាំ២០៣០ ដើម្បីធ្វើជាក្របខ័ណ្ឌមគ្គុទ្ទេស និងជាចក្ខុវិស័យអភិវឌ្ឍន៍។ ផែនការមេមានគោលដៅយុទ្ធសាស្ត្រមួយចំនួន ដូចខាងក្រោម ៖

- នៅឆ្នាំ២០២៥ ៖ យ៉ាងហោចណាស់យុវជន ២៨០០នាក់ទទួលបានជំនាញការងារជាក់លាក់
- នៅឆ្នាំ២០២៥ ៖ 50% នៃអ្នកលក់ដូរតាមដងផ្លូវបានផ្លាស់ប្តូរទៅហាងលក់និងទីផ្សារាយផ្លូវការ
- នៅឆ្នាំ២០២៥ ៖ យ៉ាងហោចណាស់ការតាំងទីលំនៅមិនផ្លូវការចំនួនបី ត្រូវបានស្តារឡើងវិញ និងធ្វើឱ្យទៅជាលំនៅដ្ឋានផ្លូវការ
- នៅឆ្នាំ២០២៥ ៖ ធ្វើការអភិវឌ្ឍប្រព័ន្ធលូក្នុងទីក្រុង
- នៅឆ្នាំ២០២៥ ៖ សាងសង់រោងចក្រប្រព្រឹត្តកម្មទឹកសំណល់ចំនួនពីរ

• នៅឆ្នាំ២០២៥ ៖ ៨៥% នៃការតាំងទីលំនៅរបស់អ្នកទីក្រុងត្រូវបានគ្របដណ្ដប់ដោយប្រព័ន្ធលូ

• ផ្លូវក្រាលកៅស៊ូសរុបក្នុងទីក្រុងត្រូវបានបង្កើនពី១៧% ក្នុងឆ្នាំ២០១៦ ដល់៤០% នៅឆ្នាំ២០២៥

ម្យ៉ាងវិញទៀត ផែនការមេបានផ្ដោតលើសសរស្ដម្ភពីរ៖

♣ សសរស្ដម្ភទី១៖ ការគ្រប់គ្រងផ្លូវទីក្រុង និងទីសាធារណៈ ៖ ដើម្បីកែលម្អបរិយាកាសរស់នៅ រដ្ឋបាលខេត្តបាត់ដំបងគ្រោងនឹងធ្វើឱ្យប្រសើរឡើងនូវការរចនាផ្លូវសាធារណៈ និងទីធ្លា (ឧ.កែលម្អសួនច្បារសាធារណៈថ្មី តាមដងស្ទឹង និងដាំដើមឈើ) រៀបចំអ្នកលក់ដូរតាមដងផ្លូវ និង ធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធកាន់តែប្រសើរសម្រាប់អ្នកតាំងលំនៅមិនផ្លូវការ។ ការងារទាំងនេះនឹងធ្វើឡើងតាមរយៈការអភិវឌ្ឍន៍ទីផ្សារ លំនៅដ្ឋានតម្លៃទាប និងការលើកកម្ពស់ជំនាញ។


គម្រោងសួនឧទ្យានសាធារណៈសម្ដេចក្រឡាហោម


ផ្សាររាត្រី និងវិថីអាហារ




ផ្លូវទីក្រុងនៅពេលថ្ងៃ និងពេលយប់

♣ សសរស្ដម្ភទី២៖ ការគ្រប់គ្រងសំណល់រឹង និងរាវ ៖ បាត់ដំបងប្រាថ្នាចង់ក្លាយជាទីក្រុងបៃតង និងមានផាសុកភាពល្អ។ វានឹងផ្លាស់ប្ដូរពីការគ្រប់គ្រងសំណល់រាវតាមដងស្ទឹងធម្មជាតិ ទៅជាប្រព័ន្ធគ្រប់គ្រងទឹកស្អុយ និងទឹកសំណល់។ ការងាររៀបចំប្រព័ន្ធលូកំពុងដំណើរការដោយរដ្ឋបាលខេត្តបាត់ដំបង គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី(ADB)។






រហូតមកដល់ពេលនេះ មានតែខេត្តចំនួន២ និងរាជធានីមួយប៉ុណ្ណោះ ដែលមានគំនិតផ្តួចផ្តើមទីក្រុងឆ្លាតវៃបែបនេះនៅក្នុងប្រទេសកម្ពុជា។ ក្នុងការធ្វើបច្ចុប្បន្នភាពចុងក្រោយលើផែនការមេរយៈពេល៥ឆ្នាំ ខេត្តមានចក្ខុវិស័យកាន់តែច្បាស់ក្នុងការអភិវឌ្ឍន៍ក្រុងបាត់ដំបងឱ្យក្លាយជាទីក្រុងឆ្លាតវៃមួយក្នុងប្រទេសកម្ពុជា តាម

រយៈការរួមបញ្ចូលបច្ចេកវិទ្យាទំនើប និងផែនការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយតុល្យភាព ធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ច និរន្តរភាពបរិស្ថាន និងថែរក្សាអត្តសញ្ញាណវប្បធម៌។ នៅឆ្នាំ២០២២ បាត់ដំបងជាទីក្រុងមួយក្នុងចំណោមទីក្រុងចំនួន៣ ក្នុងប្រទេសកម្ពុជា និងក្នុងចំណោមទីក្រុងចំនួន១៨ ផ្សេងទៀតក្នុងតំបន់ ដែលបានទទួលពានរង្វាន់ ជាទីក្រុងទេសចរណ៍ស្អាតអាស៊ាន ២០២២-២០២៤។

**ប្រភព៖** ដោយអ្នកសរសេររបាយការណ៍

## ប្រអប់ទី២ ៖ គំនិតផ្តួចផ្តើមសហគមន៍ស្អាត និងនិរន្តរភាពបៃតង នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប






**ប្រវត្តិ៖** ស្រុកបន្ទាយស្រី ស្ថិតនៅក្នុងខេត្តសៀមរាប (ប្រាសាទអង្គរវត្ត ដែលជាបេតិកភណ្ឌពិភពលោក) និងមានចម្ងាយប្រហែល៤០គីឡូម៉ែត្រពីមជ្ឈមណ្ឌលក្រុងសៀមរាប។ ស្រុកនេះមានផ្ទៃដីសរុប៦០០គីឡូម៉ែត្រក្រឡា និងមានប្រជាពលរដ្ឋប្រមាណ៤៣.៧៣៨ (១០.១៣០គ្រួសារ) ឃុំ០៦ និងភូមិ៣៦។ ស្រុកបន្ទាយស្រីមានវប្បធម៌ប្លែកពីគេ ហើយវាមានអត្ថប្រយោជន៍យ៉ាងធំធេងដោយសារមានតំបន់ទេសចរណ៍ពេញនិយមជាច្រើន រួមមានប្រាសាទបន្ទាយស្រី ប្រាសាទបន្ទាយសំរ៉ែ ភូមិព្រះដាក និងឧទ្យានជាតិភ្នំគូលែន។ ហើយប្រជាជនភាគច្រើនពឹងផ្អែកលើវិស័យទេសចរណ៍ជាងវិស័យកសិកម្ម។

រដ្ឋបាលស្រុកបានមើលឃើញទាំងបញ្ហាប្រឈម និងទាំងឱកាសក្នុងពេលតែមួយសម្រាប់ការអភិវឌ្ឍន៍រយៈពេលវែងនៅក្នុងស្រុកនេះ តាមរយៈការធ្វើសមាហរណកម្មទេសចរណ៍ និងកសិកម្ម ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ បន្ទាប់មក រដ្ឋបាលបានចាប់ផ្តើមជាមួយនឹងគំនិតផ្តួចផ្តើមសំខាន់ៗមួយចំនួន ដោយផ្តោតលើវិធីសាស្ត្រប្រជាពលរដ្ឋជាមជ្ឈមណ្ឌល ឬគំនិតផ្តួចផ្តើមផ្តោតលើភាពជាម្ចាស់សហគមន៍។ គំនិតផ្តួចផ្តើមជោគជ័យមួយចំនួនត្រូវបានផ្តល់ជូនខាងក្រោម ៖

(i) ការដំឡើងភ្លើងបំភ្លឺផ្លូវដើរ ដោយថាមពលពន្លឺព្រះអាទិត្យសម្រាប់ផ្ទះនីមួយៗនៅក្នុងភូមិ ព្រះដាក ក្រោមគម្រោងដែលគេហៅថា "ផ្ទះមួយ អំពូលមួយ" (CSDG ៣, ៧, ១០, ១១, & ១៣)។ គំនិតផ្តួចផ្តើមនេះបានដោះស្រាយបញ្ហាសំខាន់ពីរ គឺ សុវត្ថិភាពចរាចរណ៍ផ្លូវគោក និងសុវត្ថិភាពសម្រាប់អ្នកភូមិគ្រប់រូប និងអ្នកទេសចរនៅពេលយប់។ ប្រជាជនប្រមាណ៥១៨គ្រួសារ និងភ្ញៀវទេសចររាប់ពាន់នាក់ទទួលបានអត្ថប្រយោជន៍។



(ii) ការយល់ដឹងជាសាធារណៈ និងការអនុវត្តការសម្អាតសហគមន៍ (CSDG ៣, ៦, ១១, & ១៣) ៖ ដំបូងឡើយ គម្រោងបានចាប់ផ្តើមជាមួយរដ្ឋបាលស្រុក និងអាជ្ញាធរមូលដ្ឋាន ដើម្បីប្រមូល និងរើសសំរាមយ៉ាងហោចណាស់មួយថ្ងៃ ក្នុងមួយខែ ធ្វើជាគំរូល្អសម្រាប់អ្នកភូមិ។ ជាមួយគ្នានេះ លើកទឹកចិត្ត និងពន្យល់គ្រួសារនីមួយៗឱ្យដាក់ធុងសំរាម (ផលិតផលផលិតក្នុងស្រុក) នៅក្នុងភូមិ ។ គំនិតផ្តួចផ្តើមនេះជួយធ្វើឱ្យសហគមន៍កាន់តែស្អាត និងបៃតង ហើយនៅទីបំផុតបានធ្វើឱ្យសហគមន៍កាន់តែមានភាពទាក់ទាញសម្រាប់



ភ្ញៀវទេសចរ។ តាមរយៈការខិតខំប្រឹងប្រែងបែបនេះ ជាលទ្ធផល ភូមិព្រះដាក គឺជាភូមិមួយក្នុងចំណោមភូមិស្អាតបំផុត ហើយក៏បានក្លាយជា "ភូមិទេសចរណ៍គំរូ" នៅក្នុងខេត្តសៀមរាប ក៏ដូចជា នៅក្នុងប្រទេសកម្ពុជាផងដែរ។

(iii) ការកែលម្អយុទ្ធសាស្ត្រជីវភាពប្រជាជនក្នុងតំបន់តាមរយៈការអភិវឌ្ឍន៍វិស័យកសិ-ទេសចរណ៍ ៖ វាផ្តោតលើការបង្កើតការងារ និងឱកាសអាជីវកម្មថ្មីសម្រាប់អ្នកភូមិ (ឧទាហរណ៍ សេវាកម្មផ្ទះស្នាក់នៅ លក់វត្ថុអនុស្សាវរីយ៍ធ្វើដោយដៃ អាហារក្នុងស្រុក និងផ្សេងៗទៀត) និងបង្កើតភាពទាក់ទាញថ្មីៗដោយប្រើ ធនធានដែលមាននៅក្នុងសហគមន៍ (ឧ. រង្វង់មូលបន្ទាយស្រី និងភូមិព្រះដាក) រួមទាំងយុទ្ធនាការផ្សព្វផ្សាយម៉ាកសញ្ញា និងទីផ្សារផលិតផល។

ដូចរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀតក្នុងប្រទេសកម្ពុជាដែរ រដ្ឋបាលស្រុកបន្ទាយស្រីក៏ត្រូវប្រឈមនឹងឧបសគ្គផ្នែកហិរញ្ញវត្ថុផងដែរ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋបាលនេះបានបង្កើតឡើងនូវគំនិតមួយដើម្បីកៀរគរធនធានក្នុងស្រុកពីវិស័យឯកជន និងបុគ្គលម្នាក់ៗនៅក្នុងតំបន់របស់ខ្លួន(CSDG ១៧) តួយ៉ាង ដូចជា កម្មវិធីរែអង្គាសប្រាក់សង្គម។ កម្មវិធីនេះ បានទទួលជោគជ័យដ៏ធំ និងបានទទួលការគាំទ្រយ៉ាងខ្លាំងពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដោយសារការដឹកនាំដ៏រឹងមាំ និងសមិទ្ធផលនៃរដ្ឋបាលនេះ ដែលបានបង្ហាញដល់សាធារណជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា Facebook។




រូបភាពទេសចរណ៍ និងផលិតផលស្រុកបន្ទាយស្រី

ប្រភព៖ ដោយអ្នកសរសេររបាយការណ៍

## ប្រអប់ទី៣ ៖ ការិយាល័យច្រកចេញចូលតែមួយ រួមវិភាគទានដល់មូលដ្ឋានីយកម្ម SDGs នៅកម្ពុជា




ប្រវត្តិ៖ រចនាសម្ព័ន្ធបែបប្រពៃណីនៃការផ្តល់សេវាសាធារណៈត្រូវបានផ្លាស់ប្តូរយ៉ាងខ្លាំងទៅជាការរៀបចំថ្មី និងទំនើប ដែលបម្រើដល់តម្រូវការរបស់ប្រជាពលរដ្ឋ និងអាជីវកម្មបានល្អបំផុត តាមរយៈយន្តការ ការិយាល័យច្រកចេញចូលតែមួយ(OWSO)។ តាមបច្ចេកទេស ការិយាល័យច្រកចេញចូលតែមួយ - ការ ទិញទំនិញមួយកន្លែងសម្រាប់កិច្ចការរដ្ឋបាល- ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់សេវាសាធារណៈ ប្រកបដោយភាពរួសរាយរាក់ទាក់ ដោយនាំយកសេវាកម្មសាមញ្ញៗទាំងអស់នៅក្នុងទីតាំងតែមួយ ឬ ការិយាល័យតែមួយទៅជិតប្រជាពលរដ្ឋ ដែលសេវាកម្មទាំងនោះមានការបញ្ចូលកាន់តែច្រើន មានតម្លា ភាព មានគណនេយ្យភាព និងកាន់តែមានប្រសិទ្ធភាព ។

មកទល់ពេលនេះ ការិយាល័យច្រកចេញចូលតែមួយមាននៅទូទាំង២៥ រាជធានី-ខេត្ត និងក្រុង/ស្រុក/ខណ្ឌទាំង ២០៤ ហើយយ៉ាងហោចណាស់៨០% នៃឃុំ/សង្កាត់ទាំងអស់មានការិយាល័យច្រកចេញចូល តែមួយ។ នៅកម្រិត រាជធានី ខេត្ត មានវិស័យចំនួន១៤ ដែលផ្តល់មកពីក្រសួងចំនួន១២ ខណៈ ១៧ វិស័យបានមកពីក្រសួងចំនួន១៣ នៅកម្រិត ក្រុង ស្រុក ខណ្ឌ និងមានប្រមាណ១.៣០០ ការិយាល័យច្រក ចេញចូលតែមួយនៅកម្រិត រាជធានី ខេត្តនៅទូទាំងប្រទេស។

ចាប់តាំងពីដើមខែកក្កដា ឆ្នាំ២០២២មក ការិយាល័យច្រកចេញចូលតែមួយនៅកម្រិត រាជធានី ខេត្តបាន ផ្តល់សេវាចំនួន២.១លានសេវា ហើយទទួលបានប្រាក់ចំណូលសរុបប្រហែល៧៤លានដុល្លារ (គឺប្រហែល ២០ លានដុល្លារជាមធ្យមក្នុងមួយឆ្នាំ)។ ខណៈពេលដែលការិយាល័យច្រកចេញចូលតែមួយនៅ ក្រុង ស្រុក ខណ្ឌ បានផ្តល់សេវាកម្មចំនួន៧.៦លាន សេវា និងទទួលបានប្រាក់ចំណូលសរុបប្រហែល ១៩ លានដុល្លារ (ជាមធ្យមប្រហែល៥ ទៅ៧ លានដុល្លារក្នុងមួយឆ្នាំ)។ នៅចុងឆ្នាំ ២០២៣ រាជធានី ខេត្ត ទាំងអស់នៅក្នុងប្រទេសកម្ពុជាត្រូវ បានគេរំពឹងថានឹងមានការិយាល័យច្រកចេញ ចូលតែមួយ គ្រប់100% ។




ទាក់ទិននឹងចំណុចនេះដែរ គេសង្កេតឃើញថា ការិយាល័យច្រកចេញចូលតែមួយមានតួនាទី

យ៉ាងសំខាន់ក្នុងការធ្វើមូលដ្ឋានីយកម្មSDGs នៅថ្នាក់ក្រោមជាតិ។ ឧទាហរណ៍ វាជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុក និងកំណើនអាជីវកម្មតាមរយៈការវិនិយោគក្នុងស្រុក សហគ្រិនក្នុងស្រុក និងការប្រកួតប្រជែងអាជីវកម្មដោយយុត្តិធម៌។ ជាទូទៅ វាមានន័យថាមិនទុកនរណាម្នាក់នៅពីក្រោយនោះទេ ព្រោះតាមរយៈការលើកកម្ពស់សេវាសាធារណៈប្រកបដោយភាពរួសរាយរាក់ទាក់នៅក្នុងប្រទេសកម្ពុជានៅថ្នាក់ក្រោមជាតិ។



ការរួមចំណែកពិសេសៗមួយចំនួន មានសង្ខេបជូនដូចខាងក្រោម ៖

- ធានាបាននូវសេវាសាធារណៈប្រកបដោយភាពរួសរាយរាក់ទាក់ និងជាមជ្ឈមណ្ឌលប្រជាពលរដ្ឋនៅកម្ពុជានៅកម្រិតមូលដ្ឋាន។ នៅក្នុងការអនុវត្តជាក់ស្តែង មន្ត្រីការិយាល័យច្រកចេញចូលតែមួយ មានច្បាប់ពិសេស ឬការយកចិត្តទុកដាក់ក្នុងការផ្តល់សេវាដល់ក្រុមងាយរងគ្រោះ ដូចជាជនពិការ ជនក្រីក្រ និងស្ត្រីមានផ្ទៃពោះ។ ក្រុមទាំងនេះទទួលបានបដិសណ្ឋារកិច្ចពិសេស ដោយមិនគិតថ្លៃ និងសេវារហ័សទាន់ចិត្ត។
- កែលម្អបរិយាកាសវិនិយោគក្នុងស្រុក និងបង្កើនឱកាសការងារក្នុងស្រុកសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុក។ ដូចដែលការិយាល័យច្រកចេញចូលតែមួយអនុវត្តជាក់ស្តែងកាត់បន្ថយពេលវេលា (ពេលវេលាជាលុយសម្រាប់អ្នកជំនួញ) និងថ្លៃដើម (ថ្លៃធ្វើដំណើរ នីតិវិធី និងថ្លៃសេវាដែលមិនចាំបាច់) សម្រាប់សាធារណៈជនប្រកបដោយគណនេយ្យភាព និងតម្លាភាព។ ទាំងនេះមានន័យថា ថ្លៃសេវាដែលមិនចាំបាច់ ឬលុយ "ក្រោមតុ" ត្រូវបានលុបចោល។ ទិដ្ឋភាពទាំងអស់នេះគឺជាកត្តាគាំទ្រដ៏សំខាន់សម្រាប់អាជីវកម្មខ្នាតតូចក្នុងស្រុក (ភាគច្រើនជាអាជីវកម្មរបស់ស្ត្រី) ដើម្បីធ្វើឱ្យអាជីវកម្មរបស់ពួកគេស្របច្បាប់ទៅកម្រិតបន្តបន្ទាប់។ វាជា ការបង្កើនឱកាសការងារក្នុងស្រុក និងកាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថានទៅប្រទេសផ្សេងៗ ជាយថាហេតុ។

- ម្យ៉ាងទៀត វាជួយដល់សហគ្រិនក្នុងស្រុក និងសហគ្រាសធុនតូច និងមធ្យម ពីព្រោះការិយាល័យច្រកចេញចូលតែមួយបង្កើតបរិយាកាសល្អ (ហៅថា ប្រព័ន្ធមិត្តភាពអាជីវកម្មខ្នាតតូច) សម្រាប់កំណើនសហគ្រិនក្នុងស្រុក ជាពិសេស យុវជន និងស្ត្រី ដើម្បីលើកកម្ពស់ជីវភាព និងជីវភាពរស់នៅរបស់ពួកគេ។ វាកាត់បន្ថយភាពស្មុគស្មាញនៃដំណើរការសម្រាប់ការចុះបញ្ជីអាជីវកម្មខ្នាតតូច និងការធ្វើឱ្យស្របច្បាប់សម្រាប់សហគ្រិនទាំងនោះ (ដូចជា ការចាប់ផ្តើមរបស់យុវជនវ័យក្មេង-SMEs) ដែលជួយពួកគេឱ្យទទួលបានប្រាក់កម្ចីឥណទាន និង/ឬជំនួយពីវិទ្យាស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ និង/ឬ រដ្ឋាភិបាល។



មានប្រព័ន្ធព័ត៌មានដែលមានស្រាប់ ដើម្បីកត់ត្រាព័ត៌មាននៃការអនុវត្ត និងសេវាកម្មរបស់ការិយាល័យច្រកចេញចូលតែមួយ ដូចជា លេខសេវាកម្ម ចំណូលពីសេវា និងការស្នើសុំសេវាត្រួតពិនិត្យ។ តាមរយៈប្រព័ន្ធទិន្នន័យនេះ បុគ្គលិកក្នុងស្រុកអាចយល់ពីនិន្នាការនៃកំណើនអាជីវកម្មក្នុងស្រុក ក៏ដូចជាបញ្ហាប្រឈមនានា។ ជាលទ្ធផល បុគ្គលិកការិយាល័យច្រកចេញចូលតែមួយ អាចផ្តល់ដំបូន្មានដល់ម្ចាស់អាជីវកម្ម និងបង្កើតបរិយាកាសល្អប្រសើរសម្រាប់កំណើនអាជីវកម្មរបស់ពួកគេ និងអ្នកដទៃ។

រដ្ឋបាលថ្នាក់ក្រោមជាតិអាចប្រមូលចំណូល(ពន្ធក្នុងស្រុក) សម្រាប់របៀបវារៈអភិវឌ្ឍន៍មូលដ្ឋាន។ ឥឡូវនេះ ភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋានអាចប្រមូលចំណូល(ពន្ធក្នុងស្រុក) ពីការផ្តល់សេវាសាធារណៈតាមរយៈការិយា ល័យច្រកចេញចូលតែមួយ។ នៅទីបំផុត ពួកគេអាចបែងចែកថវិកាមួយចំនួនទៅក្នុងរបៀបវារៈ ឬកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគេ (ដូចជាការកាត់បន្ថយភាពក្រីក្រ កម្មវិធីកែលម្អសាលារៀន ការប្រមូលសំរាម និងកម្មវិធីផលប្រយោជន៍សាធារណៈផ្សេងទៀត)។
ឌីជីថលនីយកម្មត្រូវបានកែលម្អនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រព័ន្ធព័ត៌មានថ្មី (ដូចជា ប្រព័ន្ធព័ត៌មានគ្រប់គ្រង-MIS) ត្រូវបានណែនាំនៅក្នុងការិយាល័យច្រកចេញចូលតែមួយ។ តាមរយៈប្រព័ន្ធនេះ រដ្ឋបាលរបស់រដ្ឋាភិបាលក្នុងតំបន់ឥឡូវកាន់តែស្គាល់ (បទពិសោធន៍ និងស្នាដៃ) គេស្គាល់តួនាទី និងឥទ្ធិពលនៃបច្ចេកវិទ្យាឌីជីថលសម្រាប់ការកែលម្អសេវាសាធារណៈ។ មកទល់នឹងពេលនេះ ពួកគេទទួលស្គាល់ថា ពួកគេពឹងផ្អែកលើបច្ចេកវិទ្យា (ប្រព័ន្ធ) ជាជាងការងារដោយដៃ។ ការប្រើប្រាស់បច្ចេកវិទ្យាកំពុងឈានទៅរកការបង្កើនប្រសិទ្ធភាព និងការកែលម្អសេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងពេលជាមួយគ្នានេះ គេសង្កេតឃើញថា មន្ត្រីរដ្ឋាភិបាលក្នុងតំបន់កាន់តែច្រើនឡើងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម(ឧ.Facebook) និងវេទិកាឌីជីថល(ឧ.តេឡេក្រាម)សម្រាប់ធ្វើការ ចែករំលែកព័ត៌មាន និងទំនាក់ទំនង។



ក្រៅពីMIS ក៏មានកម្មវិធី OWSM Cambodia ដែលអនុញ្ញាតឱ្យសាធារណជនសិក្សា និងស្វែងរកសេវាដែលមាន ទាំងតម្លៃសេវា និងតម្រូវការតាមវិស័យនីមួយៗនៅកម្រិតCP, MDK និងCS តាមរយៈទូរស័ព្ទឆ្លាតវៃរបស់ពួកគេ។ កម្មវិធីនេះមិនត្រឹមតែបានលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការិយាល័យច្រកចេញចូលតែមួយនៅក្នុងតំបន់របស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយពួកគេឱ្យយល់ពីរបៀបប្រើប្រាស់សេវាOWSO ប្រកបដោយប្រសិទ្ធភាពថែមទៀត។

*__ប្រភព៖__ ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយតំណាងក្រសួងមហាផ្ទៃ(MOI) និងអនុម័តពីរបាយការណ៍ស្តីពីវឌ្ឍនភាពនៃរបាយការណ៍វាយតម្លៃការិយាល័យច្រកចេញចូលតែមួយដោយ FCM និង NLC តាមរយៈភាពជាដៃគូសម្រាប់ការច្នៃប្រឌិតក្រុង៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុក (PMI-LED ) (ខែសីហា ឆ្នាំ២០២១)។*

## ប្រអប់ទី៤ ៖ គម្រោងធ្វើឱ្យបរិស្ថានរស់នៅ និងសមត្ថភាពបង្ការគ្រោះមហន្តរាយនៅកម្ពុជា កាន់តែល្អប្រសើរ



**រយៈពេល ៖** ២០១៩-២០២០

**ថវិកា ៖ ៩១២.៤០៩ ដុល្លារ**

គាំទ្រដោយ ៖ រដ្ឋាភិបាលជប៉ុន

**ដៃគូអភិវឌ្ឍន៍ ៖** MPLUPC និង UN-Habitat

**ទីតាំង ៖ ខេត្តត្បូងឃ្មុំ**

**សារតារៈ** គម្រោងនេះមានគោលបំណងពង្រឹងសមត្ថភាពធន់ តាមរយៈការកសាងឡើងវិញនូវផ្ទះដែលរងការខូចខាត និងបំផ្លាញដោយសារទឹកជំនន់នាពេលថ្មីៗនេះ ហើយក៏បានជួយដល់សហគមន៍ដែលរងផលប៉ះពាល់ក្នុងការលើកកម្ពស់របៀបរបបរស់នៅ និងជីវភាពរបស់ពួកគេ។ គម្រោងនេះបានរួមចំណែកយ៉ាងសំខាន់ដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចបាននូវ "គោលនយោបាយលំនៅដ្ឋានតម្លៃសមរម្យ" ជាពិសេស SDG១១ "ធ្វើឱ្យទីក្រុងរួមបញ្ចូល សុវត្ថិភាព ធន់ និងមាននិរន្តរភាព"។ ពិសេសជាងនេះទៅទៀត គម្រោងនេះផ្តោតលើគ្រួសារក្រីក្រដែលងាយរងគ្រោះបំផុតដែលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិ (ដូចជាទឹកជំនន់)។ គម្រោងនេះត្រូវបានអនុវត្តដោយមានកិច្ចសហប្រតិបត្តិការណ៍យ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងអាជ្ញាធរមូលដ្ឋានផងដែរ។ វាក៏បានបង្ហាញផងដែរនូវ "វិធីសាស្ត្រស្តារឡើងវិញ តាមតម្រូវការសហគមន៍" ដែលជួយបណ្តុះបណ្តាល និងផ្តល់អំណាចដល់ប្រជាពលរដ្ឋក្នុងតំបន់ (ផ្ទះដែលត្រូវបានបំផ្លាញទាំងស្រុង) ក្នុងវិធីសាស្ត្រសំណង់ធន់ និងលំនៅដ្ឋានធន់នឹងការស្តារឡើងវិញ។ ខណៈពេលដែលនៅថ្នាក់ជាតិ បានបញ្ចូលកម្មវិធីជាតិ និងផ្តល់នូវវិធីសាស្ត្រកសាងសមត្ថភាពដើម្បីធានាបាននូវការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទៅក្នុងរបៀបវារៈនៃការរៀបចំផែនការទីក្រុងក្នុងតំបន់។

### រដ្ឋបាលស្រុក និងក្រុមប្រឹក្សាស្រុក



- ជ្រើសរើសទីតាំងអនុវត្តគម្រោង
- ផ្តល់យោបល់ លើការជ្រើសរើសក្រុមគោលដៅទទួលផលពីគម្រោងដែលជាគ្រួសារក្រីក្រ និងងាយរងគ្រោះ
- កំណត់អត្តសញ្ញាណ និងលក្ខខណ្ឌគ្រួសារត្រូវទទួលបានផ្ទះ
- រៀបចំប្លង់ផ្ទះ និងបញ្ជីសម្ភារៈសាងសង់ និងប៉ាន់ស្មានតម្លៃ.

**រដ្ឋបាលឃុំ និងក្រុមប្រឹក្សាឃុំ**







- គ្រប់គ្រងថវិកាសាងសង់ពីអង្គការ UN-Habitat
- បង្កើតគណកម្មការអភិវឌ្ឍន៍សហគមន៍ (មាន៥០នាក់ ក្នុងនេះមានស្ត្រី ២៨) ដើម្បីពង្រឹងការសាងសង់ផ្ទះ និងភាពជាម្ចាស់
- ចូលរួមរៀបចំប្លង់ផ្ទះ និងបញ្ជីសម្ភារៈសាងសង់ និងប៉ាន់ស្មានតម្លៃ.
- បណ្តុះបណ្តាលអ្នកភូមិ អំពីបច្ចេកទេសសាងសង់ និងជួលជាងក្នុងភូមិ

**អាជ្ញាធរមូលដ្ឋាន**

- ផ្តល់យោបល់បច្ចេកទេស និងត្រួតពិនិត្យប្រចាំថ្ងៃ ដើម្បីធានាថាសំណង់ទាំងនោះស្របនឹងបទដ្ឋានបច្ចេកទេស
- រួមវិភាគទាន សម្រួលដល់ការតាំងទីលំនៅ និងចូលរួមទប់ស្កាត់ផលប៉ះពាល់សង្គម

**អ្នកទទួលផល**

- ចូលរួមពលកម្មក្នុងការសាងសង់ផ្ទះ ដោយឥតគិតថ្លៃ
- ផ្តល់សម្ភារៈសាងសង់មានស្រាប់ក្នុងមូលដ្ឋាន ដូចជា ឫស្សី



បន្ទាប់ពីការប្រកួតប្រជែងគម្រោងក្នុងខែឧសភា ឆ្នាំ ២០២០ ផ្ទះចំនួន២០២ (សាងសង់ថ្មីចំនួន១០៤ និងជួសជុលឡើងវិញចំនួន៩៨) រួមទាំងបង្គន់អនាម័យចំនួន ២០២ ត្រូវបានសាងសង់ទាំងស្រុងដោយមានការរួមចំណែកជាសម្ភារៈពីអ្នកទទួលផល(អ្នកភូមិ) និងបានប្រគល់ជូនដល់គ្រួសារសំខាន់ៗទាំងអស់ដែលបានកំណត់អត្តសញ្ញាណថាជាអ្នកបានរងផលប៉ះពាល់ដោយទឹកជំនន់។ ក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ បង្គន់អនាម័យចំនួន១៤បន្ថែមទៀតត្រូវបានសាងសង់សម្រាប់ ១៤គ្រួសារក្នុងសហគមន៍ទាំង៥ និងបានផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋយ៉ាងហោចណាស់៨៦នាក់។ លក្ខខណ្ឌសម្រាប់អ្នកមានសិទ្ធិទទួលបានផ្ទះ និងបង្គន់អនាម័យត្រូវតែឆ្លើយតបយ៉ាងហោចមួយលក្ខខណ្ឌក្នុងចំណោមលក្ខខណ្ឌទាំងនេះ៖ (១) អ្នកដែលមានប័ណ្ណក្រីក្រ; (២) អ្នករងផលប៉ះពាល់ដោយគ្រោះធម្មជាតិ; និង (៣) គ្រួសារដែលមានសមាជិកលើសពី៥នាក់ ពិសេសមានកុមារ/មនុស្សចាស់ជាច្រើន និង/ឬគ្រួសារដែលមេគ្រួសារជាស្ត្រី។

គម្រោងនេះអាចត្រូវបានគេចាត់ទុកថា ជាផលប៉ះពាល់តិចតួចមួយសម្រាប់ទស្សនវិស័យហេដ្ឋារចនាសម្ព័ន្ធរឹង ប៉ុន្តែវាបានធ្វើជាឧទាហរណ៍សំខាន់នៃភាពជាដៃគូ និងកិច្ចសហការគ្នារវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ ឬភ្នាក់ងារម្ចាស់ជំនួយក្នុងការធ្វើមូលដ្ឋានីយកម្មSDGs នៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូចគ្នានេះផងដែរ វាបង្ហាញពីការយល់ដឹងរយៈពេលវែងដ៏សំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ទាក់ទងនឹងការរៀបចំផែនការទីក្រុងរួមបញ្ចូលគ្នា ជាមួយនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅកម្ពុជា។ ចំណុច

មួយក្នុងចំណោមនោះ គឺតាមរយៈរបៀបវារៈតស៊ូមតិរបស់ខ្លួន ដើម្បីលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យរួមបញ្ចូលការការពារ និងការរៀបចំផែនការនៃគ្រោះមហន្តរាយនៅក្នុងPIP។ គម្រោងនេះបានកំណត់ក្រុមគោលដៅយ៉ាងម៉ឺងម៉ាត់ដើម្បីសម្រេចគោលដៅ គឺ «គ្មានទុកនរណាម្នាក់នៅពីក្រោយការអភិវឌ្ឍ»។

***ប្រភព៖*** *ទំនាក់ទំនងផ្ទាល់ខ្លួនតាមរយៈក្រុមការងារ Microsoft ជាមួយតំណាងការិយាល័យ UN-Habitat ប្រចាំប្រទេសកម្ពុជា (ថ្ងៃទី ០៣ ខែមករា ឆ្នាំ២០២៣) និងរបាយការណ៍វាយតម្លៃបញ្ចប់គម្រោង (ឆ្នាំ២០២០) ដោយ UN-Habitat កម្ពុជា ។*

## ប្រអប់ទី៥ ៖ ក្រុមការងារថ្នាក់ខេត្តសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ (PWG-FSN)

**ប្រវត្តិ** ៖ កំពត ជាខេត្តមួយនៅភាគនិរតីនៃប្រទេសកម្ពុជា បែងចែកជា៧ស្រុក ២ក្រុង ៨៥ឃុំ ៨សង្កាត់ និង ៤៨៨ភូមិ។ មានព្រំប្រទល់ជាប់ខេត្តកោះកុង និងកំពង់ស្ពឺ នៅប៉ែកខាងជើង ជាប់ខេត្តតាកែវ នៅប៉ែកខាងកើត ជាប់ខេត្តកែប និងប្រទេសវៀតណាម នៅប៉ែកខាងត្បូង និងជាប់នឹងខេត្តព្រះសីហនុ ប៉ែកខាងលិច។ ខេត្តកំពតមានឆ្នេរសមុទ្រប្រហែល៤៥ គីឡូម៉ែត្រនៅលើឈូងសមុទ្រថៃ។ ជាខេត្តសម្បូរទៅដោយដីដាំដុះទំនាបហើយមានធនធានធម្មជាតិច្រើនក្រៃលែង។ ទីក្រុងរបស់ខេត្តនេះ គឺ ក្រុងកំពត និងក្រុងបូកគោ។ ប្រជាពលរដ្ឋសរុប គឺ ៥៩២.៨៤៥ (៥៣% ជាស្ត្រី និង៤៧% ជាបុរស)។ ចំណូលចម្បងគឺបានមកពីវិស័យកសិកម្ម ទេសចរណ៍ និងការផ្ញើប្រាក់ពីគ្រួសារដែលរស់នៅក្រៅប្រទេស។ អត្រានៃភាពក្រីក្រក្នុងខេត្ត គឺ១៧.៨% (យោងទៅលើការសិក្សាថ្មីៗក្នុងឆ្នាំ២០២១ ដោយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។

**សមាជិកព្រឹទ្ធសភា មន្ត្រីក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ សមាជិកក្រុមការងារខេត្ត ទស្សនកិច្ចការចិញ្ចឹមត្រីអណ្តែងក្នុងតង់កៅស៊ូ**



**កិច្ចខិតខំប្រឹងប្រែងបានធ្វើឡើង** ៖ PWG-FSN ត្រូវបានបង្កើតឡើងក្នុងខែតុលា ឆ្នាំ ២០២០ ដោយក្រុមប្រឹក្សាខេត្ត ដោយមានជំនួយបច្ចេកទេសពី CARD/CM និង GIZ-MUSEFO ។ ក្រុមការងារថ្នាក់ខេត្តនេះ មានសមាជិកសកម្មមកពីមន្ទីរ៩ ដូចជា PDH, PDWA, PDRD, PDP, PDEYS, PDWRM, PDAFF, និង PDEF បូករួមនឹងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ (HKI, Word Vision, RACHA, GIZ-MUSEFO, និង NGO ក្នុងស្រុក) និងដឹកនាំដោយអភិបាលរងខេត្ត។ មានសមាជិកសរុបចំនួន២៧ រូប។ មន្ទីរនីមួយៗតែងតាំងមន្ត្រី ២រូប គឺ អនុប្រធានមន្ទីរ១រូប និងមន្ត្រីបច្ចេកទេស១រូប ហើយដៃគូអភិវឌ្ឍន៍នីមួយៗតែងតាំងតំណាង១រូប ឱ្យចូលរួម។ PWG-FSN ដឹកនាំដោយអភិបាលរងខេត្ត និងធ្វើជាសហប្រធានដោយ GIZ-MUSEFO ។ PWG-FSN គឺជាយន្តការមួយក្នុងការធ្វើសមាហរណកម្មធនធានផ្សេងៗគ្នា និងប្រមូលផ្តុំចំណេះដឹងបច្ចេកទេសឆ្ពោះទៅរកការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

PDH និង PDAFF មានភាពជឿនលឿនជាងសមាជិកដទៃទៀត ដោយសារ FSN គឺជា អាទិភាពចម្បងមួយនៅក្នុងវិស័យរបស់ពួកគេ។ អាស្រ័យហេតុនេះ មន្ទីរខេត្តទាំងពីរនេះមានធនធានមនុស្សច្រើនជាងគេ ដើម្បីចែក

រំលែកចំណេះដឹង និងបទពិសោធន៍ដល់អ្នកដទៃក្នុងកិច្ចប្រជុំប្រចាំត្រីមាស។ លើសពីនេះ លេខាធិការនៃ PWG-FSN មានការិយាល័យត្រឹមត្រូវដែលបំពាក់ដោយបរិក្ខារព័ត៌មានវិទ្យា ដូចជាប្រព័ន្ធសន្និសីទវីដេអូ កុំព្យូទ័រលើតុ និងកុំព្យូទ័រយួរដៃ អេក្រង់ LCD និងម៉ាស៊ីនបោះពុម្ព។ ការរៀបចំនេះបានធ្វើឱ្យមានភាពងាយស្រួលក្នុងការតភ្ជាប់ជាមួយ PWG-FSN ទាក់ទងនឹងប្រធានបទនៃ FSN នៅថ្នាក់ខេត្ត។

**មុខងាររបស់ PWG-FSN** ៖ ជាមួយនឹងមូលដ្ឋាននៃយុទ្ធសាស្ត្រជាតិសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ PWG-FSN បានបង្កើត និងអនុវត្តផែនការការងារប្រចាំឆ្នាំច្បាស់លាស់។ ពួកគេរៀបចំកិច្ចប្រជុំជាប្រចាំ រៀងរាល់ត្រីមាស ដើម្បីផ្តល់ព័ត៌មានថ្មីៗទៅវិញទៅមក ចែករំលែកបទពិសោធន៍ជាក់ស្តែង កំណត់ និងដោះស្រាយបញ្ហាពាក់ព័ន្ធ និងកំណត់អាទិភាពសម្រាប់ត្រីមាសខាងមុខ។ សមាជិកគ្រប់រូបនៃ PWG-FSN បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ថ្នាក់ឃុំ សង្កាត់ និងភូមិ តាមភារៈកិច្ចចាំបាច់រៀងៗខ្លួន។

ខាងក្រោមនេះ គឺជា ឧទាហរណ៍នៃការវាយតម្លៃដោយការចូលរួមដែលធ្វើឡើងដោយទីប្រឹក្សាជាតិ ហើយត្រូវបានវាស់វែងដោយ PWG-FSN ខ្លួនឯង (ពិន្ទុ ១: ទាបបំផុត, ៥: ខ្ពស់បំផុត)




អន្តរាគមន៍ដែលបានធ្វើឡើងដោយ PWG-FSN គឺបញ្ជាក់ពីរបៀបដែលមន្ទីរវិស័យរបស់រដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ NGO/OI/UNO និងក្រុមប្រឹក្សាឃុំ/សង្កាត់ កំពុងធ្វើការរួមគ្នាក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ចាប់តាំងពីយុទ្ធសាស្ត្រដាក់ចេញនូវអន្តរវិស័យ/ពហុវិស័យ PWG-FSN ពិតជាបានរួមចំណែកដល់ការធ្វើមូលដ្ឋានីយកម្ម និងការសម្រេចបាន SDG #១, #២, #៣, #៥, #៦ និងSDG #១៣។

នៅពេលធ្វើការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តនេះ PWG-FSN ត្រូវបានបង្កើតឡើង និងដំណើរការនៅក្នុងខេត្តចំនួន២៤ និងរាជធានីចំនួន១ នៃប្រទេសកម្ពុជា។

*ប្រភព ៖ ដោយអ្នកសរសេររបាយការណ៍ ករណីសិក្សារបស់អង្គ GIZ-MUSEFO និងឯកសារគម្រោងពិភពលោកមួយគ្មានភាពស្រេកឃ្លាន។*

## ប្រអប់ទី ៦ ៖ ក្រុមការងារថ្នាក់ខេត្ត ដើម្បីបិទបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល ក្នុងវិស័យ WASH

**ប្រវត្តិ៖** ស្វាយរៀង គឺជាខេត្តមួយក្នុងចំណោមខេត្តទាំង២៥ នៃប្រទេសកម្ពុជា។ វាមានទីតាំងនៅភាគខាងកើត នៃប្រទេស និងមានព្រំប្រទល់ជាប់ប្រទេសវៀតណាម ផ្នែកខាងកើតនិងខាងត្បូង។ ខេត្តនេះត្រូវបានគេចាត់ថ្នាក់ជាខេត្តក្រីក្រមួយ។ ស្វាយរៀងមាន ៦ស្រុក ក្រុង២ ឃុំ៦៨ សង្កាត់១២ និងភូមិ៦៩០។ មានប្រជាពលរដ្ឋតាំងលំនៅដ្ឋាន ១៤៣.៣៤១ ខ្នងផ្ទះ ស្មើនឹង១៥២.១៧៣គ្រួសារ និងមានប្រជាពលរដ្ឋសរុប៦៤២.៧១៣នាក់ ក្នុងនោះមានស្រី ៣៣០.៩១៥នាក់។ ប្រភពចំណូលសំខាន់របស់ប្រជាពលរដ្ឋ គឺ កសិកម្ម និងវាយនភណ្ឌ។ លទ្ធភាពទទួលបានសេវាWASH នៅមានកម្រិតទាបនៅឡើយ នៅក្នុងខេត្តនេះ។ មនុស្សជាច្រើនបានធ្លាក់ខ្លួនឈឺដោយជំងឺឆ្លងបណ្តាលមកពីទឹកមិនស្អាត និងកង្វះអនាម័យ ហើយភាគច្រើននៃស្ត្រី និងកុមារជាអ្នករងគ្រោះជាងគេ។

**កិច្ចខិតខំប្រឹងប្រែងបានធ្វើឡើង៖** ក្រុមប្រឹក្សាខេត្តបានបង្កើត PWG/RWSSH (ក្រុមការងារថ្នាក់ខេត្តសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតជនបទ ហេដ្ឋារចនាសម្ព័ន្ធអនាម័យ និងអនាម័យបុគ្គល) និងបានបង្កើតឡើងបន្ថែមទៀតនូវក្រុមការងារ DWG/RWSSH នៅតាមថ្នាក់ស្រុក ក្នុងឆ្នាំ២០១៨។ ក្រុមការងារនេះ មានគោលដៅផ្តល់លទ្ធភាពទទួលបានសេវាWASH ១០០% នៅឆ្នាំ ២០២៣។

**ទិន្នន័យមូលដ្ឋាន**

| សូចនាករ | ២០១៨ | ២០២១ | ២០២៣ |
|---|---|---|---|
| % នៃការទទួលបានហេដ្ឋារចនាសម្ព័ន្ធអនាម័យ | ៨៦.0 | ៩៥.0 | ១00 |
| % នៃការទទួលបានសម្ភារៈលាងសម្អាតដៃ | ៧៥.0 | ១00 | |
| % នៃការទទួលបានទឹកស្អាត | ៩៩.៣ | ៩៩.៤ | ១00 |
| % នៃការទទួលបានទឹកសុវត្ថិភាព | ៨៦.៦ | ៨៨.៦ | ១00 |

PWG/RWSSH បានរៀបចំយុទ្ធសាស្រ្តបំពេញបន្ថែម ដើម្បីជំរុញ និងសម្រេចបាននូវគោលដៅឆ្នាំ២០២៣ ។ ក្នុងការអនុវត្តវិធីសាស្រ្តយុទ្ធសាស្រ្តនោះ និងដោយមានការគាំទ្រពីក្រុមប្រឹក្សាខេត្តផងនោះ ក្រុមការងារថ្នាក់ខេត្ត PWG/RWSSH និងក្រុមការងារថ្នាក់ស្រុក DWG/RWSSH បានធ្វើសកម្មភាពសំខាន់ៗ ដូចជា (i) លើកទឹកចិត្តដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីវិនិយោគធនធានបន្ថែមទៀតសម្រាប់វិស័យWASH; (ii) ក្រុមប្រឹក្សាខេត្ត



បែងចែកមូលនិធិសម្រាប់WASH ដល់សហគមន៍មូលដ្ឋាន (iii) កៀរគរការចូលរួមពីវិស័យឯកជនក្នុងវិស័យទឹកស្អាតនិងអនាម័យ និង (iv) បើកដំណើរការយុទ្ធនាការ អប់រំផ្សព្វផ្សាយព័ត៌មានជាសាធារណៈ និងការលើកកម្ពស់ការយល់ដឹង អំពីការប្រកាន់យកទម្លាប់ល្អក្នុងវិស័យទឹកស្អាត និងអនាម័យ ដោយផ្តោតការយកចិត្តទុកដាក់ខ្លាំងលើប្រធានបទយេនឌ័រ។

**ជាលទ្ធផលៈ** ក្នុងខែមករា ឆ្នាំ២០២៣ ក្រុមវាយតម្លៃថ្នាក់ជាតិ រួមជាមួយនឹងក្រុមការងារថ្នាក់ខេត្ត PWG/RWSSH និងក្រុមការងារថ្នាក់ស្រុកDWG/RWSSHបាន ធ្វើការត្រួតពិនិត្យបច្ចេកទេស ហើយបានសន្និដ្ឋានថា ខេត្តស្វាយរៀង គឺជាខេត្តទីមួយដែលបានបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល(ODF) និងជាខេត្តគំរូក្នុងការជំរុញកំណើនភាគរយទទួលបានសេវាWASH ប្រសើរ។
វិធីសាស្ត្រ និងបទពិសោធន៍ជោគជ័យខាងលើត្រូវបានចម្លងទៅអនុវត្តនៅក្នុងខេត្តផ្សេងៗទៀត។ ហើយក្នុងពេលត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តនេះ យ៉ាងហោចណាស់ខេត្តចំនួន៦ ត្រូវបានចងក្រងជាឯកសារថាទទួលបានជោគជ័យបែបនេះ។

ករណីសិក្សានេះបង្ហាញពីតួនាទីសំខាន់ និងអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តSDGs ជាពិសេស SDG #១, #៣, #៥ និង SDG #៦។

*ប្រភព៖ ដោយអ្នកសរសេររបាយការណ៍ ការទំនាក់ទំនងជាមួយក្រុម WASH/ODF និង PWG/RWSSH*

### ប្រអប់ទី ៧ ៖ ការកសាងសមត្ថភាពធន់របស់អ្នកភូមិនឹងបម្រែបម្រួលអាកាសធាតុ

**ប្រវត្តិ៖** ឃុំដូង ស្ថិតក្នុងស្រុកបាទី ខេត្តតាកែវ។ ជាឃុំដែលមិនសូវមានការអភិវឌ្ឍ ជាពិសេសភូមិមួយឈ្មោះភូមិតានន។ ភូមិនេះ គឺជា ភូមិមួយក្នុងចំណោមភូមិទាំងប្រាំបីរបស់ឃុំដូង។ វាមានទីតាំងភូមិសាស្ត្រជាប់ស្រយាល និងនៅជាប់ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល។ ភូមិនេះស្ថិតនៅភូមិសាស្ត្រលិចទឹកនៅរដូវវស្សា។ មានផ្លូវដីឆ្លងកាត់ភូមិតាននមួយខ្សែ មានប្រវែង៩២៤ម៉ែត្រ (ពីច្រកចូលដល់ចុងភូមិ)។ ភូមិតាននមានផ្ទៃដីសរុប៧១ ហិកតា និងមានលំនៅដ្ឋានសរុបចំនួន១០៧ខ្នងផ្ទះ ស្មើនឹង១២៤គ្រួសារ និងមានសមាជិកសរុបចំនួន៥៦៣នាក់។ ដោយផ្អែកលើការកំណត់អត្តសញ្ញាណកម្មនៃភាពក្រីក្រថ្នាក់ជាតិ ភូមិតាននត្រូវបានគេចាត់ថ្នាក់ ជាភូមិក្រីក្រ។ អ្នកភូមិប្រកបរបរធ្វើស្រែចម្ការ ដែលប្រមូលផលម្ដងក្នុងមួយឆ្នាំ ដោយទទួលបានទិន្នផលជាមធ្យម ២,៥ តោនក្នុងមួយហិកតា។ ក្រៅពីធ្វើស្រែ អ្នកភូមិបានប្រកបរបរនេសាទត្រីនៅរដូវវស្សា សម្រាប់ហូបចុកក្នុងគ្រួសារ និងលក់ដូរក្នុងភូមិ ។ គ្រួសារខ្លះរកប្រាក់ចំណូលបន្ថែមពីការងារផ្នែកវាយនភណ្ឌមានទីតាំងនៅឆ្ងាយពីភូមិ។
នៅឆ្នាំ២០១៩ ក្រុមប្រឹក្សាស្រុកបាទីបានបង្កើតក្រុមការងារមួយ ដែលរួមមានការិយាល័យគ្រប់វិស័យ និងរដ្ឋបាលស្រុក ដើម្បីជួយក្រុមប្រឹក្សាឃុំដូងក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ក្រុមប្រឹក្សាឃុំដូង បានជ្រើសរើសយកភូមិតានន ដើម្បីធ្វើមូលដ្ឋានីយកម្ម និងអនុវត្តCSDGs។

**កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាឃុំក្នុងការធ្វើមូលដ្ឋានីយកម្ម CSDGs នៅកម្រិតភូមិមួយ៖** ក្រុមប្រឹក្សាឃុំបានអនុវត្តគម្រោងបំពេញបន្ថែមចំនួន៦ នៅក្នុងភូមិតានន គឺ (i) ការផ្គត់ផ្គង់ទឹកដែលមានសុវត្ថិភាព (ii) ផ្លូវបេតុងភូមិ (iii) ភ្លើងសូឡាបំភ្លឺផ្លូវ (iv) ការសាងសង់ប្រឡាយភូមិ (v) ការកែច្នៃកាកសំណល់ទៅជាជីសរីរាង្គ និង (vi) ការបង្កើនប្រសិទ្ធភាពកសិកម្ម ។
(i) ការផ្គត់ផ្គង់ទឹកសុវត្ថិភាពតាមទុយោ ៖ គម្រោងនេះប្រើប្រាស់បច្ចេកវិទ្យាថ្មីហៅថា "ការផ្គត់ផ្គង់ទឹកវិមជ្ឈការ" ក្រុមប្រឹក្សាឃុំបានជួសជុលនិងស្ដារស្រះទឹកទំហំ៥៤ម បួនជ្រុង មានជម្រៅ៨ម ដំឡើងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតមួយឈុត ប្រព័ន្ធផ្គត់ផ្គង់ថាមពលស្អាត (សូឡា) និងបានដំឡើងបណ្ដាញទុយោមេប្រវែង២,៦២៨ ម៉ែត្រ និងផ្ដល់ការតភ្ជាប់បណ្ដាញតាមគ្រួសារចំនួន១១៧។ គ្រួសារស្ត្រីមេម៉ាយ គ្រួសារក្រីក្រ គ្រួសារងាយរងគ្រោះ និងគ្រួសារចាស់ជរាឬមានពិការភាព បានទទួលការតភ្ជាប់បណ្ដាញគ្រួសារដោយមិនគិតថ្លៃ ខណៈដែលគ្រួសារក្រៅពីដូចបានរៀបរាប់ខាងលើនេះ បានរួមវិភាគទាន១០ដុល្លារអាមេរិកក្នុងមួយគ្រួសារៗ។
នៅចុងខែធ្នូ ឆ្នាំ២០២២ មានគ្រួសារសរុបចំនួន៨៨% បានប្រើប្រាស់ទឹកសុវត្ថិភាពដែលផ្គត់ផ្គង់តាមប្រព័ន្ធទុយោ ហើយ៩៨% នៃអ្នកប្រើប្រាស់ទឹកបានសម្ដែងការពេញចិត្តចំពោះវត្តមានទឹកសុវត្ថិភាពដល់ផ្ទះ និងភាពងាយស្រួលនៃការប្រើប្រាស់ប្រព័ន្ធទឹកតាមបំពង់ដែលមានសុវត្ថិភាព។ ជាមួយនឹងលទ្ធភាពទទួលបានទឹកសុវត្ថិភាពងាយស្រួលនៅតាមផ្ទះ អាជីវកម្មខ្នាតតូចមួយចំនួន ដូចជា ហាងកាហ្វេ ហាងលក់អាហារ គេហៈសួន ការចិញ្ចឹមសត្វត្រូវបានបង្កើតឡើង។
គម្រោងនេះសម្រេចបានយ៉ាងល្អ លើសពីចក្ខុវិស័យ និងគោលដៅជាតិ ទាក់ទងនឹងលទ្ធភាពទទួលបាន និងការប្រើប្រាស់សេវាផ្គត់ផ្គង់ទឹកសុវត្ថិភាព។ គោលដៅជាតិ គឺធ្វើឱ្យប្រជាពលរដ្ឋទាំងអស់គ្នាទទួលបានទឹកស្អាតប្រើប្រាស់ទាំងអស់នៅឆ្នាំ២០២៥ និងធ្វើឱ្យ៩0% នៃគ្រួសារជនបទទទួលបាននិងប្រើប្រាស់សេវាផ្គត់ផ្គង់ទឹកជាមូលដ្ឋាននៅឆ្នាំ២០២៣។ កិច្ចខិតខំប្រឹងប្រែងនេះបានរួមចំណែកដល់ការទទួលបានទឹកស្អាតប្រកបដោយនិរន្តរភាព និងស្មើភាពនៃCSDG ៦ (ទឹកស្អាត និងអនាម័យ) នៅឆ្នាំ២០៣០។ លើសពីនេះ លទ្ធផលដែលទទួលបានពីគម្រោងក៏បានរួមចំណែកដល់គោលដៅមួយចំនួនទៀតដែរ ដូចជា គោលដៅ SDG ១ (គ្មានភាព

ក្រីក្រ); គោលដៅ ២ (គ្មានភាពអត់ឃ្លាន); គោលដៅ ៣ (សុខភាពល្អ និងសុខុមាលភាពសម្រាប់មនុស្សគ្រប់រូប); គោលដៅ ៥ (សមភាពយេនឌ័រ) និង គោលដៅ ១៣ (សកម្មភាពអាកាសធាតុ)។




(ii) ផ្លូវបេតុងភូមិ ៖ ផ្លូវបេតុងប្រវែងសរុប១,៤៥០ម៉ែត្រ កម្រាស់ ០,៣ម៉ែត្រ ត្រូវបានសាងសង់នៅភូមិតានន។ គម្រោងនេះជួយលើកកម្ពស់ជីវភាពរស់នៅរបស់ភូមិក្នុងការធ្វើដំណើរចេញ ចូលបានទាំងស្រុងនិងងាយស្រួល ហើយថែមទាំងស្រូបទាញអ្នកលក់ដូរ និងភ្ញៀវខាងក្រៅមកភូមិផងដែរ។



(iii) អំពូលភ្លើងតាមដងផ្លូវ៖ បង្គោលភ្លើង/បន្ទះស្រូបពន្លឺព្រះអាទិត្យចំនួន៦៨ដើម ត្រូវបានដំឡើងនៅតាមបណ្ដោយផ្លូវក្រាលបេតុងរបស់ភូមិ។ វាបំភ្លឺផ្លូវចាប់ពីម៉ោង៦ល្ងាចដល់ម៉ោង៦ព្រឹក។ គម្រោងនេះជួយទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ពេលយប់ ជួយសន្សំសំចៃអគ្គិសនីបណ្ដាញ និងជួយលើកកម្ពស់សន្តិសុខសង្គម។

(iv) ការសាងសង់ប្រឡាយ៖ ប្រឡាយបេតុងប្រវែង ១,៤៥៣ ម៉ែត្រ ត្រូវបានសាងសង់នៅភូមិតានន។ វាបង្ហូរទឹកជំនន់និងទឹកសំណល់ពីភូមិទៅវាលស្រែ។ នៅតាមបណ្ដោយប្រឡាយនេះត្រូវបានតុបតែងលម្អដោយរុក្ខជាតិផ្កា។ គម្រោងនេះជួយរំដោះអ្នកភូមិឱ្យរួចផុតពីទឹកជំនន់រដូវវស្សា និងបានកែលម្អទិដ្ឋភាពភូមិទាំងមូលផងដែរ។

(v) ការកែច្នៃកាកសំណល់៖ ក្រុមប្រឹក្សាឃុំដូងចុះកិច្ចសន្យាជាមួយអង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្ដល់ការបណ្ដុះបណ្ដាល និងជួយសម្រួលដល់ការអនុវត្តការកែច្នៃកាកសំណល់ទៅជាជីសរីរាង្គ។ នៅក្នុងសកម្មភាពជាក់ស្ដែង សំណល់រឹងត្រូវបានកែច្នៃឡើងវិញតាមរយៈការធ្វើជីកំប៉ុស ហើយទឹកសំណល់ពណ៌ប្រផេះ និងខ្មៅត្រូវបានកែច្នៃឡើងវិញតាមរយៈការធ្វើប្រព្រឹត្តិកម្មបឋម។ ទាំងជីកំប៉ុស និងទឹកសំណល់ដែលត្រូវបានធ្វើប្រព្រឹត្តិកម្ម ត្រូវបានប្រើប្រាស់ដើម្បីបង្កើនលក្ខខណ្ឌគុណភាពដី និងប្រើប្រាស់ក្នុងផលិតកម្មកសិកម្ម។

(vi) ការបង្កើនប្រសិទ្ធភាពកសិកម្ម៖ វគ្គបណ្ដុះបណ្ដាលបច្ចេកទេសជាបន្តបន្ទាប់លើការធ្វើពិពិធកម្ម និងបង្កើន

ប្រសិទ្ធភាពកសិកម្មត្រូវបានចាប់ផ្តើមនៅក្នុងភូមិ។ ជាលទ្ធផល អ្នកភូមិបានអនុវត្តចំណេះដឹងរបស់ពួកគេក្នុងការងារស្រែចំការ ចិញ្ចឹមត្រីក្នុងស្រែ និងចិញ្ចឹមបសុបក្សី។
ការអនុវត្តសកម្មភាពបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ដោយក្រុមប្រឹក្សាឃុំ បានធ្វើឱ្យជីវភាពអ្នកភូមិកាន់តែប្រសើរឡើង និងបានរួមចំណែកដល់ការសម្រេចបាននូវ CSDG #១, #៣, #៦, #៧, #១០, និង CSDG #១៣។

*ប្រភព៖ អ្នកសរសេររបាយការណ៍*

# ជំពូក ៥ ៖ មធ្យោបាយ និងបញ្ហាប្រឈមក្នុងការអនុវត្តCSDGs

មធ្យោបាយបីផ្សេងគ្នានៃការអនុវត្តCSDGs នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានសង្កេតឃើញនៅក្នុងការរៀបចំរបាយការណ៍ត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តនេះ គឺ (១) គំនិតផ្តួចផ្តើម កម្មវិធី គម្រោង សកម្មភាព(PPAs) ដែលធ្វើឡើងដោយCP/MDK ក្រោមជំនួយផ្នែកហិរញ្ញវត្ថុ និង/ឬបច្ចេកទេសពីរដ្ឋាភិបាលជាតិ។ (២) គំនិតផ្តួចផ្តើមដែលធ្វើឡើងដោយCP/MDK ក្រោមជំនួយផ្នែកហិរញ្ញវត្ថុ និង/ឬបច្ចេកទេសពីDP/DA ឬ NGOs។ និង (៣) គំនិតផ្តួចផ្តើមដែលធ្វើឡើងដោយវិស័យឯកជនក្រោមភាពជាដៃគូជាមួយCP/MDK។ គេសង្កេតឃើញថា ការបែងចែកថវិកាសរុបនៅថ្នាក់ក្រោមជាតិបាននិងកំពុងកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ (សូមមើលតារាងទី៧ និងផ្នែក៣.៣ ខាងលើ និងរូបភាពទី៧)។ ជាងនេះទៅទៀត ការបែងចែកថវិកាឃុំ-សង្កាត់(CSB)មានទំហំធំជាងថវិកាស្រុក-ក្រុង(DMB)។ ប៉ុន្តែវាពិបាកក្នុងការគណនាសមាមាត្រថវិកាតាមគោលដៅនីមួយៗនៃCSDGs នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសារទិន្នន័យមានកំណត់។

**តារាងទី៨ ៖ ការបែងចែកថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

| ខ្ទង់ថវិកា | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ថវិកាក្រសួង | 80.8% | 80.5% | 78.6% | 77.6% | 75.1% | 74.7% | 75.0% |
| ថវិកាមន្ទីរ | 13.8% | 13.5% | 14.8% | 15.6% | 17.8% | 17.9% | 18.2% |
| ថវិកាថ្នាក់ក្រោមជាតិ | 5.4% | 6.0% | 6.6% | 6.9% | 7.1% | 7.4% | 6.7% |
| • រាជធានី ខេត្ត | 3.8% | 3.9% | 4.5% | 4.7% | 4.9% | 5.0% | 4.3% |
| • ក្រុង ស្រុក ខណ្ឌ | 0.0% | 0.5% | 0.5% | 0.5% | 0.6% | 0.7% | 0.6% |
| • ឃុំ សង្កាត់ | 1.6% | 1.6% | 1.6% | 1.7% | 1.6% | 1.7% | 1.7% |

ប្រភព ៖ របាយការណ៍ថវិការបស់NC-SNDD ២០១៨

មានបញ្ហាប្រឈមសំខាន់ៗមួយចំនួនក្នុងការបញ្ចូលCSDGs ទៅក្នុង PDP និង PIP នៅកម្រិតថ្នាក់ក្រោមជាតិ។ កង្វះមូលនិធិ និងការគាំទ្រផ្នែកបច្ចេកទេស ឬជំនួយពីភាគីពាក់ព័ន្ធ (វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល សហគមន៍) គឺជា បញ្ហាប្រឈមសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធ្វើមូលដ្ឋានីយកម្មCSDGs។ ក្នុងអំឡុងពេលជំងឺរាតត្បាតCOVID-19 មានការបង្វែរអាទិភាពដើម្បីដោះស្រាយវិបត្តិសុខភាពសាធារណៈ ប៉ុន្តែកង្វះមូលនិធិនៅតែជាបញ្ហាប្រឈមចម្បង (សូមមើលរូបភាពទី២៦)។




**រូបភាពទី២៦ ៖ បញ្ហាប្រឈមក្នុងការអនុវត្តCSDGs នៅថ្នាក់ក្រោមជាតិ**

បញ្ហាប្រឈមសំខាន់ៗផ្សេងទៀតគឺ ៖

(១) ខ្វះគោលការណ៍ណែនាំជាក់លាក់ និងសូចនាកររបស់CSDGs ដើម្បីអនុវត្ត និងតាមដានវឌ្ឍនភាព និងសមិទ្ធិផលនោះទេ។ អាស្រ័យហេតុនេះ រដ្ឋបាលថ្នាក់ក្រោមជាតិពិបាកធ្វើសមាហរណកម្មCSDGs ទៅក្នុងកម្មវិធីវិនិយោគសាធារណៈ និងផែនការអភិវឌ្ឍន៍របស់ពួកគេ។

(២) គ្មានការិយាល័យ ឬគណៈកម្មាធិការបច្ចេកទេស ដែលទទួលខុសត្រូវក្នុងការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តCSDGs នៅថ្នាក់ក្រោមជាតិឡើយ។ នេះធ្វើឱ្យពួកគេពិបាកក្នុងការស្វែងរកមធ្យោបាយអនុវត្ត និងស្វែងរកជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស។




**រូបភាពទី២៧ ៖ បញ្ហាប្រឈមក្នុងការអនុវត្តCSDGs នៅថ្នាក់ក្រោមជាតិ ក្នុងពេលមានវិបត្តិ កូវីដ១៩**

# ជំពូក ៦ ៖ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

## ៦.១. សេចក្ដីសន្និដ្ឋាន

ការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត(VSR) លើការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តCSDGs ត្រូវបានរៀបចំបង្កើតឡើងដោយNLC ក្រោមការគាំទ្រពី UCLG ASPAC, UCLG និងFCM។ ដំណើរការរៀបចំVSR មានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន រួមទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងទីភ្នាក់ងារម្ចាស់ជំនួយផងដែរ។ ជាមួយគ្នានេះដែរ ខេត្តនីមួយៗ និងMDKs ត្រូវបានលើកទឹកចិត្តឱ្យមានការប្រជុំជាក្រុមនិងជាមួយភាគីពាក់ព័ន្ធ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងតំបន់របស់ពួកគេ ដើម្បីរួមចំណែកផ្តល់មតិ យោបល់ ឆ្លើយកម្រងសំណួរ។

រដ្ឋបាលថ្នាក់ក្រោមជាតិបានបង្ហាញពីតួនាទីសំខាន់ៗជាច្រើនក្នុងការធ្វើមូលដ្ឋានីយកម្មCSDGs ដូចបានរៀបរាប់ក្នុងផ្នែក៤.២ និង៤.៣។ គោលដៅ១៖ គ្មានភាពក្រីក្រកំពុងលេចចេញជាគោលដៅសំខាន់បំផុតមិនត្រឹមតែនៅថ្នាក់ជាតិប៉ុណ្ណោះទេ ថែមទាំងនៅថ្នាក់ក្រោមជាតិទៀតផង។ ទន្ទឹមនឹងនេះ វិធីសាស្ត្រផ្សេងៗត្រូវបានគេសង្កេតឃើញជុំវិញការធ្វើមូលដ្ឋានីយកម្មCSDGs នៅថ្នាក់ក្រោមជាតិ ដែលភាគច្រើនជាការលើកកម្ពស់យល់ដឹងជាសាធារណៈ(រួមទាំងកម្មវិធីពង្រឹងសមត្ថភាព និងការអនុវត្តច្បាប់) និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ(រួមទាំងហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុប្រែប្រួល)។ ទោះជាយ៉ាងណាក៏ដោយ មធ្យោបាយនៃការអនុវត្ត គឺ ពឹងផ្អែកយ៉ាងខ្លាំងទៅលើថវិកាដែលបានបែងចែក និងមាននៅថ្នាក់ក្រោមជាតិ ដែលបច្ចុប្បន្នជាបញ្ហាប្រឈមដ៏សំខាន់មួយ។ ទោះជាយ៉ាងនេះក្តី គេសង្កេតឃើញថា ថវិកាដែលបានបែងចែកសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងពន្ធក្នុងស្រុក បាននិងកំពុងកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

ដូចបានថ្លែងនៅក្នុងផ្នែកទី៤.១ បានលើកឡើង "អ្នកឆ្លើយសំណួរចំនួន៨រូប មើលឃើញថា រដ្ឋបាលថ្នាក់ក្រោមជាតិកំពុងស្ថិតក្នុងការអនុវត្តCSDGs។ អ្នកឆ្លើយសំណួរចំនួន១១រូប មើលឃើញថា រដ្ឋបាលថ្នាក់ក្រោមជាតិកំពុងស្ថិតក្នុងដំណើរការនៃការបន្សុីCSDGs នៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគេ។ អ្នកឆ្លើយសំណួរចំនួន៣៨នាក់ មើលឃើញថា រដ្ឋបាលថ្នាក់ក្រោមជាតិស្ថិតក្នុងដំណាក់កាលនៃការស្វែងយល់ និងការយល់ដឹងអំពីCSDGs" ប៉ុន្តែចាំបាច់ត្រូវទទួលស្គាល់ការងារដ៏ធំធេងដែលរដ្ឋបាលមូលដ្ឋានដាក់ចូលទៅក្នុងការធ្វើមូលដ្ឋានីយកម្ម ទោះបីជាពួកគេមិនបានដាក់ស្លាកសកម្មភាពរបស់ពួកគេថាជា "CSDGs" ក៏ដោយ។

សរុបមក រដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្ត CSDGs នៅក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន ក្នុងកិច្ចខិតខំប្រឹងប្រែងបំពេញបន្ថែមលើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលថ្នាក់ជាតិ។ ពួកគេបានប្រើប្រាស់ធនធានដែលថ្នាក់ជាតិបានបែងចែក ធនធាននិង

ជំនួយពីDP/DA ចំណូលក្នុងស្រុក និងធនធានដែលប្រមូលបានក្នុងមូលដ្ឋាន។ លើសពីនេះ គម្រោងភាគច្រើនដែលអនុវត្តដោយMDK និងC/S បានផ្តល់អត្ថប្រយោជន៍ដល់សហគមន៍មូលដ្ឋាន។

## ៦.២. ការបរិយាយវិភាគ

ក្នុងអំឡុងពេល VSR តួអង្គអភិវឌ្ឍន៍សំខាន់ៗមួយចំនួននៅថ្នាក់ក្រោមជាតិបានយល់ដឹងប្រសើរជាងមុន អំពីខ្លឹមសារ CSDGs ដោយសារតែកន្លងមកពួកគេខ្លះមិនត្រូវបានបញ្ជាក់ពីថ្នាក់លើឱ្យបានច្បាស់ថា ពួកគេត្រូវបានផ្ទេរសិទ្ធិ និងផ្តល់សិទ្ធិអំណាចដើម្បីធ្វើមូលដ្ឋានីយកម្មCSDGs។ ដូច្នេះVSR អាចជួយលើកកម្ពស់ការយល់ដឹងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អំពី ការធ្វើមូលដ្ឋានីយកម្មCSDGs។

លើសពីនេះ តួអង្គសំខាន់ៗមួយចំនួននៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិបានបង្ហាញពីតម្រូវការរបស់ពួកគេក្នុងការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹងលើការបកស្រាយ និងការធ្វើមូលដ្ឋានីយកម្ម CSDGs ដើម្បីឱ្យពួកគេអាចបន្សុីវាទៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគេ។ ពួកគេក៏បានសម្តែងនូវតម្រូវការការគាំទ្រ ការណែនាំ ការគ្រប់គ្រង និងជំនួយបច្ចេកទេសពីថ្នាក់ជាតិNLC និងពីDP/DA។ ក្រៅពីនេះ ពួកគេបានលើកឡើងថា ពួកគេចង់ឱ្យមានទិន្នន័យ/ព័ត៌មានជាមូលដ្ឋានរួមមួយសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគេឱ្យស្របតាមCSDGs។

ការបង្ហាញពីតម្រូវការទាំងនេះ មានន័យថា រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវការការគាំទ្រដើម្បីឱ្យកាន់តែយល់ច្បាស់ អំពីCSDGs និងភារកិច្ចរបស់ពួកគេក្នុងការធ្វើមូលដ្ឋានីយកម្មCSDGs ហើយពួកគេមានការប្តេជ្ញាចិត្តក្នុងការធ្វើមូលដ្ឋានីយកម្ម និងមានការការយល់ដឹងខ្លះៗ អំពីCSDGs។ តម្រូវការពិតប្រាកដ គឺរួមទាំងបច្ចេកទេស និងការណែនាំ ក៏ដូចជាការត្រួតពិនិត្យផងដែរ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសរើសដោយផ្ទាល់ដោយប្រជាពលរដ្ឋនៅតាមមូលដ្ឋានរៀងៗខ្លួន ដើម្បីអនុញ្ញាតឱ្យពួកគេតំណាងឱ្យកម្រិតទាបបំផុតរបស់រដ្ឋាភិបាល និងដើម្បីបម្រើសុខុមាលភាពសាធារណៈនៅតាមមូលដ្ឋាន។ លើសនេះទៅទៀត ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអ្នកបោះឆ្នោតជូនក្រុមប្រឹក្សាCP និង MDK ហើយថែមទាំងបោះឆ្នោតជូនសមាជិកព្រឹទ្ធសភា មួយភាគធំផង។ ក្រុមប្រឹក្សាឃុំ សង្កាត់ ដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើមូលដ្ឋានីយកម្មCSDGs ទន្ទឹមពេលជាមួយគ្នានេះ ពួកគេត្រូវទទួលខុសត្រូវចំពោះអ្នកបោះឆ្នោត គឺប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន។

## ៦.៣. អនុសាសន៍

១. ការលើកកម្ពស់ការយល់ដឹង ការកសាងសមត្ថភាព ការផ្តល់ជំនួយបច្ចេកទេស និងការណែនាំផ្ទាល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តCSDGs គួរតែជាកិច្ចខិតខំប្រឹងប្រែង

បន្ត។ យើងចង់ស្នើឱ្យNLC, NCDD, DP/DA និងNGOs ពាក់ព័ន្ធ បន្តផ្តល់សេវាខាងលើ និងចំណេះដឹងបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការត្រួតពិនិត្យប្រកបដោយការចូលរួមក៏ជាឧបករណ៍មានប្រសិទ្ធភាពមួយដើម្បីជួយរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

២. លទ្ធភាពទទួលបានទិន្នន័យ និងស្ថិតិជាមូលដ្ឋាន ដែលមានលក្ខណៈសាមញ្ញអាចចូលប្រើបាន/និងសមស្របទៅនឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានអត្ថប្រយោជន៍ណាស់សម្រាប់ពួកគេក្នុងការបន្សុំ និងបកស្រាយCSDGs ទៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគេ។ ដូចគ្នានេះដែរ ទិន្នន័យ និងស្ថិតិទាំងនោះគួរតែត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់ និងជៀសវាងនូវភាពខុសគ្នា។

៣. ដើម្បីបង្កើនល្បឿននៃការសម្រេចបានCSDGs ការលើកទឹកចិត្ត និងបញ្ជ្រាបដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរវិស័យពាក់ព័ន្ធឱ្យប្រើប្រាស់CSDGs ជាឯកសារយោង សម្រាប់ការរៀបចំPDP និងPIP ព្រមទាំងលើកទឹកចិត្តឱ្យមូលនិធិវិនិយោគថ្នាក់ក្រោមជាតិ(SNIF) ផ្តោតលើCSDGs ផងដែរនោះ វានឹងជួយបានច្រើន ។

៤. មានការទទួលស្គាល់ជាទូទៅថា ការប្រើប្រាស់ឧបករណ៍ការពារសង្គម និងការការពារបរិស្ថាន (Safeguards) ក្នុងគ្រប់គម្រោងនៅថ្នាក់ក្រោមជាតិ គួរតែត្រូវបានពង្រឹង ព្រោះវាជួយបញ្ចៀសផលប៉ះពាល់អវិជ្ជមានណាមួយនៃគម្រោង និងជួយរួមចំណែកដល់គោលដៅរួមCSDGs "ធានាបាននូវការរួមបញ្ចូល និងសមធម៌ អនាគតប្រសើរ និងនិរន្តរភាព"។

៥. កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តCSDGs គួរតែត្រូវបានចាត់ទុកថាសំខាន់ និងរួមបញ្ចូលនៅក្នុងដំណើរការ ត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត (VSR) យ៉ាងហោចណាស់នៅក្នុងប្រទេសកម្ពុជា។

៦. វាគួរឱ្យចាប់អារម្មណ៍ក្នុងការស្វែងយល់ពីរបៀបដែលរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការរួមគ្នាជាក្រុម ក្នុងការធ្វើមូលដ្ឋានីយកម្មCSDGs។ នេះអាចរួមបញ្ចូលក្នុងកម្រងសំណួរលើកក្រោយៗ ឧ. ចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត(KAP: Knowledge, Attitude and Practice)។ ក្នុងករណីជាច្រើនKAP ជួយបានច្រើនក្នុងការកសាងការងារជាក្រុមឱ្យកាន់តែខ្លាំង និងជួយឱ្យការបំពេញមុខងារបានល្អបំផុត។

៧. សូចនាករCSDGs ជាច្រើនទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីវិស័យឯកជន ដូច្នេះ វាចាំបាច់ណាស់ក្នុងការលើកទឹកចិត្តឱ្យមានការចូលរួមបន្ថែម ពីវិស័យឯកជនក្នុងការធ្វើមូលដ្ឋានីយកម្មCSDGs នៅថ្នាក់ក្រោមជាតិ។

៨. អនុលោមតាមផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់NLC និងជាការឆ្លើយតបទៅនឹងការស្នើសុំរបស់ សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន តាមខេត្ត សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន គួរត្រូវបានស្នើសុំឱ្យពិចារណា លើការស្វែងរកថវិកាសម្រាប់គាំទ្រ សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន តាមខេត្ត(PALC) និង ក្រុមប្រឹក្សាឃុំ សង្កាត់(CS) ក្នុងគម្រោងសន្តិសុខស្បៀង និងអាហារូបត្ថម្ភដែលផ្សាភ្ជាប់ជាមួយគម្រោងទឹកស្អាត និងអនាម័យ ផងដែរ។

៩. សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន(NLC) ត្រូវបានស្នើសុំឱ្យតស៊ូមតិសម្រាប់ការបង្កើនមូលនិធិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស មូលនិធិសម្រាប់ធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តCSDGs។

## ឯកសារយោង សំខាន់ៗ


១) យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤

២) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

៣) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០២៣

៤) គោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥

៥) គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ២០១៥-២០២៥

៦) ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ២០១៣-២០៣០

៧) យុទ្ធសាស្ត្រអព្យាក្រឹត្យកាបោនរយៈពេលវែង ២០២១

៨) ផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣

៩) ផែនការសកម្មភាព និងយុទ្ធសាស្ត្រជីវៈចម្រុះជាតិ ២០១៦-២០២០

១០) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម ២០១៩-២០២៣

១១) នារីរតនៈទី៥ (ផែនការយុទ្ធសាស្ត្រដើម្បីជំរុញការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី ២០១៩-២០២៣

១២) ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០

១៣) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣

១៤) គោលនយោបាយអន្តោប្រវេសន៍ពលកម្ម សម្រាប់កម្ពុជា ២០១៥-២០១៨

១៥) គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥

១៦) ការសិក្សាស្ថាប័ត្យកម្មសារពើពន្ធ អន្តររដ្ឋាភិបាលកម្ពុជា

១៧) ផែនការការងារនិងថវិកាប្រចាំឆ្នាំ របស់ខេត្តបាត់ដំបង កំពង់ចាម ក្រចេះ កំពត

១៨) របាយការណ៍ករណីសិក្សា PWG-FSN និង PWG-ODF

១៩) វឌ្ឍនភាព និងសមិទ្ធផលរួម SDGs នៅកម្ពុជា

២០) របាយការណ៍ត្រួតពិនិត្យមូលដ្ឋានីយកម្ម SDGs

២១) ទិន្នន័យប្រទេសកម្ពុជា របាយការណ៍សង្កេត មូលនិធិថ្នាក់ក្រោមជាតិ និងការវិនិយោគ

## ឧបសម្ព័ន្ធ A ៖ បញ្ជីឈ្មោះបុគ្គលសំខាន់ៗដែលបានផ្តល់ព័ត៌មាន

| ល.រ | ឈ្មោះ | មុខងារ | អង្គភាព |
|---|---|---|---|
| ១ | ឯ.ឧ ប៊ុន ឆេង | ប្រធាននាយកដ្ឋានមុខងារ និងធនធាន | ក្រសួងមហាផ្ទៃ |
| ២ | លោក អ៊ុង កែវរតនៈ | អនុប្រធាននាយកដ្ឋានមុខងារ និង ធនធាន | |
| ៣ | លោក ជីវ សម្បត្តិ | ប្រធានការិយាល័យ | |
| ៤ | លោក ប៊ុន ចំរើន | ប្រធានការិយាល័យ | |
| ៥ | ឯ.ឧ ឡាយ ឈាន | អគ្គនាយករង | វិទ្យាស្ថានជាតិស្ថិតិ នៃ ក្រសួងផែនការ |
| ៦ | លោកស្រី សូ សុវណ្ណចរិយា | អគ្គនាយករង | |
| ៧ | លោក បុយ សុមេធា | ប្រធាននាយកដ្ឋាន | |
| ៨ | លោក ចាន់ សំរិទ្ធ | អនុប្រធាននាយកដ្ឋាន | |
| ៩ | លោក សំ បូនី | អនុប្រធាននាយកដ្ឋាន | |
| ១០ | លោកស្រី | តំណាង | ក្រសួងកិច្ចការនារី |
| ១១ | លោកស្រី | តំណាង | |
| ១២ | លោកស្រី | តំណាង | |
| ១៣ | លោកស្រី នឹម នួន | ប្រធានគោលនយោបាយ | UNDP |
| ១៤ | លោក ជារ៉ា | អ្នកវិភាគគោលនយោបាយ | |
| ១៥ | លោក សុខ វណ្ណា | តំណាងប្រចាំប្រទេស | UN-Habitat |
| ១៦ | លោក ឡុង សូណា | តំណាង | NCSD |
| ១៧ | ឯ.ឧ ប៉ុក សុគន្ធតារា | អគ្គលេខាធិការ | NLC |
| ១៨ | លោកស្រី ទេព កេតសុនី | បុគ្គលិក | |
| ១៩ | លោក សង់ ពលរិទ្ធ | ទីប្រឹក្សា | NCDD |
| ២០ | លោក ជឹម ចរណៃ | ទីប្រឹក្សា WASH | CARD/CM |
| ២១ | លោក ប៉ុល ច័ន្ទរិទ្ធី | ទីប្រឹក្សា | GIZ-MUSEFO |
| ២២ | លោក កៀង សេងគី | ប្រធាន | PALC កំពង់ធំ |
| ២៣ | លោក យស់ យឿន | ប្រធាន | PALC បាត់ដំបង |
| ២៤ | លោក សំរិទ្ធ អេង | ប្រធាន | PALC ពោធិសាត់ |
| ២៥ | លោក ឈួរ ថន | ប្រធាន | PALC កំពង់ឆ្នាំង |
| ២៦ | លោក ជាម សុខ | ប្រធាន | PALC បន្ទាយមានជ័យ |

## ឧបសម្ព័ន្ធ B ៖ បញ្ជីគម្រោងដែលបានអនុវត្តដោយ NLC/NACPC និងចូលរួមដោយរដ្ឋបាលថ្នាក់ក្រោមជាតិ

### គម្រោងលេខ ១ ៖ ផែនការអនុវត្តកម្មវិធីជាតិបីឆ្នាំដំបូង

**គោលបំណង** ៖ អភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ តាមគោលការណ៍ចូលរួមតាមបែបប្រជាធិបតេយ្យ (តម្លាភាព និងគណនេយ្យភាព) ដើម្បីលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាកម្មសាធារណៈស្របតាមតម្រូវការប្រជាពលរដ្ឋ សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងដែនសមត្ថកិច្ចមូលដ្ឋាន។

| | |
|---|---|
| ចំនួនថវិកា | $1,000,000 ដុល្លារសហរដ្ឋអាមេរិក |
| រយៈពេលគម្រោង | 2011-2017 (បញ្ចប់) |
| ផ្តល់មូលនិធិដោយ | គ.ជ.អ.ប |
| ស្រុក/ក្រុងគោលដៅ | ទូទាំងប្រទេស |
| ខេត្តគោលដៅ | ទូទាំងប្រទេស |
| ឆ្លើយតបនឹងSDGs លេខ | 16, 17, 5, 10 |

### គម្រោងលេខ ២ ៖ គម្រោងពង្រឹងសេវាកម្មសមាគមក្រុមប្រឹក្សា

**គោលបំណង** ៖ ប្រែក្លាយសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ (ASAC) ឱ្យទៅ ជាតំណាងដ៏មានប្រសិទ្ធភាពនៃសម្លេងមូលដ្ឋានសម្រាប់ការអភិវឌ្ឍបែបលទ្ធិប្រជាធិបតេយ្យ។

| | |
|---|---|
| ចំនួនថវិកា | UNDP TRAC: $1,600,000 ដុល្លារសហរដ្ឋអាមេរិក<br>សរុប: $4,990,398 ដុល្លារសហរដ្ឋអាមេរិក |
| រយៈពេលគម្រោង | 2012-2017 (បញ្ចប់) |
| ផ្តល់មូលនិធិដោយ | សហគមន៍អឺរ៉ុប-កម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ |
| ស្រុក/ក្រុងគោលដៅ | ទូទាំងប្រទេស |
| ខេត្តគោលដៅ | ទូទាំងប្រទេស |
| ឆ្លើយតបនឹង SDGs លេខ | 16, 17, 5, 10 |

### គម្រោងលេខ ៣ ៖ គម្រោងភាពជាដៃគូសម្រាប់ភាពច្នៃប្រឌិតទីក្រុង ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន (PMI-LED)

**គោលបំណង** ៖ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងដៃគូអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន(LED) ធ្វើការរួមដៃគ្នាបង្កើតនិងបង្កើនបរិយាកាសជំរុញភាពរុងរឿងសេដ្ឋកិច្ចមូលដ្ឋាន ព្រមទាំងជួយគាំទ្រដល់ភ្នាក់ងាររដ្ឋាភិបាលក្នុងមូលដ្ឋានក្នុងការលើកកម្ពស់ធុរកិច្ចតំបន់ ការពង្រីកវិសាលវិនិយោគនិងពាណិជ្ជកម្ម និងពង្រឹការគាំទ្រដល់

| សហគ្រាសខ្នាតតូចនិងមធ្យមក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងការបើកចំហទីផ្សារ | | |
|---|---|---|
| | ចំនួនថវិកា | $1,5 លានដុល្លារសហរដ្ឋអាមេរិក |
| | រយៈពេលគម្រោង | 2015-2020 (បញ្ចប់) |
| | ផ្តល់មូលនិធិដោយ | រដ្ឋាភិបាលកាណាដា |
| | ស្រុក/ក្រុងគោលដៅ | បាត់ដំបង មង្គលបុរី សិរីសោភ័ណ និងប៉ោយប៉ែត |
| | ខេត្តគោលដៅ | បាត់ដំបង និងបន្ទាយមានជ័យ |
| | ឆ្លើយតបនឹង SDGs លេខ | 16, 17, 5, 10 |

**គម្រោងលេខ ៤ ៖ កសាងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការចូលរួម ធ្វើសមាហរណកម្ម និងការកសាងផែនការអភិវឌ្ឍទីក្រុងនិងផែនការគ្រប់គ្រងដីធ្លី ដើម្បីជួយដល់ការតាំងទីលំនៅរបស់អ្នកក្រីក្រទីក្រុង និងជួយសម្រួលឱ្យសហគមន៍ងាយរងគ្រោះនៅទីនោះទទួលបាននូវសេវាកម្មជាមូលដ្ឋាន។**

| **គោលបំណង ៖** ធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការកសាងផែនការអភិវឌ្ឍទីក្រុង និងផែនការប្រើប្រាស់ដីធ្លី ដើម្បីជួយដល់ការតាំងទីលំនៅរបស់អ្នកក្រីក្រទីក្រុង និងជួយសម្រួលឱ្យសហគមន៍ងាយរងគ្រោះទទួលបានសេវាកម្មគ្រប់គ្រាន់ សុវត្ថិភាព និងលំនៅដ្ឋានមានតម្លៃសមរម្យ | | |
|---|---|---|
| | ចំនួនថវិកា | • សហគមន៍អឺរ៉ុប (75%) : 750,000 € (អឺរ៉ូ)<br>• សរុប : 1,004,410 € |
| | រយៈពេលគម្រោង | 2019-2022 (បញ្ចប់) |
| | ផ្តល់មូលនិធិដោយ | សហគមន៍អឺរ៉ុប-AIMF |
| | ស្រុក/ក្រុងគោលដៅ | ទូទាំងប្រទេស |
| | ខេត្តគោលដៅ | ទូទាំងប្រទេស |
| | ឆ្លើយតបនឹង SDGs លេខ | 16, 17, 5, 10 |

**គម្រោងលេខ ៥ ៖ គម្រោងភាពជាដៃគូសម្រាប់ភាពច្នៃប្រឌិតទីក្រុង – លើកកម្ពស់ភាពជាអ្នកដឹកនាំមូលដ្ឋានរបស់ស្ត្រី (PMI-WILL)**

| **គោលបំណង ៖** ធ្វើឱ្យគុណភាពរស់នៅរបស់ស្ត្រីនិងកុមារីមានភាពប្រសើរឡើង ពិសេសស្ត្រីនិងកុមារីទទួលការរើសអើង (សម្រាប់ប្រទេស បេណាំង កម្ពុជា ហ្គាណា ស្រីលង្កា និងប្រទេសសំបី) | | |
|---|---|---|
| | ចំនួនថវិកា | $1,5 លានដុល្លារសហរដ្ឋអាមេរិក |
| | រយៈពេលគម្រោង | 2021-2027 (កំពុងដំណើរការ) |
| | ផ្តល់មូលនិធិដោយ | FCM |
| | ស្រុក/ក្រុងគោលដៅ | ក្រុងកែប ស្រុកទឹកឈូរ រលាប្អៀរ ក្រឡាញ់ និងស្រុកមេសាង |
| | ខេត្តគោលដៅ | កែប កំពត កំពង់ឆ្នាំង សៀមរាប និងខេត្តព្រៃវែង |

| | ឆ្លើយតបនឹង SDGs លេខ | 16, 17, 5, 10 |
|---|---|---|

# ឧបសម្ព័ន្ធ C ៖ សមាសភាពអ្នកផ្តល់ចម្លើយក្នុងកម្រងសំណួរ













ឆ្នាំចូលបម្រើជាមន្ត្រីរាជការ
18
16
14
12
10
8
6
4
2
0
12
9
17
13
9
1980-1990
1991-2000
2001-2010
2011-បច្ចុប្បន្ន
NA


ប្រភពផ្តល់ការសិក្សា អំពីSDG
ផ្សេងៗ
ប្រព័ន្ធព័ត៌មានជាតិ អន្តរជាតិ
អង្គការក្រៅរដ្ឋាភិបាល/សហគមន៍មូលដ្ឋាន
វិទ្យាស្ថានសិក្សា ស្រាវជ្រាវ
អង្គការដៃគូ/ម្ចាស់ជំនួយ
ទីភ្នាក់ងាររាជរដ្ឋាភិបាល
សមាគមជាតិ/សម្ព័ន្ធភាពជាតិ (NLC/PACPC)
2
8
13
3
22
39
27
0
5
10
15
20
25
30
35
40


បាន/មិនបានចូលរួមក្នុង NVR
15%
20%
65%
បាន
អត់
គ្មានចម្លើយ


បំណងចង់/មិនចង់ចូលរួមក្នុង VNR នៅអនាគត
3%
0%
97%
ចង់
មិនចង់
គ្មានចម្លើយ

## ឧបសម្ព័ន្ធ D ៖ វឌ្ឍនភាពគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (ឆ្នាំ២០២១)

| គោលដៅ | លទ្ធផលវាស់វែង | | |
|---|---|---|---|
| | សូចនាករ | ទិន្នន័យឆ្នាំ | ទិន្នន័យឆ្នាំ |
| គោលដៅ ១៖ គ្មានភាពក្រីក្រ | ពលរដ្ឋម្នាក់ៗមានចំណូល ២.១៥ដុល្លារក្នុងមួយថ្ងៃ (PPP ២០១៧) (% នៃប្រជាពលរដ្ឋ) | អត់មានទិន្នន័យវាស់វែង | |
| | បន្ទាត់ភាពក្រីក្រថ្នាក់ជាតិ (% នៃ ប្រជាពលរដ្ឋ) | 23.9 (2009) | 17.7 (2012) |
| | ពហុវិមាត្រនៃភាពក្រីក្រ (% នៃ ប្រជាពលរដ្ឋសរុប) | អត់មានទិន្នន័យវាស់វែង | |
| គោលដៅ ២៖ គ្មានគ្រោះអត់ឃ្លាន | ប្រេវ៉ាឡង់នៃភាពក្រិន កម្ពស់ធៀបអាយុ (% នៃ កុមារអាយុក្រោមអាយុ៥ឆ្នាំ) | 42.8 (2000) | 32.4 (2014) |
| | អត្រាប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភ (% នៃ ប្រជាពលរដ្ឋ) | 24.0 (2001) | 6.0 (2020) |
| | អត្រាប្រេវ៉ាឡង់នៃអសន្តិសុខស្បៀងធ្ងន់ធ្ងរនៅ ក្នុងចំណោមប្រជាពលរដ្ឋ (%) | 16.9 (2015) | 15.1 (2020) |
| | ប្រេវ៉ាឡង់នៃភាពក្រិន កម្ពស់ធៀបអាយុ ក្មេងស្រី (% នៃកុមារីអាយុក្រោម៥ឆ្នាំ) | 48.5 (2000) | 31.9 (2014) |
| | ប្រេវ៉ាឡង់នៃភាពក្រិន កម្ពស់ធៀបអាយុ ក្មេងប្រុស (% នៃកុមារាអាយុក្រោម៥ឆ្នាំ) | 49.4 (2000) | 33.0 (2024) |
| គោលដៅ ៣៖ សុខភាព និងសុខុមាលភាពទាំមួន | សមាមាត្រមរណៈមាតា (ការប៉ាន់ប្រមាណក្នុង ១០០.០០០ កំណើតទារក) | 488 (2000) | 160 (2017) |
| | អត្រាមរណៈភាពកុមារក្រោមអាយុ៥ឆ្នាំ (ក្នុង ១.០០០ កំណើត) | 106 (2000) | 25 (2021) |
| | ឧប្បត្តិហេតុនៃមេរោគអេដស៍អាយុពី ១៥-៤៩ឆ្នាំ (ក្នុង ១.០០០ នាក់ មិនឆ្លងមេរោគមានអាយុចន្លោះពី ១៥-៤៩ ឆ្នាំ) | 98 (2000) | 0.1 (2021) |
| | អត្រាមរណៈភាព កុមារីក្រោមអាយុ ៥ឆ្នាំ (ក្នុង ១.០០០ កំណើត) | 98 (2000) | 22 (2021) |
| | អត្រាមរណៈភាព កុមារាក្រោមអាយុ ៥ឆ្នាំ (ក្នុង ១.០០០ កំណើត) | 114 (2000) | 28 (2021) |
| | អត្រាមានកូនក្នុងចំណោមក្មេងស្រីជំទង់ (កំណើតក្នុងស្ត្រី ១. ០០០ នាក់ មានអាយុពី ១៥-១៩ឆ្នាំ) | 54 (2000) | 46 (2021) |
| គោលដៅ៤៖ ការអប់រំប្រកបដោយគុណភាព | ការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សា (សរុប) សន្ទស្សន៍សមភាពយេនឌ័រ (GPI) | 0.82 (2000) | 1.04 (2021) |
| | អត្រាបញ្ចប់មធ្យមសិក្សាកម្រិតទាប សរុប (% នៃក្រុមអាយុដែលពាក់ព័ន្ធ) | 16.5 (2001) | 57.7 (2021) |
| | អត្រាអក្ខរកម្ម យុវជនសរុប (% នៃមនុស្សអាយុពី ១៥-២៤ ឆ្នាំ) | 83 (2004) | 96 (2021) |
| | អត្រាស្ត្រីបញ្ចប់មធ្យមសិក្សាកម្រិតទាប (% នៃក្រុមអាយុដែលពាក់ព័ន្ធ) | 10.7 (2001) | 63.0 (2021) |
| | អត្រាបុរសបញ្ចប់មធ្យមសិក្សាកម្រិតទាប (% នៃក្រុមអាយុដែលពាក់ព័ន្ធ) | 22.2 (2001) | 52.5 (2021) |

| | | | |
|---|---|---|---|
| គោលដៅ ៥៖ សមភាពយេនឌ័រ | សមាមាត្រនៃអាសនៈដែលគ្រប់គ្រងដោយស្ត្រីនៅក្នុងសភាជាតិ (%) | 7 (2000) | 22 (2021) |
| | អាជីវកម្មគ្រប់គ្រងដោយស្ត្រី និងច្បាប់ពិន្ទុសន្ទស្សន៍ (មាត្រដ្ឋាន ១-១០០) | 63.1 (2000) | 81.3 (2021) |
| | ស្រីចូលរួមនិយោជិកភាព ក្នុងតំណែងអ្នកគ្រប់គ្រងខ្ពស់និងមធ្យម (%) | 15 (2000) | 29 (2019) |
| | ក្រុមហ៊ុនដែលមានស្រីជាមេដឹកនាំកំពូល (% នៃក្រុមហ៊ុន) | 57 (2016) | 57 (2016) |
| គោលដៅ ៦៖ ទឹកស្អាត និងអនាម័យ | ប្រជាពលរដ្ឋប្រើប្រាស់យ៉ាងហោចណាស់ សេវាទឹកស្អាតមូលដ្ឋាន (% នៃចំនួនប្រជាពលរដ្ឋ) | 53 (2000) | 71 (2020) |
| | ប្រជាពលរដ្ឋប្រើប្រាស់យ៉ាងហោចណាស់ទឹកសុវត្ថិភាព និងសេវាអនាម័យ (% នៃចំនួនប្រជាពលរដ្ឋ) | គ្មានទិន្នន័យវាស់វែង | |
| | ប្រជាពលរដ្ឋប្រើប្រាស់យ៉ាងហោចណាស់ សេវាអនាម័យមូលដ្ឋាន (% នៃចំនួនប្រជាពលរដ្ឋ) | 10 (2000) | 69 (2020) |
| | កម្រិតទាញទឹក៖ ការដកទឹកសាបតាមកម្រិតសមាមាត្រនៃធនធានទឹកសាបដែលមាន | 1.04 (2006) | 1.04 (2019) |
| | ប្រជាពលរដ្ឋប្រើប្រាស់ទឹកផឹកសុវត្ថិភាព (% នៃ ប្រជាពលរដ្ឋ) | 17 (2000) | 28 (2020) |
| គោលដៅ ៧៖ ថាមពលស្អាតដែលមានតម្លៃសមរម្យ | ការប្រើប្រាស់ថាមពលកកើតឡើងវិញ (%សរុបនៃការប្រើប្រាស់ថាមពលចុងក្រោយ) | 81.58 (2000) | 53.36 (2019) |
| | % ប្រជាពលរដ្ឋប្រើប្រាស់ថាមពលអគ្គីសនី | 16.6 (2000) | 86.4 (2020) |
| | % ប្រជាពលរដ្ឋប្រើប្រាស់ថាមពលស្អាត និងបច្ចេកវិទ្យាសម្រាប់ការដាំស្ល | 4 (2000) | 37 (2020) |
| | % ប្រជាពលរដ្ឋជនបទ ប្រើប្រាស់ថាមពលអគ្គីសនី | 6.6 (2000) | 82.9 (2020) |
| | % ប្រជាពលរដ្ឋទីក្រុង ប្រើប្រាស់ថាមពលអគ្គីសនី | 60.6 (2000) | 93.3 (2020) |
| គោលដៅ ៨៖ ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច | ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗដែលមានការងារធ្វើ (ថេរឆ្នាំ 2017 PPP ជាប្រាក់ដុល្លារ) | 3,192 (2000) | 7,777 (2021) |
| | កំណើនផលិតផលក្នុងស្រុកសរុប (% ប្រចាំឆ្នាំ) | 10.0 (2000) | 3.0 (2021) |
| | កំណើនផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ(% ប្រចាំឆ្នាំ) | 8.0 (2000) | 1.8 (2021) |
| | ភាពជាម្ចាស់គណនីនៅគ្រឹះស្ថានហិរញ្ញវត្ថុ ឬជាមួយអ្នកផ្តល់សេវាហិរញ្ញវត្ថុតាមទូរស័ព្ទ (% ប្រជាពលរដ្ឋ មានអាយុលើសពី ១៥ឆ្នាំ ឡើងទៅ) | 3.66 (2011) | 33.39 (2021) |
| គោលដៅ ៩៖ ឧស្សាហកម្ម នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ | ការបំភាយឧស្ម័នកាបូន (ម៉ែត្រតោនក្នុងមនុស្សម្នាក់ៗ) | 0.2 (2000) | 1.0 (2019) |
| | ផលិតកម្ម និងតម្លៃបន្ថែម (% នៃផលិតផលក្នុងស្រុកសរុប) | 16 (2000) | 18 (2021) |
| | ការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ (% នៃផលិតផលក្នុងស្រុកសរុប) | 0.05 (2002) | 0.12 (2015) |

| | | | |
|---|---|---|---|
| គោលដៅ ១០៖ កាត់បន្ថយវិសមភាព | ធ្វើអត្រាមធ្យមភាគប្រចាំឆ្នាំសម្រាប់ការស្ទង់មតិជាក់ស្តែង មនុស្សម្នាក់ៗ លើការប្រើប្រាស់ ឬប្រាក់ចំណូល យ៉ាងតិច៤០% នៃចំនួនប្រជាពលរដ្ឋ (%) | គ្មានទិន្នន័យវាស់វែង | |
| | ធ្វើបង្កើនអត្រាមធ្យមភាគប្រចាំឆ្នាំសម្រាប់ការស្ទង់មតិជាក់ស្តែង មនុស្សម្នាក់ៗ លើការប្រើប្រាស់ ឬប្រាក់ចំណូល នៃចំនួនប្រជាពលរដ្ឋ (%) | គ្មានទិន្នន័យវាស់វែង | |
| | សមាមាត្រប្រជាពលរដ្ឋរស់នៅក្រោមចំណូលមធ្យមឱ្យបាន ៥០% (%) | គ្មានទិន្នន័យវាស់វែង | |
| | តម្លៃប្រតិបត្តិការមធ្យមនៃការផ្ទេរប្រាក់ទៅតាមប្រទេសជាក់លាក់នីមួយៗ (%) | 13.56 (2016) | 11.75 (2020) |
| | តម្លៃប្រតិបត្តិការមធ្យមនៃការផ្ទេរប្រាក់មកពីប្រទេសជាក់លាក់នីមួយៗ (%) | គ្មានទិន្នន័យវាស់វែង | |
| គោលដៅ ១១៖ ទីក្រុង និងសហគមន៍ប្រកបដោយចីរភាព | ប្រជាពលរដ្ឋរស់នៅតំបន់មិនរៀបរយ (% នៃ ប្រជាពលរដ្ឋ ទីក្រុង) | 85 (2000) | 40 (2020) |
| | កំណើនប្រជាពលរដ្ឋទីក្រុង (%ប្រចាំឆ្នាំ) | 2.5 (2000) | 2.9 (2021) |
| | ការបំពុលបរិយាកាស PM2.5 ៖ ចំនួនប្រជាជនប្រឈមនឹងកម្រិតលើសពីតម្លៃគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោក (% នៃចំនួនសរុប) | 100 (2000) | 100 (2017) |
| គោលដៅ ១២៖ ការប្រើប្រាស់ និងការផលិតប្រកបដោយការទទួលខុសត្រូវ | ការរក្សាស្ថានភាពកែតម្រូវ ដោយមិនរាប់បញ្ចូលនូវការខូចខាតនៃការបំភាយភាគល្អិត (% នៃ GNI) | 8.1 (2000) | 17.4 (2020) |
| | ការជួលធនធានធម្មជាតិសរុប (% នៃ GDP) | 2.5 (2000) | 1.0 (2020) |
| | គ្រោះរាំងស្ងួត ទឹកជំនន់ សីតុណ្ហភាពប្រែប្រួលខ្លាំង (% នៃចំនួនប្រជាពលរដ្ឋ មធ្យមភាគ 1990-2009) | 6.6 (2009) | 6.6 (2009) |
| គោលដៅ ១៣៖ សកម្មភាពបរិស្ថាន | ពិន្ទុវឌ្ឍនភាពនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (មាត្រដ្ឋាន ១-៥; ៥=ល្អបំផុត) | គ្មានទិន្នន័យវាស់វែង | |
| | ការបំភាយឧស្ម័នផ្ទះកញ្ចក់សរុប (kt នៃឧស្ម័នកាបូន មានសមមូលគ្នា) | 19,380 (2000) | 40,060 (2019) |
| គោលដៅ ១៤៖ ជីវិតក្រោមទឹក | តំបន់ការពារដែនសមុទ្រ (% នៃដែនទឹក) | 0.2 (2016) | 1.4 (2021) |
| | ផលិតកម្មជលផលសរុប (ម៉ែត្រគូប) | 298,798 (2000) | 933,260 (2020) |
| | ផលិតកម្មវារីវប្បកម្មសរុប (ម៉ែត្រគូប) | 14,430 (2000) | 400,400 (2020) |
| | ផលិតកម្មជលផលនេសាទ (ម៉ែត្រគូប) | 284,368 (2000) | 532,860 (2020) |

| | | | |
|---|---|---|---|
| គោលដៅ ១៥៖ ជីវិតលើដី | ផ្ទៃដីព្រៃឈើ (%នៃផ្ទៃដី) | 61.1 (2000) | 45.7 (2020) |
| | តំបន់ការពារដីគោក និងផ្ទៃសមុទ្រ (% នៃផ្ទៃដីសរុប) | 20.6 (2016) | 31.8 (2021) |
| | តំបន់ការពារដីគោក (% នៃផ្ទៃដីសរុប) | 26 (2016) | 39.7 (2021) |
| គោលដៅ ១៦៖ សន្តិភាព យុត្តិធម៌ និង ស្ថាប័នរឹងមាំ | ការចំណាយរបស់រដ្ឋាភិបាលមានសមាមាត្រនឹងផែនការថវិកាដែលបានអនុម័តដើម (%) | 94.1 (2007) | 94.69 (2020) |
| | ឧប្បត្តិហេតុនៃការស៊ីសំណូក (% នៃក្រុមហ៊ុនជួបប្រទះយ៉ាងហោចណាស់មួយនៃសំណើបង់ប្រាក់សំណូក) | 59.5 (2007) | 64.7 (2016) |
| | ភាពពេញលេញនៃការចុះឈ្មោះកំណើត (%) | 66 (2005) | 73 (2014) |
| | ភាពពេញលេញនៃការចុះឈ្មោះកំណើត នៅជនបទ (%) | 66 (2005) | 72 (2014) |
| | ភាពពេញលេញនៃការចុះឈ្មោះកំណើត នៅទីក្រុង (%) | 71 (2005) | 84 (2014) |
| គោលដៅ ១៧៖ ភាពជាដៃគូ ដើម្បីសម្រេច គោលដៅ | ប្រជាពលរដ្ឋម្នាក់ៗប្រើប្រាស់អ៊ិនធឺណែត (% នៃ ប្រជាពលរដ្ឋ) | 0 (2001) | 33 (2017) |
| | ការផ្ទេរប្រាក់ផ្ទាល់ខ្លួន បានទទួល (% នៃ ចំណូលដុលក្នុងស្រុកសរុប) | 2.8 (2000) | 4.3 (2021) |
| | ការវិនិយោគផ្ទាល់ពីបរទេស លំហូរចូលសុទ្ធ (% នៃ ចំណូលដុលក្នុងស្រុកសរុប) | 3.2 (2000) | 12.9 (2021) |
| | សេវាបំណុល (សម្រាប់តែ PPG និង IMF ប៉ុណ្ណោះ ។ % នៃការនាំទំនិញចេញ សេវាកម្ម និងប្រាក់ចំណូលបឋម) | 0.7 (2000) | 1.9 (2021) |
| | ចំណូលពន្ធ (% នៃ ចំណូលដុលក្នុងស្រុកសរុប) | 8.2 (2002) | 17.9 (2020) |
| | ការនាំទំនិញចេញ និងសេវាកម្ម (% នៃ ចំណូលដុលក្នុងស្រុកសរុប) | 49.8 (2000) | 64.6 (2021) |

Source: https://data.worldbank.org/country/cambodia?view=chart

## ឧបសម្ព័ន្ធ E ៖ របាយការណ៍សង្ខេបសិក្ខាសាលាផ្ទៀងផ្ទាត់លទ្ធផល VSR

សិក្ខាសាលាផ្ទៀងផ្ទាត់លទ្ធផលVSR បានដំណើរការទៅនៅព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ នៅសាលប្រជុំភោជនីយដ្ឋានបាយ័ន ក្រោមការដឹកនាំដោយតំណាងមកពីក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងកិច្ចការនារី និងសមាគមក្រុមប្រឹក្សាមូលដ្ឋានខេត្ត និងក្រោមអធិបតីយភាពរបស់ ឯកឧត្តម **សយ កុសល** ប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។ សិក្ខាសាលាខាងលើ មានការចូលរួមយ៉ាងពេញលេញពីបុគ្គលសំខាន់ៗចំនួន៤៧រូប មកពីក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងកិច្ចការនារី សមាគមក្រុមប្រឹក្សាមូលដ្ឋានខេត្ត សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន អង្គការ API អង្គការ UNDP និងក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៃទីស្តីការគណៈរដ្ឋមន្ត្រី។

ក្នុងគោលបំណង ធ្វើបទបង្ហាញ អំពី របកគំហើញនិងលទ្ធផលវិភាគរបស់VSR និងដើម្បីបើកឱ្យមានការពិភាក្សានិងការផ្តល់ជាតុចូលពីគណៈអធិបតី និងពីសិក្ខាកាមផងនោះ សិក្ខាសាលានេះបានដំណើរការទៅឆ្លងកាត់ប្រធានបទ ៤ រួមមាន៖ (១) សន្ទរកថាស្វាគមន៍ និងបើកសិក្ខាសាលា (២) បទបង្ហាញ អំពី របកគំហើញនិងលទ្ធផលវិភាគរបស់VSR (៣) វេទិកាសេរី សំណួរ ចម្លើយ ស្រាយបំភ្លឺ ការពិភាក្សា និងការផ្តល់ជាតុចូលពីគណៈអធិបតីនិងពីសិក្ខាកាម និង (៤) បូកសរុបលទ្ធផលសិក្ខាសាលា និងបិទ ដោយឯកឧត្តម **សយ កុសល**។

ក្នុងសុន្ទរកថាបើកសិក្ខាសាលា ឯកឧត្តម សយ កុសល បានរំលឹកអំពីបុព្វហេតុ និងបានជម្រាបជូនសិក្ខាកាម អំពី គោលបំណងនិងការងារត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត។ លោកបានសម្តែងនូវអំណរគុណចំពោះម្ចាស់ជំនួយ អ្នកគាំទ្រ និងអ្នកចូលរួមទាំងអស់ ព្រមទាំងបានលើកទឹកចិត្តសិក្ខាកាមឱ្យយកចិត្តទុកដាក់លើបទបង្ហាញនិងសូមឱ្យសិក្ខាកាមចែករំលែក គំនិត យោបល់ដោយសេរី ដើម្បីធ្វើសុពលភាពរបាយការណ៍ត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត នេះ។

នៅក្នុងវគ្គពេញអង្គទីពីរ ទីប្រឹក្សាត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត បានធ្វើបទបង្ហាញ លើ (១) វិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត (២)សមាសភាពអ្នកផ្តល់ចម្លើយ តាមតួនាទី តាមវ័យ តាមភេទ និងតាមអតីតភាពការងាររបស់គេ (៣) របកគំហើញ ការវិភាគ និងការបកស្រាយ រួមទាំងឯកសារយោងនិងភស្តុតាង ផងដែរ និង(៤) សេចក្តីសំយោគ និងសំណើ/អនុសាសន៍ ។

ក្នុងវគ្គពេញអង្គទីបី ទីប្រឹក្សាត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត បានលើកទឹកចិត្តឱ្យសិក្ខាកាមនិងគណៈអធិបតី ចូលរួមផ្តល់គំនិត យោបល់ អនុសាសន៍ និងផ្តល់ជាតុចូលដោយសេរី ដូចបានសង្ខេបក្នុងតារាងខាងក្រោម។ សិក្ខាកាមបានបង្ហាញចំណាប់អារម្មណ៍រីករាយនឹងរបាយការណ៍ត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត ដែលរបាយការណ៍នេះបានផ្តិតយកភាពពិតជាក់ស្តែងនូវអ្វីៗដែលបានអនុវត្ត/កើតឡើងនៅថ្នាក់ក្រោមជាតិ។ ពួកគាត់ពេញចិត្ត និងគាំទ្រចំពោះអនុសាសន៍ស្នើឡើងដោយទីប្រឹក្សា។ លើសនេះទៅទៀត ពួកគាត់សម្តែងនូវសេចក្តីសោមនស្សចំពោះអ្វីៗដែលពួកគាត់បាននិងកំពុងខិតខំប្រឹងប្រែងត្រូវបានគេទទួលស្គាល់ និងបានកត់ត្រានៅក្នុងរបាយការណ៍នេះ។

## តារាងសង្ខេបគំនិត យោបល់ សំណួរ និងអនុសាសន៍

| ល.រ | គំនិត យោបល់ សំណួរ និងអនុសាសន៍ ពីអ្នកចូលរួម | ចម្លើយ សេចក្តីស្រាយបំភ្លឺ ពីទីប្រឹក្សា ពីអ្នកចូលរួម និងពីគណៈអធិបតី |
|---|---|---|
| 1 | ក្រសួងផែនការ ៖ ក្រសួងផែនការបានធ្វើការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ដោយឆ្លងកាត់ការសម្ភាសន៍ក្រសួង និងមន្ទីរជំនាញ។<br>ហេតុអ្វី បានជាការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត ធ្វើដោយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានទៅវិញ ហេតុដូចម្តេចមិនអោយក្រសួងផែនការធ្វើទៅ? | ឯកឧត្តម សយ កុសល ៖ ការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តនេះ ជាផ្លែផ្កា បានមកពីកិច្ចពិភាក្សានិងការចរចារច្រើនលើក ច្រើនសារជាមួយដៃគូជាតិនិងអន្តរជាតិ តាំងពីឆ្នាំ ២០១៩ មកម្លេះ។ គំនិតផ្តួចផ្តើមនេះត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអណ្ណត្តិរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។ បន្ទាប់មក សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន បានព្យាយាម ស្វះស្វែងរកការគាំទ្រដើម្បីអនុវត្តផែនការនេះ ដោយយើងមានជំនឿចិត្តថា វាដល់ពេលដែលយើងត្រូវ ពិនិត្យមើលឱ្យស៊ីជម្រៅនូវអ្វីដែលថ្នាក់ក្រោមជាតិបានខិតខំបំពេញ ក្នុងនាមជាសម្ព័ន្ធភាពជាតិនិងសមាគមជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ។ យើងបានទទួលការគាំទ្រពី UCLG និង FCM ហេតុដូច្នេះហើយ បានជា ការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តនេះបានកើតមានឡើងនៅពេលនេះ។ |
| 2 | ក្រសួងផែនការ ៖ ហេតុអ្វី បានជាការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តនេះ ប្រើប្រាស់វិធីសាស្ត្រ ដូចបានធ្វើបទបង្ហាញនេះអញ្ចឹង ហើយតើយកសំណាកអ្នកផ្តល់ព័ត៌មានប៉ុន្មាន? | ទីប្រឹក្សា ៖ វិធីសាស្ត្រដែលបានយកមកប្រើប្រាស់នៅក្នុងការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តនេះ គឺ អនុលោមតាមគោលការណ៍ ស្តង់ដារដែលបានប្រើប្រាស់ជាអន្តរជាតិ។ ចំពោះការយកសំណាកវិញ យើងបានទទួលការឯកភាពពីអ្នកគាំទ្រនិងម្ចាស់ជំនួយ។<br>ជាមួយគ្នានោះ ទីប្រឹក្សាភ្ជាប់និងបង្ហាញបញ្ជីសំណាកអ្នកផ្តល់ព័ត៌មាន។ |
| 3 | ក្រសួងផែនការ ៖ តើរបាយការណ៍នៃការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តនេះនឹងត្រូវបានចែកមកឱ្យក្រសួងផែនការឬទេ? | អគ្គលេខាធិការសម្ព័ន្ធភាពជាតិនិងសមាគមជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ៖ ដូចទីប្រឹក្សាបានបង្ហាញអញ្ចឹង នៅពេលរបាយការណ៍នេះត្រូវបានធ្វើសុពលភាពរួច យើងនឹងប្រគលវាជូនទៅ UCLG បោះពុម្ព។ វាអាស្រ័យលើ UCLG ប៉ុន្តែយើងជឿថា ក្រសួងផែនការនឹងទទួលបានមួយឈុត។ |
| 4 | អង្គការមិនមែនរដ្ឋាភិបាល ៖ អង្គការមិនមែនរដ្ឋាភិបាលក៏កំពុងធ្វើការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តបែបនេះដែរ តែយើងសិក្សាលើការចូលរួម និងវិភាគទានរបស់អង្គការសង្គមស៊ីវិលក្នុងការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្ត SDGs តែប៉ុណ្ណោះ ។ យើងនឹងចែកចាយរបាយការណ៍នេះ នៅពេលវាបានបញ្ចប់។ | ឯកឧត្តម សយ កុសល ៖ សូមអរគុណ ! យើងទន្ទឹងរង់ចាំទទួលរបាយការណ៍នោះ |
| 5 | អង្គការមិនមែនរដ្ឋាភិបាល ៖ តារាងទី៥ ក្នុងបទបង្ហាញ មានភាគរយទាបណាស់។ ហេតុអ្វី ទាបយ៉ាងនេះ?<br>រដ្ឋបាលថ្នាក់ក្រោមជាតិបានធ្វើការងារ | ទីប្រឹក្សា ៖ ភាគរយបានបង្ហាញនៅតារាងទី៥ មិនមែនភាគរយនៃសម្មិទ្ធផលអនុវត្តទេ តែវាជាភាគរយនៃអ្នកផ្តល់ចម្លើយដែលពួកគាត់បានមើលឃើញខ្លួនឯងថាគាត់បានអនុវត្តសកម្មភាពទាំងនោះ តាមសូចនាករនីមួយៗនៃ CSDGs ។ |

| ល.រ | គំនិត យោបល់ សំណួរ និងអនុសាសន៍ ពីអ្នកចូលរួម | ចម្លើយ សេចក្តីស្រាយបំភ្លឺ ពីទីប្រឹក្សា ពីអ្នកចូលរួម និងពីគណៈអធិបតី |
|---|---|---|
| | ច្រើនណាស់ លើការងារ ធ្វើមូលដ្ឋានីយកម្ម និងការអនុវត្ត CSDGs។ | |
| 6 | អង្គការមិនមែនរដ្ឋាភិបាល ៖ រាជរដ្ឋាភិបាលថ្នាក់ជាតិ គួរតែបង្កើនមូលនិធិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តCSDGs។ កន្លងមក មានតែមូលនិធិចំនួន១២,៩% នៃGDP តែប៉ុណ្ណោះ។ ចំនួនថវិកានេះ គួរតែបង្កើន ដើម្បីជំរុញល្បឿនសម្រេចបាននូវCSDGs។ | ឯកឧត្តម សយ កុសល ៖ សូមអរគុណចំពោះអនុសាសន៍នេះ។ យើងយល់ស្របថា មូលនិធិសម្រាប់ការធ្វើមូលដ្ឋានីយកម្មនិងការអនុវត្ត CSDGs របស់រដ្ឋបាលថ្នាក់ក្រោមជាតិ គួរតែតដំឡើងឱ្យលើសពី ១២,៩% នៃ GDP ។ យើងនឹងធ្វើការតស៊ូមតិតាមអនុសាសន៍នេះ។ |
| 7 | ក្រសួងកិច្ចការនារី ៖ យើងបានខិតខំប្រឹងប្រែងអនុវត្ត គោលដៅ(CSDG) លេខ៥ ខ្លាំងណាស់ ប៉ុន្តែតារាងលេខ៥ ក្នុងបទបង្ហាញ ឃើញថាមានភាគរយតិចតួចម្លេះ? | ទីប្រឹក្សា ៖ ជាថ្មីម្តងទៀត ខ្ញុំបាទ សូមជម្រាបថា ភាគរយបានបង្ហាញនៅតារាងទី៥ មិនមែនភាគរយនៃសមិទ្ធផលអនុវត្តទេ តែវាជាភាគរយនៃអ្នកផ្តល់ចម្លើយដែលពួកគាត់បានមើលឃើញខ្លួនឯងថាគាត់បានអនុវត្តសកម្មភាពទាំងនោះ តាមសូចនាករនីមួយៗនៃ CSDGs ។ |
| 8 | ក្រសួងផែនការ ៖ យើងសូមឱ្យទីប្រឹក្សាដាក់បញ្ចូលអនុក្រឹត្យ លេខ ១១៤ ជាឯកសារយោងទៅក្នុងរបាយការណ៍នេះផង។ អនុក្រឹត្យ លេខ ១១៤ ផ្តល់សិទ្ធិអំណាចអោយក្រសួងផែនការសម្របសម្រួល និងគាំទ្របច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តCSDGs។ | ទីប្រឹក្សា ៖ បាទ យើងនឹងអានអនុក្រឹត្យ លេខ ១១៤ នោះ ។ ប្រសិនបើអាច យើងនឹងដាក់បញ្ចូលនៅក្នុងរបាយការណ៍VSR តាមអនុសាសន៍។ |
| 9 | សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្ត ៖ យើងឃើញ ទិន្នន័យនៃអត្រាភាពក្រីក្រ ក្នុងឆ្នាំ ២០១៩ មាន ១៨% ។ តែឯកសារខ្លះដែលយើងបានអាន គឺ ១២% ទៅ ១៣%ប៉ុណ្ណោះ ហេតុអ្វីមានភាពខុសគ្នា? | ក្រសួងផែនការ ៖ ក្នុងឆ្នាំ២០១៩ ក្រសួងផែនការបានសិក្សានិងកំណត់អាត្រាភាពក្រីក្រ ១៣% តែធនាគារពិភពលោកបានណែនាំយើងឱ្យប្រើប្រាស់ឧបករណ៍វាយតម្លៃភាពក្រីក្រថ្មី ហើយក្រសួងផែនការបានប្រើប្រាស់ឧបករណ៍នោះ និងបានវាយតម្លៃភាពក្រីក្រម្តងទៀត ឃើញ ១៨% ។ |
| 10 | សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្ត ៖ ការធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តគោលដៅ(CSDG) លេខ១៧ នៅថ្នាក់ក្រោមជាតិ ពិសេសនៅខេត្តកំពង់ធំ មានកម្រិតខ្ពស់ និងសកម្មខ្លាំង។ យើងបានសហការជាមួយអង្គការដៃគូដើម្បីគណនេយ្យភាពសង្គម (រូបភាពទី១៤) | ទីប្រឹក្សា ៖ បាទមែនហើយ យើងបានសិក្សាឃើញថា ខេត្តកំពង់ធំបានធ្វើមូលដ្ឋានីយកម្ម និងការអនុវត្តគោលដៅ(CSDG) លេខ១៧ សកម្មខ្លាំងណាស់។ ទោះជាយ៉ាងណាក៏ដោយ រូបភាពទី១៤ដែលបានបង្ហាញនោះ ជាទិន្នន័យរួមទូទាំងប្រទេស ហើយមិនបានឆ្លុះដាក់លាក់ចំពោះតែខេត្តកំពង់ធំទេ។ |
| 11 | សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្ត | ទីប្រឹក្សា ៖ បាទ សូមអរគុណ ! ត្រឹមត្រូវហើយ គឺ សមាគមក្រុមប្រឹក្សា |

| ល.រ | គំនិត យោបល់ សំណួរ និងអនុសាសន៍ ពីអ្នកចូលរួម | ចម្លើយ សេចក្តីស្រាយបំភ្លឺ ពីទីប្រឹក្សា ពីអ្នកចូលរួម និងពីគណៈអធិបតី |
|---|---|---|
| | ៖ តំណាងឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ។ ដូច្នេះ សូមសរសេរឱ្យពេញពាក្យ ។ | ថ្នាក់មូលដ្ឋានខេត្ត តំណាងឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ។ យើងនឹងកែតម្រូវ នៅក្នុងភាសាខ្មែរ ។ |

ក្នុងវគ្គពេញអង្គទីបួន អ្នកចាត់តាំងកម្មវិធីបានបូកសរុប និងរាយការណ៍ពីលទ្ធផលម្តងមួយៗរបស់សិក្ខាសាលា ជូនគណៈអធិបតីនិងសិក្ខាកាម។ គាត់បានចែកគណនីតេឡេក្រាមជូនអង្គសិក្ខាសាលាទាំងមូល សម្រាប់ការទំនាក់ទំនង ផ្តល់គំនិត យោបល់ អនុសាសន៍ ការកែតម្រូវ និងការផ្តល់ធាតុចូលនានា សម្រាប់រយៈពេលមួយសប្តាហ៍ក្រោយពីសិក្ខាសាលានេះទៅ។

នៅក្នុងប្រសាសន៍បិទសិក្ខាសាលា ឯកឧត្តម សយ កុសល បានបង្ហាញនូវការពេញចិត្តចំពោះលទ្ធផលសិក្ខាសាលាដែលបានសម្រេចគោលបំណង ដូចការគ្រោងទុក។ ឯកឧត្តមបានថ្លែងអំណរគុណជាថ្មីទៀតចំពោះការចូលរួម និងការរួមវិភាគទានដល់សិក្ខាសាលា និងបានស្នើរសុំថ្នាក់ជាតិបន្តជួយគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងជួយគាំទ្រសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ក្នុងការអនុវត្តនូវអនុសាសន៍ទាំងឡាយក្នុងរបាយការណ៍ត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្តនេះ។

សិក្ខាសាលាពិនិត្យផ្ទៀងផ្ទាត់បានបញ្ចប់នៅម៉ោង១២និង១០នាទី នាកាលបរិច្ឆេទដដែល ក្រោមទឹកមុខញញឹមប្រកបដោយមោទនៈភាព ចំពោះអ្វីដែលថ្នាក់ក្រោមជាតិបានខិតខំប្រឹងប្រែងត្រូវបានទទួលស្គាល់ និងកត់ត្រាទុកក្នុងរបាយការណ៍ការត្រួតពិនិត្យថ្នាក់ក្រោមជាតិដោយស្ម័គ្រចិត្ត។

**<u>ទំព័រចុងបញ្ចប់</u>**